Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

# សំណុំទឹកឃ្មុំ

# Honeycomb

ព្រឹត្តិបត្រទេវសាស្ត្រទ្វេភាសា ខ្មែរ-អង់គ្លេស ផ្តល់នូវចំណេះដឹងផ្នែកព្រះគម្ពីរ
ដល់លោកអ្នក ប្រៀបដូចជាទឹកឃ្មុំផ្តល់កម្លាំងដល់អ្នកដំណើរដែលកំពុងខ្សោយល្វើយ ។

A bilingual Khmer-English Theological Journal to give biblical knowledge to its readers as a honeycomb gives strength to exhausted travelers.

---

ឆ្នាំទី ៣ លេខ ១ ខែ មករា ឆ្នាំ ២០០២

Vol. 3, No. 1 January 2002

គម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ បានបោះពុម្ពព្រឹត្តិបត្រ *សំណុំទឹកឃ្មុំ* នេះឡើង ។
ទាក់ទងតាមការិយាល័យប្រៃសណីយ៍ ប្រអប់សំបុត្រលេខ ៤៧៩ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៦ ០៥២ ទូរសារលេខ (៨៥៥) ២៣ ២១៦ ៤២០
សារអេឡិចត្រូនិច: Russell_Bowers@wvi.org
បណ្ណាធិការ Russell H. Bowers, Jr.
ផ្នែកប្រែសម្រួល: អ៊ួន សិលា
ពិនិត្យផ្ទៀងផ្ទាត់ភាសាខ្មែរ: ម៉ម បាណាបាស
ផ្នែកបច្ចេកទេស: ម៉ាក ច័ន្ទស៊ីថា
សំណោរអត្ថបទ និង ការទាក់ទងផ្សព្វផ្សាយ ត្រូវដាក់ជូនមកបណ្ណាធិការ
បោះពុម្ពនៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

*Honeycomb* is published by Training of Timothys
Central Post Office, P.O. Box 479, Phnom Penh, Kingdom of Cambodia
Email, Russell_Bowers@wvi.org
Editor, Russell H. Bowers, Jr.
Translation, Uon Seila
Khmer proofreading, Barnabas Mam
Technical support, Mark Chann Sitha

Manuscripts and communications should be addressed to the editor.
Printed in Phnom Penh, Kingdom of Cambodia.

VOLUME 3 JANUARY 2002 NUMBER 1

# Honeycomb


**ការត្រាស់ហៅ និង ភារកិច្ចដ៏ឧត្តម នៃអ្នកដឹកនាំក្រុមជំនុំ** ១
*ហេង ចេង*

**The Calling and Great Obligation of Church Leaders** 12
*Rev. HENG Cheng*

**On Respecting Beliefs and People** 18
*Russell H. BOWERS, Jr.*

**ការគោរពជំនឿ និង មនុស្ស** ២៣
*រ៉ាស់សែល ប្វាចទើស៍*

**ពាក់មួកការពារ** ៣២
*អ៊ួន សិលា*

**Wearing A Helmet** 42
*UON Seila*

**Human Rights and Responsibilities**
**Approaching a Biblical Balance** 47
*Rolf LEPELAAR*

**សិទ្ធិមនុស្ស និង ការទទួលខុសត្រូវ** ៥៦
*រហ្វ ឡាប៉ាឡា*

**Jonah—The Reluctant Missionary** 72
*Russell H. BOWERS, Jr.*

**យ៉ូណាស-បេសកជនដែលរារែក** ៨១
*រ៉ាស់សែល ប្វាចទើស៍*

**Biography: YOURNG Soth** 98
*Debbi MAHER*

**ការជួបជាមួយ លោកគ្រូ យង់ សុត** ១០៣
*ដេប៊ី ម៉ាហើ*

**Addresses of the Training of Timothys Board of Directors** 112


First listing of an article is the language in which the article was originally written.

សំណុំធីកឃ្មុំ ៣/១ (មករា ២០០២): ១-១១



# ការត្រាស់ហៅ និង ភារកិច្ចដ៏ឧត្តម នៃអ្នកដឹកនាំក្រុមជំនុំ

*លោកគ្រូ ហេង ចេង*

ក្រុមជំនុំនៃប្រទេសកម្ពុជាបានទទួលរងការឈឺចាប់ជាច្រើន រហូតស្ទើរតែសាបសូន្យ ជាមួយជីវិតដ៏អស់សង្ឃឹមនាសម័យកាលដ៏ខ្មៅងងឹតនៃអតីតកាល ។ ប៉ុន្តែព្រះជាម្ចាស់មានក្តីមេត្តាករុណាស្រឡាញ់ប្រជាជនកម្ពុជា ហើយព្រះអង្គចាប់ផ្តើមតាំងពួកជំនុំព្រះអង្គឡើង តាមព្រះបន្ទូលសន្យារបស់ផងទ្រង់ ។ អស់រយៈពេលជាងពីរទសវត្សរ៍កន្លងទៅហើយ ពួកជំនុំរបស់ព្រះអង្គបានរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ ទោះបីមានការលំបាក ហើយខ្វះខាតដូចម្តេចក៏ដោយ ។ នៅពេលនេះក្រុមជំនុំបានរីកសាយគ្រប់ទីកន្លែងក្នុងប្រទេសទាំងមូល ហើយកំពុងបន្តទៅមុខទៀត ។ ព្រះជាម្ចាស់បានដឹកនាំក្រុមជំនុំរបស់ទ្រង់ តាំងពីប្រទេសជាតិស្ថិតក្នុង សភាពខ្មៅងងឹតរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

ព្រះជាម្ចាស់ត្រូវការអ្នកដឹកនាំជាច្រើននាក់ទៀត ដើម្បីស្ថាបនាក្រុមជំនុំឲ្យបានរឹងមាំឡើង ហើយរីកចំរើនប្រកបដោយនិរន្តភាព ។ ព្រះវិញ្ញាណបរិសុទ្ធបានមានបន្ទូលតាមរយៈលោកសាវ័កប៉ូលថា៖ ខ្ញុំជាបាវរបស់ព្រះយេស៊ូគ្រីស្ទដែលទ្រង់បានហៅមកធ្វើជាសាវ័ក ទាំងញែកចេញទុក

សំរាប់ដំណឹងល្អនៃព្រះ”[១] ។ ព្រះបន្ទូលនេះបង្ហាញពីការត្រាស់ហៅសំរាប់ការងាររបស់ទ្រង់ ដែលជាបេសកកម្មដ៏សំខាន់ព្រះអង្គមានព្រះហឫទ័យចង់ឲ្យយើងជាពួកជំនុំ ជារាស្ត្រដ៏វិសុទ្ធ ជាអ្នកដែលទទួលការប្រោសលោះអំពីទ្រង់មានស្មារតី និងត្រចៀកស្តាប់ឮការត្រាស់ហៅដ៏ពិសេសនេះដើម្បីឆ្លើយតបនិងសេចក្តីត្រូវការចំពោះមុខ ដែលក្រុមជំនុំត្រូវការជាចាំបាច់។ តើមនុស្សម្នាក់អាចឈានចូលក្នុងការងារបំរើព្រះ ក្នុងភារកិច្ចជាអ្នកដឹកនាំក្រុមជំនុំរបស់ព្រះអង្គ ដោយរបៀបណា?

## ការត្រាស់ហៅរបស់ព្រះជាម្ចាស់

ការត្រាស់ហៅគឺជាចំណុចដ៏សំខាន់សំរាប់អ្នកបំរើព្រះជាម្ចាស់ ។ ដ្បិតយោងតាមព្រះបន្ទូលនៅក្នុងយ៉ូហាន ១០:១ បានបង្ហាញឲ្យយើងដឹងថាមានទ្វារសំរាប់ចូលក្នុងក្រោលចៀម ហើយក៏មានចន្លោះផ្សេងទៀតដែរដែលសំរាប់ចូលទៅក្នុងនោះ ។ ដ្បិតមានអ្នកខ្លះបានស្ទុះចូលក្នុងភារកិច្ចធ្វើជាអ្នកដឹកនាំ ដោយមានផែនការផ្សេងៗតាមគំនិតគេគិតទុកជាស្រេច។ អ្នកខ្លះបានទទួលយកភារកិច្ចនេះប្រដូចជាមុខរបរមួយសំរាប់ចិញ្ចឹមជីវិត។ ឯអ្នកខ្លះទៀតនោះយល់ថា ព្រោះបានផ្តល់នូវតួនាទី កិត្តិយសក្នុងឋានៈធ្វើជាអ្នកដឹកនាំដ៏សំខាន់ ។ សរុបសេចក្តីមកកម្លាំងអូសទាញឲ្យចូលធ្វើជាអ្នកបំរើប្រភេទនេះ សុទ្ធតែមិនមែនចូលតាមទ្វារនៃក្រោលចៀម ពិតប្រាកដសោះឡើយ ។ ដ្បិតការទាំងនេះសុទ្ធតែកើតចេញពីសន្ទុះនៃមហិច្ឆតានិងអារម្មណ៍តែប៉ុណ្ណោះ ។ មនុស្សប្រភេទនេះមិនបានងើបភ្នែកមើលទៅរកព្រះជាម្ចាស់ដ៏ពិតប្រាកដនោះឡើយ[២] ។

---

[១] *រ៉ូម ១:១*

[២] *ទំនុក. ១២១:១-២*

ហេតុនេះ ដោយសេចក្ដីជឿជាក់របស់ខ្ញុំ អ្នកដែលឈានចូលក្នុងព័ន្ធកិច្ចបំរើព្រះអម្ចាស់ក្នុងឋានៈជាអ្នកដឹកនាំសំរាប់ដំណឹងល្អរបស់ព្រះគ្រីស្ទ ត្រូវអ្នកនោះបានដឹងច្បាស់អំពីការត្រាស់ហៅរបស់ព្រះសំរាប់ខ្លួន ដើម្បីរស់នៅបំរើភារកិច្ចដែលទ្រង់ប្រគល់ឲ្យ ។ សម្លេងត្រាស់ហៅរបស់ព្រះវិញ្ញាណបានលាន់ឮនៅក្នុងព្រលឹងវិញ្ញាណរបស់យើង វាហាក់ដូចជាចាប់បង្ខំឲ្យយើងត្រូវតែអនុវត្តការងារដ៏ឧត្តមនេះ[៣] ។ ការត្រាស់ហៅនេះ ហាក់បីដូចជារាជបញ្ជាដ៏ដាច់ណាត់សំរាប់ជីវិតរស់នៅរបស់ខ្លួន ដែលមិនអាចបដិសេធបាន ។

ព្រះជាម្ចាស់បានត្រាស់ហៅមនុស្សគ្រប់រូប សំរាប់បំរើកិច្ចការរបស់ទ្រង់តាមបែបខុសៗគ្នា ។ ព្រះអង្គមិនបានបង្ខំយើងជាដំបូងឲ្យចូលនៅក្នុងកិច្ចការនោះឡើយ មុនពេលដែលព្រះអង្គត្រាស់ហៅយើងឲ្យទៅបំរើ ព្រះអង្គគោរពសិទ្ធិនៃអត្តចរិក និងឧត្តមគតិរបស់យើងនៅពេលដែលទ្រង់ហៅយើងម្នាក់ៗនោះ ។ ការនេះឯងហើយដែលនាំឲ្យចិត្តយើងបើកចំហទទួលនូវការត្រាស់ហៅរបស់ព្រះអង្គ ។

ព្រះគម្ពីរបានផ្ដល់នូវគំរូជាច្រើនដែលព្រះជាម្ចាស់ប្រើក្នុងការត្រាស់ហៅឲ្យចូលមកក្នុងការបំរើរបស់ព្រះអង្គ ។ លោកម៉ូសេជាអ្នកគង្វាលដែលបានឃ្វាលចៀមនៅក្នុងស្រុកម៉ាឌាន ។ នៅក្នុងដែលគាត់កំពុងឃ្វាលចៀមនោះនឹកឃើញទៅដល់ការរងឈឺចាប់ របស់ជនជាតិអ៊ីស្រាអែលដែលជាជនរួមជាតិរបស់គាត់ និងអំពើអយុត្តិធម៌ដែលគេបានប្រព្រឹត្តមកលើពួកគេ ដូចដែលគម្ពីរបានពណ៌នានៅក្នុងជំពូក៥៩:១៤ "ឯសេចក្ដីយុត្តិធម៌បានត្រឡប់ថយចេញទៅ ហើយសេចក្ដីសុចរិតក៏ឈរនៅទីឆ្ងាយ ដ្បិតសេចក្ដីពិតបានដួលនៅកណ្ដាលផ្លូវ ហើយសេចក្ដីទៀងត្រង់ចូលមក

---

[៣] *១ កូរិនថូស ៩:១៦*

មិនបាន" ។ នេះគឺជាស្ថានភាពដែលព្រះជាម្ចាស់ត្រាស់ហៅលោកម៉ូសេ ហើយពេលនោះគាត់ត្រូវបង្ខំចិត្តទៅតាមការត្រាស់ហៅនោះ ។

ឯចំណែកលោក អេសាយ វិញ បរិយាកាសនៃការត្រាស់ហៅផ្សេងទៅវិញ ។ លោកអេសាយអាចមានមិត្តសម្លាញ់ជាច្រើនដែលមានឋានៈជាស្តេចនៅក្នុងអាណាចក្រយូដា ជាពិសេស ស្តេច ហេសេគា ។ យោងតាមការប្រើពាក្យ និងផ្តល់ដែលប្រកបដោយប្រាជ្ញានោះ សបញ្ជាក់ឲ្យយើងដឹងថា គាត់ជាមនុស្សដែលមានការអប់រំជ្រៅជ្រះ ។ គាត់ប្រហែលជាអាចមានឱកាសរស់នៅក្នុងព្រះរាជវាំង និងក្នុងកន្លែងដែលមានបរិយាកាសល្អ មិនដូចជាលោកម៉ូសេទេ ដែលរស់នៅក្នុងវាលហោស្ថាននោះ ។ ការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះលោកអេសាយ នៅក្នុងអំឡុងពេលដែលស្តេចអូសៀសសុគត"[៤] ។ ពីព្រោះដោយសារតែស្តេច អូសៀសជាស្តេចមួយអង្គដែលឆ្លាត ទើបប្រទេសជាតិរីកចំរើននៅក្រោមការដឹកនាំរបស់ព្រះអង្គ ហើយបណ្តារាស្ត្រទាំងអស់សង្ឃឹមទុកចិត្តលើស្តេចអង្គនោះ ។ ប៉ុន្តែឥឡូវនេះ នៅពេលដែលស្តេចនោះសុគតទៅសេចក្តីសង្ឃឹមរបស់គេរលាយអស់ទៅហើយ ។ គឺហាក់បីដូចជាការទុកចិត្ត និងក្តីសង្ឃឹមដ៏រឹងមាំរបស់គេត្រូវបាក់ស្រុតអស់ទៅហើយ ។ ប្រទេសជាតិនោះត្រូវប្រឈមមុខនឹងរលំដួលនិង កើតចលាចល ។ នៅពេលនោះបល្ល័ង្ករបស់ស្តេចអូសៀស នៅទំនេរ ដោយព្រោះតែស្តេចនោះសុគតបាត់ទៅហើយនោះ លោកអេសាយមើលឃើញបល្ល័ង្ករបស់ព្រះជាម្ចាស់នៅលើបល្ល័ង្កនោះ ។ ការនេះចង់បញ្ជាក់ប្រាប់ដល់អេសាយថា គ្រឹះស្ថានសំរាប់ទីពឹងរបស់លោកីយ៍នេះមានពេលកំណត់ដែលត្រូវដួលរលំ តែគ្រឹះដ៏មាំមួនរបស់ព្រះជាម្ចាស់នោះ នៅដដែលមិនផ្លាស់ប្រែឡើយ ។ "នៅ

---

[៤] *អេសាយ ៦:១*

ឆ្នាំដែលស្តេចអូសៀសសុគត នោះខ្ញុំឃើញព្រះអម្ចាស់ទ្រង់គង់លើបល្ល័ង្ក នៅទីខ្ពស់" ហើយលោកត្រឡប់ជាឮសម្លេងសូរសៀងរបស់ព្រះអម្ចាស់ចំពោះលោក "តើអញនឹងចាត់អ្នកណាឲ្យទៅ តើអ្នកណានឹងទៅឯអញ"[៥] ព្រះសូរសៀងត្រាស់ហៅនៃព្រះ បានប៉ះពាល់ដួងចិត្តរបស់អេសាយ ហើយបង្ខំលោកឲ្យធ្វើជាហោរារបស់ព្រះ "ទូលបង្គំនៅឯនេះហើយ សូមចាត់ទូលបង្គំចុះ" ។

សូមយើងក្រឡេកមើលលោកយេរេមាម្តង ការត្រាស់ហៅរបស់ព្រះជាម្ចាស់សំរាប់លោកផ្សេងពីអ្នកដទៃទៀត ។ យើងមិនបានដឹងពីស្ថានការណ៍នៅជុំវិញការដែលព្រះត្រាស់ហៅគាត់ឡើយ តែថ្ងៃមួយគាត់បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់មានបន្ទូលថា៖ " មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយនោះ អញស្គាល់ឯង ហើយកាលមុនដែលឯងសំរាលចេញពីផ្ទៃមកនោះអញបានញែកឯងជាបរិសុទ្ធផង ក៏បានតាំងឯងឡើងជាហោរារបស់អស់ទាំងសាសន៍"[៦] នេះជាព្រះសូរសៀងត្រាស់ហៅពិតប្រាកដរបស់ព្រះជាម្ចាស់ ។ គឺជាការពិតមិនមែនជាក្តីស្រមៃនោះ ឡើយ ជាសម្លេងនៃព្រះវិញ្ញាណក្នុងដួងចិត្តដែលមិនអាចបដិសេធបាន ។ ទោះបីមានការភ័យខ្លាចចំពោះភារកិច្ចដ៏ធំនេះក៏ដោយ លោកយេរេមាត្រូវបង្ខំចិត្តទទួលយកការត្រាស់ហៅនេះដោយស្មោះស្មគ្រ ។

នេះគ្រាន់តែជាគំរូខ្លះនៃការត្រាស់ហៅរបស់ព្រះសំរាប់អ្នកបំរើការងាររបស់ទ្រង់សំរាប់ឲ្យយើងបានពិចារណា ។ បើសិនជាយើងពិនិត្យមើលលើព្រះគម្ពីរថែមទៀត នោះយើងនឹងបានប្រទះឃើញការត្រាស់ហៅរបស់ព្រះមានច្រើនទៀត ។ ហេតុនេះយើងមិនអាចនិយាយមុនថា តើព្រះ

---

[៥] អេសាយ ៦:១, ៨

[៦] យេរេមា ១:៥

ត្រាស់ហៅតាមរបៀបដូចម្ដេចបានទេ ប្រសិនបើយើងមិនទាន់ឆ្លងកាត់ការត្រាស់ហៅនេះដោយខ្លួនយើងផ្ទាល់នោះទេ ។ ពេលខ្លះការត្រាស់ហៅរបស់ព្រះអង្គ ពេញទៅដោយភាពកក់ក្ដៅរីករាយដូចនៅក្នុងទំនុកដំកើង ៣២:៨ "អញនឹងបង្ហាត់បង្រៀនឲ្យឯងស្គាល់ផ្លូវដែលឯងត្រូវដើរ អញនឹងទូន្មានឯងដោយភ្នែកអញមើលឯងជាប់" ។ ជួនកាលការត្រាស់ហៅពេញដោយអំណាចចេស្ដាដែលមិនអាចធ្វើឲ្យយើងគេចវេះឬបដិសេធបានឡើយ ។ ដូច្នេះការត្រាស់ហៅរបស់ព្រះអង្គខុសប្លែកគ្នា ប៉ុន្តែគោលបំណងរបស់ព្រះអង្គមានតែមួយគឺជាបេសកកម្មចំពោះពិភពលោកយើងនេះ។ លោកសាវ័កប៉ូលបានសរសេរថា៖ "ហើយគ្រប់គ្នាគឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់នោះនឹងបានសង្គ្រោះ ដូច្នេះ បើគេមិនជឿធ្វើដូចម្ដេចឲ្យគេអំពាវនាវដល់ព្រះបាន ហើយបើគេមិនបានឮនិយាយនោះធ្វើដូចម្ដេចឲ្យគេជឿដល់ព្រះបាន ហើយធ្វើដូចម្ដេចឲ្យគេឮនិយាយបាន បើគ្មានអ្នកណាប្រាប់សោះ មួយទៀតធ្វើដូចម្ដេចឲ្យមានអ្នកណាប្រាប់បាន លើកតែមានអ្នកណាចាត់ឲ្យទៅ ដូចជាមានសេចក្ដីចែងទុកមកថា "ជើងនៃអ្នកដែលប្រកាសប្រាប់ដំណឹងល្អ ពីសេចក្ដីសុខសាន្ត ហើយថ្លែងប្រាប់ពីសេចក្ដីដែលបណ្ដាលឲ្យរីករាយចិត្តនោះល្អប្រពៃយ៉ាងណាហ្ន៎ "[៧] ។

ការរំពឹងគិតចំពោះការត្រាស់ហៅ ដែលព្រះអង្គដាក់កិច្ចការនោះដល់យើងនោះជាការប្រពៃហើយ ក្នុងយើងធ្វើជាអ្នកដឹកនាំក្នុងការងាររបស់ព្រះអង្គ ។

## ការខាវដ៏ធំឧត្តម

អ្នកណាដែលឈានចូលបេសកកម្មបំរើព្រះជាម្ចាស់ ដោយទទួល

---

[៧] រ៉ូម ១០:១៣-១៥

បានការត្រាស់ហៅ នឹងបានយល់ពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ ។ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យមកធ្វើអ្នកទទួលមត៌ករួមជាមួយនឹងព្រះ អង្គ ហើយត្រូវមានភារកិច្ចក្នុងការចែករំលែកចំពោះការនេះ ជាមួយអ្នកដទៃទៀតដែរ គឺចំពោះអ្នកមិនដែលបានទទួលដំណឹងល្អនៅឡើយ ។ ចូរគិតអំពីការត្រាស់ហៅ និងព្រះគុណរបស់ព្រះជាម្ចាស់នោះ យើងនឹងមានការកោតខ្លាចដល់ព្រះអម្ចាស់ និងខំធ្វើការពង្រីកអាណាចក្រថ្វាយព្រះអង្គទៀតផង ។

ការកោតខ្លាចដល់ព្រះអម្ចាស់នេះយើងឃើញនៅក្នុងជីវិតរបស់សាវ័កប៉ូល ។ បន្ទាប់ពីទទួលពន្លឺនៃសេចក្តីសង្គ្រោះរួចមក លោកសាវ័ក ប៉ូលមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការត្រាស់ហៅរបស់ព្រះចំពោះ ខ្លួនគាត់ ។ ព្រះជាម្ចាស់ទ្រង់ចេញរាជបញ្ជាឲ្យលោកសាវ័កប៉ូលប្រកាសពីព្រះគុណរបស់ព្រះអង្គ ។....ព្រះជាម្ចាស់បានផ្តល់ព្រះគុណមកខ្ញុំ គឺឲ្យខ្ញុំប្រកាសដំណឹងល្អដល់សាសន៍ដទៃ ដែលមិនបានទទួលនូវភាពពេញបរិបូណ៌របស់ព្រះគ្រីស្តនោះ" ។[៨] ព្រះគុណនេះជានិច្ចមានពន្លឺចាំងចែងក្នុង ជីវិតរបស់លោកប៉ូលដែលធ្វើឲ្យគាត់កាន់តែមានភាពកោតខ្លាចអំពីភារកិច្ចដែលព្រះប្រទានឲ្យនេះពិសេសនៅពេលដែលមានការសាកល្បង ការលំបាក ឧបសគ្គ ព្រះបានសម្តែងព្រះគុណកាន់តែលើសលុបសំរាប់លោកថែមទៀត ។ ព្រះជាម្ចាស់សម្តែងព្រះគុណយ៉ាងពិសេសមកលោក ប៉ូល ដូចបានចែង នៅក្នុងអេភេសូរ ៣:២ ថា៖ "អ្នករាល់គ្នាបានឮនិយាយពីការត្រួតត្រារបស់ព្រះគុណនៃព្រះដែលបានប្រទានមកខ្ញុំសំរាប់អ្នករាល់គ្នា"។ គាត់បានប្រាប់ដល់ធីម៉ូថេ "ទ្រង់បានតាំងខ្ញុំឲ្យធ្វើជាអ្នកប្រកាសប្រាប់ និង ជាសាវ័កពីការនេះឯង គឺជាគ្រូបង្រៀនដល់ពួកសាសន៍ដទៃ ដោយជំនឿ និងសេចក្តីពិត"[៩] ។ នៅពេល

---

[៨] អេភេសូ ៣:៨

ដែលយើងដឹងប្រាកដពីការត្រាស់ហៅរបស់ព្រះ និងភារកិច្ចដ៏ឧត្តម ដែលព្រះជាម្ចាស់បានប្រគល់មកដល់យើង នោះធ្វើឲ្យយើងមិនអាច នឹងបំភ្លេចបាននូវតួនាទី និងភារកិច្ចដ៏សំខាន់ដែលយើងត្រូវតែបំពេញ ។ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យក្លាយ ជាអ្នកដឹកនាំ និង ថែរក្សាដល់ព្រលឹងមនុស្សដែលទ្រង់ប្រគល់មកឲ្យយើង ដើម្បីដឹកនាំចង្អុលបង្ហាញឲ្យគេស្គាល់ផ្លូវនៃសេចក្ដីពិត ។ យើងត្រូវបង្ហាញផ្លូវដល់គេឲ្យគេស្គាល់ពីជំនឿពិត និងជីវិតពេញបរិបូណ៌នៅក្នុងព្រះគ្រីស្ទ ។ យើងត្រូវផ្ដោតយកចិត្តទុកដាក់នូវភារកិច្ចដែលព្រះជាម្ចាស់ប្រគល់មកឲ្យយើង ។ យើងត្រូវបំពេការងារនោះដោយយកចិត្តទុកដាក់ និង ស្វែងយល់ពីរបៀបដែលមនុស្សសម័យបច្ចុប្បន្ននេះ រស់នៅក្នុងសង្គមនោះ ប្រយោជន៍ដើម្បីជួយរំដោះគេឲ្យរួចពីទាសករនៃអំពើបាប ។ យើងត្រូវធ្វើជាចៅមហាសំរាប់នាំយកកូនក្រមុំថ្មោងថ្មី ទៅឯព្រះគ្រីស្ទមិនសំរាប់សិរីរុងរឿងផ្ទាល់ខ្លួនឯងនោះឡើយ ។

## ការថ្វាយខ្លួនជាយញ្ញបូជាដ៏រស់

ព្រះអម្ចាស់យេស៊ូបានលះបល្ល័ង្កដ៏ពេញសិរីរុងរឿង នាស្ថានសួគ៌ ដើម្បីយករូបភាពជាមនុស្ស រស់នៅក្នុងចំណោមមនុស្សដែលពោរពេញដោយអំពើបាបក្នុងលោកីយ៍នេះ[១០] ដោយព្រះអង្គមកធ្វើជាកូនជាងឈើសាមញ្ញម្នាក់ ។ សូមឲ្យយើងបង្អង់គំនិតពីរឿងដទៃទៀតមកពិចារណាអំពីឧបករណ៍ជាងឈើវិញម្ដង តើមានអត្ថន័យ និងបង្រៀនអ្វីដល់យើង? ជាងឈើគ្រប់រូបតែងតែមានឧបករណ៍គ្រប់មុខសំរាប់ធ្វើឈើ ។ គឺគាត់

---

[៩] ១ ធីម៉ូថេ ២:៧

[១០] យ៉ូហាន ១:៤

មានទាំងរបស់ពិសេស និងរបស់ធម្មតា ដែលជារបស់សាមញ្ញ ។ តើយើងចង់ក្លាយជាឧបករណ៍ណាមួយនៅក្នុងកណ្ដាប់ព្រះហស្ដរបស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះអង្គប្រើឬទេ? ។ នៅក្នុងបទគម្ពីរ ២ធីម៉ូថេ ២:២០-២១បានចែងថា៖ "នៅក្នុងផ្ទះធំ មិនមែនមានសុទ្ធតែប្រដាប់មាសប្រាក់ម្យ៉ាងទេ គឺមានប្រដាប់ធ្វើពីឈើ ហើយពីដីដែរ ខ្លះសំរាប់ការប្រសើរ ខ្លះសំរាប់ការអាប់អោនវិញ ដូច្នេះ បើអ្នកបានសំអាតខ្លួន ពីសេចក្ដីទាំងនោះ អ្នកនោះនឹងបានជាប្រដាប់សំរាប់ការប្រសើរ ដោយបានញែកជាបរិសុទ្ធ ហើយក៏មានប្រយោជន៍ដល់ម្ចាស់ផង ទុកជាប្រដាប់ដែលបានរៀបចំសំរាប់ការល្អគ្រប់ជំពូក" ។

តើធ្វើដូចម្ដេចដើម្បីឲ្យក្លាយជាប្រដាប់ដែលបានរៀបចំការល្អសំរាប់ទ្រង់? មានតែវិធីមួយគត់ គឺថ្វាយជីវិតខ្លួនដល់ទ្រង់ទុកដូចជាយញ្ញបូជារស់ គឺមានន័យថាមិនបន្សល់ទុកអ្វីសំរាប់ប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ ពោលគឺយើងមិនបានពឹងផ្អែកទាំងស្រុងទៅលើសតិបញ្ញារបស់ខ្លួនឡើយ ឬអួតអាងពីការពិសោធន៍បានមកពីការរៀនពីសៀវភៅណាមួយ ឬសាលាណាមួយ ដើម្បីបំរើព្រះអង្គនោះឡើយ ។ គឺមានតែសាលាមួយដែលហ្វឹកហ្វឺនយើងជាសាលាដែលមិនកើតឡើងដោយដៃមនុស្ស ។ បើយើងចង់បំរើការងារមានប្រសិទ្ធិភាពត្រូវស្ម័គ្រចិត្តចូលរៀននៅទីនោះ សាលានោះ គឺការសាកល្បង ហើយគ្រូរបស់យើងគឺឧបសគ្គ ដើម្បីឲ្យយើងពុះពារឆ្លងកាត់ដោយខ្លួនឯង ។ តើនរណាអាចប្រឡងជាប់ចេញពីសាលាបែបនេះ? គឺអ្នកដែលទ្រាំទ្រ នឹងការឈឺចាប់ ការសាកល្បងកាន់តែច្រើននោះ កាន់តែមានប្រយោជន៍ក្នុងការរីកចំរើនដល់អ្នកបំរើព្រះកាន់តែខ្លាំង ។ សាវ័កប៉ូលបានបញ្ជាក់ថា៖ "យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ"[១១] ។

---

[១១]រ៉ូម ៥:១-៥; ១ ពេត្រុស ៤:១២-១៣; យ៉ាកុប ១:២-៣

សូមរំលឹកឡើងវិញពីឧបករណ៍របស់ជាងឈើវិញម្តងទៀត ។ ឧបករណ៍ដែលជាងយកមកប្រើច្រើន ទើបដឹងពីគុណភាពរបស់វា ថាតើល្អឬមិនល្អ ឬក៏ប្រើចំពោះឈើដែលរឹង ហើយនិងនៅជាប់បានយូរនោះឯង ដែលជាឧបករណ៍ដ៏ប្រសើរបំផុតរបស់ព្រះអង្គ ។ យើងជួនកាលអួតពីសមត្ថភាពរបស់យើងក្នុងការបំរើព្រះអម្ចាស់ ប៉ុន្តែនៅពេលដែលយើងចូលប្រឡូកនៅក្នុងសមរភូមិនៃការងារពិតប្រាកដនោះ ទើបយើង (និងអ្នកដទៃ) បានដឹងថាតើព្រះជាម្ចាស់បានរាប់យើង ជាផ្លែដែកឈូស ឬផ្លែពន្លាក ដែលអាចបុកទម្លុះឈើរឹងបាននោះ ។ តើខ្ញុំជាផ្លែដែកឈូស ឬផ្លែពន្លាកដែលបានលត់ក្នុងភ្លើងឲ្យបានក្លាយជាដែកថែបដ៏រឹងមាំអាចទម្លុះធ្លុះឈើរឹងបាន ឬក៏ទន់ជ្រាយពេកមិនអាចប្រើបាននោះ?

លោក មូឌី បានថ្វាយជីវិតរបស់លោកសំរាប់ការងាររបស់ព្រះជាម្ចាស់ ។ គាត់បានក្លាយទៅជាឧបករណ៍ដ៏មានតម្លៃ និងមានប្រយោជន៍នៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះជាម្ចាស់ ថ្វីបើលោកកើតនៅក្នុងគ្រួសារក្រខ្សត់នៅក្នុងតំបន់ នតហ្វៀល នៅក្នុងរដ្ឋ ម៉ាស្សាឈូសេត សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ១៨៣៧ ។ គាត់បានក្លាយទៅជាវិរបុរសនៃអ្នកសរសើរតម្កើងព្រះជាម្ចាស់ដោយជំនឿលើព្រះយេស៊ូគ្រីស្ទរបស់លោក ។ ព្រះជាម្ចាស់បានប្រើប្រាស់លោកសំរាប់មហាបេសកកម្មរបស់ព្រះអង្គ តាមរយៈជីវិតរបស់លោក៖

១. លោកថ្វាយខ្លួនជាយញ្ញបូជារស់ ដោយមិនទុកអ្វីសំរាប់ជាប្រយោជន៍ផ្ទាល់ខ្លួនសោះ ។
២. លោកជាមនុស្សដែលអធិស្ឋាន ទុកចិត្តលើព្រះជាម្ចាស់ទាំងស្រុងអស់ពីដួងចិត្ត ។
៣. លោករៀនសូត្រ និងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។
៤. លោកជាមនុស្សអត់ធ្មត់ ស៊ូទ្រាំ និងសុភាព ។

៥. លោកបានដោះរួចពីការលោភលន់ប្រាក់កាក់ ។

៦. លោកមានចិត្តឆេះឆួលអាណិតមេត្តាដល់មនុស្សដែលកំពុងបាត់បង់ក្នុងអំពើបាប ។

៧. លោកបានទទួលអំណាចពីស្ថានដ៏ខ្ពស់ គឺជាការជ្រមុជ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមឲ្យបងប្អូនបានក្លាយជាឧបករណ៍របស់ព្រះសំរាប់បំរើព្រះអង្គតាមការត្រាស់ហៅដែលព្រះទ្រង់សព្វព្រះហឫទ័យ ដើម្បីដំណឹងល្អដល់ប្រជាជនកម្ពុជា រាប់លាននាក់ដែលរង់ចាំក្តីសង្ឃឹមពីទីងងឹត ។

HONEYCOMB 3/1 (January 2002): 12–17



# The Calling and Great Obligation of Church Leaders

*Rev. HENG Cheng*

The Cambodian Church went through so much suffering that it nearly perished in the hopeless Dark Age of years past. But God has a compassionate love for Cambodians, and rekindled his church as promised in his word. For nearly two decades now his church has been growing steadily year by year, even though there are some difficulties and not enough resources. At this point the church is growing everywhere throughout the country; the Kingdom of God keeps advancing. God is at work although this nation was in a Dark Age until recently.

God needs more leaders to develop the church—to make it stronger and more sustainable. The Holy Spirit spoke through Paul: "From Paul, a servant of Christ Jesus and an apostle chosen and called by God to preach his Good News."[1] This verse shows God's call of Paul to do his work—the great mission God wants his church and his sacred people to undertake. We need an attentive ear to hear his special call in order to respond to the great need the church faces these days. How can a person step in to serve God in church leadership?

---

[1]Rom 1:1.

## God's Call

A divine call is essential for a person to truly be God's servant. According to John 10:1, there is a proper gate that leads into the sheep pen, as well as inappropriate ways to enter. Similarly, there are individuals who jump into the work of leadership with their own plans and agendas. Some see Christian service chiefly as an opportunity to earn a living. Others come seeking the title and status of great leaders. In short, this kind of servant has not entered the sheep pen the proper way—through the gate. This kind of motive stems only from ambition and feeling. A person so motivated does not look up to God.[2]

Therefore I strongly believe that anyone who steps into a leadership role to minister the Good News of Christ should know clearly that God has called him or her to the task. The voice of calling from the Holy Spirit vibrates in our spirits and compels us to serve in his great task.[3] This calling becomes an imperative that we cannot avoid.

God calls different people in different ways, though a common thread runs through this variety. He does not first force us into a common mold before he summons us to serve, but respects both our individual station in life and our common sense. This common sense leads us to open our hearts to accept his call.

The Bible gives examples of different methods by which God has called. Moses was a shepherd tending sheep in Midian. As he followed the flocks he doubtless recalled the suffering of his fellow Israelites and the injustice practiced against them as described years later in Isaiah 59:14—"So justice is driven back, and righteousness stands at a distance; truth has stumbled in the streets, honesty cannot enter." This was the situation from which God called Moses, and he was compelled to follow.

Isaiah's experience was different. Isaiah may have been a friend of several of Judah's kings, particularly Hezekiah. His rich vocabulary and imagery suggests that he was well educated, and he may have spent time in the palace and lived in a pleasant environment,

---

[2]Ps 121:1–2.

[3]1 Cor 9:16.

unlike the desert that was Moses' home. Isaiah's call came "in the year that king Uzziah died."[4] Because Uzziah was clever, the country had prospered under his reign, and the people placed their hope in him. But now at Uzziah's death their hope was falling apart. It looked like their strong trust and hope was going to collapse. The country possibly faced breakdown and turmoil. When Uzziah's throne was vacated because of his death, Isaiah saw the Lord seated on that throne. These events showed Isaiah that this world will end some day because it exists in time, but the foundation of God's reign will last forever and never change. "In the year that King Uzziah died, I saw the Lord seated on a throne, high and exalted," and "heard the voice of the Lord saying, 'Whom shall I send? And who will go for us?'"[5] The voice of the Lord touched Isaiah's heart and made him serve the Lord as a prophet. "Here am I. Send me!"

Jeremiah's calling was different still. We are not told the circumstances that surrounded his call, but one day he heard the voice of the Lord saying, "Before I formed you in the womb I knew you, before you were born I set you apart; I appointed you as a prophet to the nations."[6] This was the voice of God's calling. It was real and not a daydream; it was the voice of the Spirit in his heart that he could not reject. Even though he was afraid of the great task he nevertheless accepted the call wholeheartedly.

These are just a few of the various ways God has called his servants. If we examined the Bible further we would find still other instances.

Therefore we cannot say specifically how God may call—whether in this way or that—until we have gone through the experience ourselves. Sometimes his invitation is full of comfort, as in Psalm 32:8, "I will instruct you and teach you in the way you should go; I will counsel you and watch over you." Sometimes it is full of power that we cannot escape or reject. So the call comes in different forms, but with the same purpose of advancing his mission to the world. Paul

---

[4]Isa 6:1.

[5]Isa 6:1, 8.

[6]Jer 1:5.

wrote, "'Everyone who calls on the name of the Lord will be saved.' How, then, can they call on the one they have not believed in? And how can they believe in the one of whom they have not heard? And how can they hear without someone preaching to them? And how can they preach unless they are sent? As it is written, 'How beautiful are the feet of those who bring good news!'"[7]

Concentrating on the call by which God entrusts his task to us is an excellent thing for us to do as leaders in God's work.

## A Great Task

Those who accept the Lord's mission when he calls will understand the glory of God. God graciously invites us to be his coheirs, and we are commissioned to share his offer with others who have not yet heard the Good News. Thinking about the call and grace of God will inspire us to fear the Lord and advance his kingdom.

This fear of the Lord dominated Paul's life. After receiving salvation, Paul was surprised at God's call to him. God commanded that Paul proclaim his grace. ". . . [T]his grace was given me: to preach to the Gentiles the unsearchable riches of Christ."[8] God's call shone brightly in Paul's mind and moved him to fear the Lord and continue working in times of trial. God manifested special grace to Paul as described in Ephesians 3:2—"Surely you have heard about the administration of God's grace that was given to me for you." He told Timothy, "I was appointed a herald and an apostle—I am telling the truth, I am not lying—and a teacher of the true faith to the Gentiles."[9] When we know for sure that God has called us, and recognize the greatness of his task, we cannot neglect our duty. God has commissioned us to point the way—to serve as soul physicians for the people whom God has entrusted to us. We should show them the way to the true faith and the abundant life in Christ. We should pay attention to the duty God has given us. We have to take it seriously and search how people should live in present society in order to deliver them from the slavery

---

[7]Rom 10:13–15.
[8]Eph 3:8.
[9]1 Tim 2:7.

of sin. We must be persons who bring to Christ his pure bride—who do not seek their own glory.

### A Living Sacrifice

The Lord Jesus Christ left his glorious throne in heaven to become man and live among us in this sinful world[10] by becoming a son of a simple carpenter. Let us consider the tools of a carpenter and what they can teach us. Each carpenter owns many kinds of tools he uses to carve wood. He has both specialized and common, simple tools. Which kind do we want to become for God to use? 2 Timothy 2:20–21 teaches, "In a large house there are articles not only of gold and silver, but also of wood and clay; some are for noble purposes and some for ignoble. If a man cleanses himself from the latter, he will be an instrument for noble purposes, made holy, useful to the Master and prepared to do any good work."

How can we become a good tool for the Lord? There is only one way—namely to offer our lives to him as a living sacrifice and spare nothing for our own benefit. We should not rely on our own experiences or knowledge derived from any particular book or school. There is only one ultimate training institute, and it is not from the hand of man. If we want to serve God effectively we have to enroll in his school of testing, and our teachers will be the obstacles we personally go through. Who can graduate out of this kind of school? The one who learns endurance through suffering. More trials improve the servant of the Lord. Paul said, "We rejoice in our sufferings."[11] Please be reminded of the carpenter's tools again. The tools that the carpenter relies upon for his most important projects, or to use on the toughest and longest-lasting woods, are those that are his best. We sometimes casually boast of our capacity to serve the Lord, but it is when we actually enter the real battle that we (and others) will learn whether or not God considers us his trustworthy plane or chisel that can go through hard wood. Am I a plane or chisel blade that has been suffi-

---

[10]John 1:14.

[11]Rom 5:1–5; 1 Pet 4:12–13; Jas 1:2–3.

ciently tempered to work tough wood, or am I too soft to be of much use?

Dwight L. Moody dedicated his life to God's work. He became a valuable tool in God's hands, even though he was born in a poor family in Northfield, Massachusetts, U.S.A., in 1837. He became a hero in praising God though his faith in Jesus Christ. The Lord used him greatly throughout his life.

1. He offered his life as a living sacrifice without withholding anything for himself.
2. He was a man of prayer who wholeheartedly trusted God.
3. He learned and followed the words of God.
4. He was patient, enduring, and gentle.
5. He was free from greed.
6. He burned with compassion for the lost.
7. He was baptized in the Holy Spirit from the Most High.

May my brothers and sisters become tools that God uses as he wills to bring good news to millions in Cambodia waiting in darkness for lives with hope.

HONEYCOMB 3/1 (January 2002): 18–22



# On Respecting Beliefs and People

*Russell H. BOWERS, Jr.*

A letter to the editor of the *Cambodia Daily* published on February 18, 1999, pondered how Christians should relate to other religions. The *Daily* entitled that letter, "Good Christians Respect Beliefs of Others."

But is that true? Do Christians respect *beliefs*, or do we rather respect *the people who hold them*? Should we not distinguish between these two?

Without question Christians should respect *people*. James warns us not to curse our fellow humans, each of whom is made in God's likeness.[1] Jesus welcomed all kinds of people to hear him—rich and poor, educated and ignorant, powerful and weak. To him they were equally *people*; their social and economic status mattered little compared with that. Jesus did not try to attract attention to himself by denouncing others. He did denounce when necessary, of course, but this was not his preferred or characteristic style. Rather, as Isaiah foretold Jesus generally exercised a quiet ministry of good words and good deeds:

---

[1]Jas 3:9–10.

*Here is my servant whom I have chosen,*
*the one I love, in whom I delight;*
*I will put my Spirit on him,*
*and he will proclaim justice to the nations.*
*He will not quarrel or cry out;*
*no one will hear his voice in the streets.*
*A bruised reed he will not break,*
*and a smoldering wick he will not snuff out,*
*till he leads justice to victory.*
*In his name the nations will put their hope.*

Peter instructs that even when we are in the midst of defending our faith we should present our answers "with gentleness and respect."[2] So obviously Christians should respect *people.*

But what about *beliefs*? The English word "respect" means both "to consider worthy of high regard (often after careful assessment)," and "to refrain from interfering with." All who value democracy and the rule of law "respect" religions other than one's own (assuming they do not advocate violence or other crimes) in the sense that they "restrain from interfering with" them—that is, they allow them to be practiced, and they defend their right to exist. In his parable in Matthew 13 Jesus instructed his servants not to uproot tares, but to permit them to grow to the end of the age. So we "respect" different religious beliefs in the sense that we acknowledge their right to exist.[3] But that does not mean we "respect" them in the sense that we consider what they teach "worthy of high regard." Nor does it mean we do not labor to dissuade people from believing them.

As unpopular as it is in postmodern society, some ideas, beliefs, practices, and religions are just plain *wrong.* They are therefore unworthy of high regard and perpetuation.

George Washington led America's war for independence and was its first president. He refused high honors for himself, feared

---

[2]1 Pet 3:15–16.

[3]There are, of course, some beliefs and practices that governments must suppress. Shouting "Fire!" in a crowded theater is one. That is a separate issue that the present article will not address.

God, and served his country well. In his sixty-seventh year he fell ill. His physicians agreed he had "bad blood" that must be drained from his body. Four times they drained it—and as a result Washington died. Standard eighteenth-century medical wisdom was wrong and killed the man. If I were a physician attending a patient today I would not "respect" a treatment plan that advocated such bloodletting. The only responsible course of action would be to argue against it, demonstrate its errors, and urge a sounder treatment. To do less would be to shirk my duty.

There are many beliefs that I do not "respect": the anti-Semitism of Adolph Hitler; the hedonism of Hugh Hefner; the genocidal mania of Pol Pot; the nihilism of the Columbine High School murderers; the callousness of those who crash airliners into skyscrapers. These and other philosophies are objectively and horrendously *wrong*, and I do not respect them.

The same holds in religion. Christians are not those who have simply taken a Kierkegaardian leap into the void and decided, out of all the religions and philosophies out there, to mindlessly opt for Christianity. Rather, we believe that biblical Christianity is *objectively true*, that Jesus of Nazareth is *in fact* uniquely the Son of God, and that his death and resurrection provide the only way to forgiveness and eternal life. That is what being a Christian means. By implication other "ways" are wrong. They may be popular and practiced by millions, but in the end turn out to be spiritual bloodletting.

So while we recognize that many people do not believe these truths and consequently follow other ideologies, and while we both respect them as people and do not forcibly deny their right to hold to different faiths, we need not "respect" the beliefs themselves. In many cases, to do so would be to abandon the faith we ourselves claim.

If we wish to be biblical, there may be times when we decry error. The same Jesus who welcomed all people excoriated the hypocrisy of the Pharisees in Matthew 23. Elijah mocked the prophets of Baal.[4] The Psalmist berated the folly of the atheist.[5] Paul called

---

[4]1 Ki 18:27.

[5]Ps 14:53.

Elymas a "child of the devil and an enemy of everything that is right"[6] (not exactly a cordial or "respectful" statement). In these cases, those who espoused error had so consciously and culpably identified themselves with it that they as persons were virtually indistinguishable from their beliefs, and so themselves had to be opposed. He told the Athenians that their religion was wrong, and urged repentance from such "ignorance."[7] Good Christians do not smile benignly at theological error that will thrust its adherents to eternal doom, just as good physicians do not accede to bloodletting plans when medication is required. As Stott once observed, to be "intellectually tolerant of opinions we know to be false" is "unprincipled indulgence."[8]

Two caveats for Christians. First, we should recognize that rejection of a person's religious (or medical) beliefs does not require us to reject all else he is and does. Much in non-Christian culture is beautiful and worth celebrating. As has been said, "we can trust and respect, even have as a friend who can be relied on, a member of the Flat Earth Society, even though we know that his cosmological views are less than accurate."[9] There are many warm, moral, community-minded Buddhists, Muslims, Hindus, and other non-Christians. Rejection of their faith implies neither rejection of them as persons, nor out-of-hand dismissal of their other beliefs.

Second, Christians have sometimes assumed they have all the truth while the non-Christian world has none. That is wrong. Acting on this presumption may cause us to repeat the embarrassing error of Abraham, the believer and friend of God, who lied to Abimelech about Sarah because he thought, "There is surely no fear of God in this place."[10] But Abimelech was the one who heard from God, and this

---

[6]Acts 13:10.

[7]Acts 17:29–30.

[8]John Stott, *Involvement: Being a Responsible Christian in a Non-Christian Society,* vol. 1 (Old Tappan, New Jersey: Revell, 1985), 78.

[9]Paul Griffiths and Delmas Lewis, "On Grading Religions, Seeking Truth, and Being Nice to People—A Reply to Professor Hick," *Religious Studies* 19 (1983): 79.

[10]Gen 20:11.

pagan king then turned and rebuked God's deaf prophet. Likewise godly King Josiah "would not listen to what Neco [king of Egypt] had said at God's command,"[11] and so rode to his death on the plain of Megiddo. Christians need to learn what Paul argued to the Jews in Romans 2—that those who *profess* correct propositional truth may *act* less righteously than those without it, and may in the end prove less acceptable to God. Having heard and believed the great things that God has done through Christ does not justify the Christian in being proud of having heard and believed.

So do we "respect" the beliefs of others? Not necessarily. We respect the people who hold them, and endorse their right to do so. They are our co-workers, our neighbors, our fellow-citizens, our friends. We should invite them into our homes and visit freely in theirs. We can enjoy socializing and working with them on many levels. But if we love them, we will at times earnestly share the Christ who can save them, urging that they abandon the false doctrines they may sincerely believe.

---

[11]2 Chron 35:22.

សំណុំនិកាយ ៣/១ (មករា ២០០២): ២៣-៣១



# ការគោរពជំនឿ និង មនុស្ស

*លោក រ៉ាស់សែល បាវឌើស៍*

មានសំបុត្រមួយច្បាប់ ដែលគេសរសេរផ្ញើទៅកាន់ទីស្នាក់ការសារព័ត៌មាន **Cambodia Daily** កាលពីប៉ុន្មានខែមុន ដែលមានពិចារណាថាតើគ្រីស្តបរិស័ទគួរទាក់ទងឲ្យបានប្រសើរយ៉ាងដូចម្តេចទៅ ចំពោះសាសនាដទៃនោះ ។ សារព័ត៌មាននោះបានដាក់ចំណងជើងលើសំបុត្រនោះថា "គ្រីស្តបរិស័ទដ៏ល្អ គឺចេះគោរពដល់ជំនឿរបស់អ្នកដទៃ ។"

ប៉ុន្តែតើរឿងនោះពិតដែរឬទេ? តើគ្រីស្តបរិស័ទគោរពដល់ជំនឿទាំងឡាយនោះ ឬ គោរពដល់មនុស្ស ដែលបានកាន់តាមជំនឿនោះ? តើយើងមិនគួរកំណត់ឲ្យបាននូវភាពខុសគ្នាទាំងពីរនោះទេឬអី?

ដោយមិនបានផ្តល់សង្ស័យអ្វីឡើយ គ្រីស្តបរិស័ទត្រូវតែចេះគោរពដល់មនុស្សរួចស្រាប់ទៅហើយ ។ លោក យ៉ាកុប បានព្រមានយើងមិនឲ្យដាក់បណ្តាសាដល់មនុស្សដូចគ្នា ដោយព្រោះយើងម្នាក់ៗត្រូវបានព្រះបង្កើតមកជារូបឆ្លុះ ឬតំណាងរបស់ព្រះជាម្ចាស់[១] ។ ព្រះយេស៊ូ

[១] *យ៉ាកុប ៣:៩-១០*

បានស្វាគមន៍ មនុស្សគ្រប់ប្រភេទទាំងអស់ ដែលមកស្តាប់ដល់ព្រះអង្គ គឺមិនថាអ្នកមាន ឬ អ្នកក្រ, អ្នកប្រាជ្ញ ឬ អ្នកល្ងង់ខ្លៅ, អ្នកមានអំណាច ឬ អ្នកទន់ខ្សោយឡើយ ។ ចំពោះព្រះអង្គ មនុស្សទាំងអស់គឺមានតម្លៃស្មើៗគ្នា ឋានៈ និង ជីវភាពធូរធារ ឬ ខ្សត់ខ្សោយ មិនចាំបាច់អ្វីឡើយក្នុងការប្រៀបធៀបនោះ។ ព្រះយេស៊ូមិនបានព្យាយាមទាក់ទាញចិត្តមនុស្សទាំងឡាយ ឲ្យមកយកចិត្តទុកដាក់លើព្រះអង្គផ្ទាល់ ដោយសារតែព្រះអង្គផ្តន្ទាទោសដល់អ្នកដទៃនោះឡើយ ។ តាមពិតទៅព្រះអង្គបានផ្តន្ទាទោសមែន នៅពេលដែលចាំបាច់ ប៉ុន្តែមិនមែនជាការដែលព្រះគាប់ព្រះហឫទ័យចង់ធ្វើបែបនោះ ឬក៏ជាលក្ខណៈនៃវិធីសាស្ត្រដែលព្រះអង្គត្រូវធ្វើនោះឡើយ ។ តែផ្ទុយទៅវិញ ដូចដែលព្យាការី អេសាយ បានទាយពីព្រះយេស៊ូ ដែលជាទូទៅព័ន្ធកិច្ចរបស់ព្រះយេស៊ូ គឺជាព័ន្ធកិច្ចដ៏ស្ងប់ស្ងាត់មួយនៃពាក្យសំដីល្អ និង អំពើល្អគឺ:

*លោកនេះហើយ ជាអ្នកបំរើ ដែលយើងគាំទ្រ ជាអ្នកដែលយើងបានជ្រើសរើស និង ជាទីគាប់ចិត្តរបស់យើង ។ យើងដាក់វិញ្ញាណរបស់យើងលើលោក ។ លោកនឹងបង្ហាញឲ្យប្រជាជាតិទាំងឡាយស្គាល់ការវិនិច្ឆ័យ ។ លោកមិនស្រែក ឬ គំហកកំហែងដាក់នរណាឡើយ ហើយក៏មិនបន្លឺសម្លេងនៅតាមផ្លូវដែរ ។ លោកនឹងមិនកាត់ផ្តាច់ដើមត្រែងណា ដែលទក់ហើយនោះទេ ហើយលោកក៏មិនពន្លត់ភ្លើង ដែលហៀបនឹងរលត់នោះដែរ លោកនឹងនាំមកនូវការវិនិច្ឆ័យពិតមែន! លោកនឹងមិនទន់ខ្សោយឡើយ លោកអង់អាចជានិច្ចរហូតទាល់តែធ្វើឲ្យមានការវិនិច្ឆ័យនៅលើផែនដី ហើយមនុស្សនៅតាមកោះនានានាំគ្នារង់ចាំទទួលវិន័យពីលោក ។*

លោក ពេត្រុស បង្រៀនថា សូម្បីតែនៅពេលដែលយើងស្ថិតនៅក្នុងស្ថានភាពនៃការប្រឆាំងតវ៉ា ដើម្បីការពារជំនឿរបស់យើងក៏ដោយ យើង

ត្រូវបង្ហាញនូវចម្លើយរបស់យើង "ដោយសុភាព និង ដោយការគោរព ។"[២] ដូច្នេះជាការប្រាកដជាក់ច្បាស់ទៅហើយ ដែលគ្រីស្ទបរិស័ទត្រូវគោរពដល់មនុស្សដទៃទៀត[៣] ។

ប៉ុន្តែចុះពីរឿងជំនឿនោះយ៉ាងដូចម្តេចដែរ? នៅក្នុងភាសាអង់គ្លេសពាក្យ ថា respect ខ្មែរប្រែថា "គោរព" នោះគឺមានន័យថា ការគិតពិចារណានៃការរាប់អានឲ្យតម្លៃយ៉ាងខ្ពង់ខ្ពស់ (ដែលជារឿយៗបន្ទាប់ពីការប៉ាន់ប្រមាណដោយប្រុងប្រយ័ត្ន) ហើយមានន័យទៀតថា "មិនទៅរំខានយាយីអ្វីឡើយ" ។ ចំពោះមនុស្សទាំងឡាយណា ដែលឲ្យតម្លៃលើលទ្ធិ ប្រជាធិបតេយ្យ និង លើក្បួនច្បាប់ "គោរព" ដល់សាសនាដទៃលើសអ្វីដែលជារបស់ខ្លួនឯងទៅទៀត (គឺសន្មត់ថា គេមិនគាំទ្រលើអំពើហឹង្សា ឬ អំពើឧក្រិដ្ឋផ្សេងៗឡើយ គឺមានន័យថា ពួកគេ "មិនទៅជាប់ពាក់ព័ន្ធជាមួយ" អំពើអស់ទាំងនេះ គឺថាអនុញ្ញាតឲ្យគេកាន់តាមជំនឿរបស់គេ និង ការពារសិទ្ធិរស់នៅរបស់គេ ។ នៅក្នុងរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូនៅក្នុងម៉ាថាយ ១៣ ព្រះអង្គបានបង្រៀនដល់អ្នកបំរើរបស់ព្រះអង្គ មិនឲ្យដកស្រងែចេញ ប៉ុន្តែចូរទុកឲ្យវាដុះគ្រាចុងក្រោយ ។ ដូច្នេះយើង "គោរព" រាប់អានដល់ជំនឿនៃសាសនាផ្សេងៗ ក្នុងន័យថា យើងទទួលស្គាល់សិទ្ធិរបស់គេ ក្នុងការកាន់ជំនឿសាសនានោះ[៣] ។ ប៉ុន្តែការនោះមិនមែនមានន័យថា យើង "គោរព" ដល់គេក្នុងន័យថា យើងគិតថា អ្វីដែលគេបង្រៀននោះ "ត្រឹមត្រូវគួរឲ្យទទួលយក" បាននោះឡើយ ឬក៏មិន

---

*[២]១ ពេត្រុស ៣:១៥-១៦*

*[៣]ជាការពិតណាស់ មានជំនឿ និងការអនុវត្តន៍ខ្លះ ដែលរដ្ឋាភិបាលត្រូវហាមឃាត់ៗ ចំពោះការស្រែកថា "ភ្លើងឆេះហើយ!" ទៅចំណោមមនុស្សអ៊ូអរនៅក្នុងរោងល្ខោនមួយដែរៗ នោះគឺជារឿងមួយផ្សេងដែលមិនបានលើកមកនិយាយទេៗ*

មែនមានន័យថា ខិបដៃមើលមិនធ្វើអ្វីសោះ បណ្តោយឲ្យមនុស្សទៅជឿលើការអះអាងរបស់គេនោះដែរ ។

ដូចកាលក្នុងសង្គមមនុស្សមុនពេលចូលយុគសម័យទំនើប ដែលមិនសូវមានគេនិយមច្រើនប៉ុន្មាននោះ មានការយល់ឃើញខ្លះ ជំនឿទំនៀមទម្លាប់ និង សាសនាខ្លះៗ នោះគឺខុសឆ្គងទាំងស្រុងតែម្តង ។ ហេតុដូច្នេះហើយ ទើបសាសនា និង ទំនៀមទម្លាប់ទាំងនោះគ្មានតម្លៃគ្រប់គ្រាន់ឲ្យមានមនុស្សគោរពរាប់អាន និង កាន់តាមបានយូរអង្វែង ។

លោក ជច វ៉ាស៊ីនតោន បានដឹកនាំសង្គ្រាមរបស់អាមេរិកកាំងដើម្បីទាមទារឯករាជ្យ និង ក៏ជាប្រធានាធិបតីទីមួយរបស់ប្រទេសអាមេរិក។ គាត់បានបដិសេធចំពោះការទទួលកិត្តិយសខ្ពង់ខ្ពស់សម្រាប់ខ្លួនឯង គាត់ជាមនុស្សដែលកោតខ្លាចព្រះជាម្ចាស់ និង បំរើប្រទេសរបស់គាត់បានយ៉ាងល្អប្រសើរ ។ នៅពេលដែលគាត់មានអាយុ ៦៧ ឆ្នាំ គាត់ធ្លាក់ខ្លួនឈឺ ។ គ្រូពេទ្យរបស់គាត់យល់ស្របថាគាត់មាន "ឈាមមិនល្អ" ទើបបណ្តាលឲ្យគាត់ឈឺ ដូច្នេះគេត្រូវតែបង្ហូរឈាមឲ្យចេញពីខ្លួនរបស់គាត់ ។ ពួកវេជ្ជបណ្ឌិតបានបង្ហូរឈាមរបស់គាត់ ៤ដង ដោយហេតុនោះទើប លោក វ៉ាស៊ីនតោនខ្សោះឈាមស្លាប់ ។ គតិបណ្ឌិតផ្នែកវេជ្ជសាស្ត្រសម័យសតវត្សទី ១៨ នោះមិនត្រឹមត្រូវឡើយ ទើបបានជាធ្វើឲ្យគាត់ស្លាប់ ។ បើសិនជាវេជ្ជបណ្ឌិតសម័យឥឡូវនេះ ខ្ញុំមិនព្រម "គោរពតាម" ឬជឿតាមការព្យាបាលតាមបែបបង្ហូរឈាមនោះឡើយ ។ ការងារដ៏ត្រឹមត្រូវចំពោះខ្ញុំដែលខ្ញុំត្រូវធ្វើនោះ គឺត្រូវប្រឆាំងនឹងការព្យាបាលបែបនេះ បង្ហាញឲ្យគេដឹងថាការធ្វើបែបនោះខុសឆ្គងទេ និង ជំរុញលើកទឹកចិត្តឲ្យគេប្រើរបៀបព្យាបាលមួយដែលល្អជាងនេះ ។ ការធ្វើមិនដឹង មិនឮ នោះគឺជាការសម្ងំយកសុខតែម្នាក់ឯង ។

មានជំនឿជាច្រើន ដែលខ្ញុំមិន "គោរពតាម" គឺ: គោលនយោបាយ

សង្គមជាតិនិយម និង គោលគំនិតស្អប់ដល់សាសនាយូដារបស់លោក អាឌុល អ៊ីត្លែរ ទស្សនវិជ្ជានៃការរស់នៅយ៉ាងសប្បាយបែបសម្ភារៈនិយមរបស់ ហាក់ ហែហ្វនឹរ ទស្សនៈនៃការប្រល័យពូជសាសន៍របស់ ចូសែហ្វ ស្តាលីន, សាដាម ហ៊ូសេន និង ប៉ុល ពត ការសម្លាប់សិស្សសាលាយ៉ាងវង្វាលនៅកូឡុមប៊ី ពួកអ្នកដែលគ្មានចិត្តមេត្តាប្រហារជីវិតមនុស្ស បើកយន្តហោះបុកអាគារខ្ពស់ៗ ។ ជំនឿ និង ទស្សនវិជ្ជាទាំងនេះ គឺពិតជាខុសឆ្គង និងគួរឲ្យព្រឺព្រួចមែនទែន ហើយខ្ញុំក៏មិនគោរពតាមជំនឿ និងទស្សនវិជ្ជាបែបនោះឡើយ ។

ការកាន់សាសនា ក៏បែបដូចគ្នានេះដែរ ។ គ្រីស្តបរិស័ទមិនមែនជាអ្នកដែលគ្រាន់តែសម្រេចចិត្តជឿសាសនាទាំងអស់ និង ទស្សនវិជ្ជាទាំងឡាយ ដែលជ្រើសរើសយកជំនឿគ្រីស្តបរិស័ទ ដោយមិនបានគិតរកទិសដៅច្បាស់លាស់នោះឡើយ ។ តែយើងជឿថា ជំនឿគ្រីស្តបរិស័ទតាមព្រះគម្ពីរនោះ គឺពិតជាត្រឹមត្រូវ ព្រោះថា ព្រះយេស៊ូ អ្នកស្រុក ណាសារ៉ែត គឺពិតជាព្រះរាជបុត្រាតែមួយរបស់ព្រះមែន ហើយជឿថាការសុគត និងការរស់ឡើងវិញរបស់ព្រះអង្គ គឺជាផ្លូវតែមួយគត់ដែលអាចអត់ទោសបាប និង ផ្តល់ជីវិតអស់កល្បជានិច្ចបាន ។ ការធ្វើជាគ្រីស្តបរិស័ទគឺមានន័យដូច្នេះឯង ។ តាមរយៈការអនុវត្តន៍ដោយជ្រើសរើស "រកផ្លូវផ្សេងៗទៀតនោះ" មិនត្រឹមត្រូវទេ ។ ប្រហែលជាជំនឿទាំងនោះមានគេនិយមច្រើនដល់ទៅរាប់លានឯណោះ ប៉ុន្តែនៅក្នុងពេលចុងបញ្ចប់បានបង្ហាញឲ្យឃើញថា ធ្វើឲ្យខ្សោះជីវិតខាងវិញ្ញាណទៅវិញ ។

ដូច្នេះនៅក្នុងខណៈដែលយើងទទួលស្គាល់ថា មនុស្សជាច្រើនមិនជឿលើសេចក្តីពិតទាំងនេះទេ និង ដែលជាហេតុនាំឲ្យគេជឿលើមនោគមវិជ្ជាផ្សេងៗ ហើយនៅក្នុងខណៈដែលយើងគោរពរាប់អានគេ ជា មនុស្ស និង មិនបង្ខំឲ្យគេបដិសេធនូវសិទ្ធិរបស់គេ ក្នុងការកាន់តាមជំនឿផ្សេងៗ

យើងមិនចាំបាច់ "គោរព" តាមជំនឿនោះដោយផ្ទាល់ខ្លួនយើងឡើយ ។ ក្នុងករណីជាច្រើន ដើម្បីធ្វើរបៀបនោះបានប្រហែលជាយើងត្រូវបោះបង់ចោលជំនឿរបស់យើង ដែលកំពុងតែប្រកាសប្រាប់ដល់គេនោះផងក៏មិនដឹង ។

បើសិនជាយើងប្រាថ្នាធ្វើតាមគំរូនៃព្រះគម្ពីរនោះ យើងត្រូវតែហ៊ាននិយាយប្រឆាំងយ៉ាងខ្លាំងក្លាទាស់នឹងជំនឿខុសឆ្គង ។ ដូចគ្នានេះដែរ ព្រះយេស៊ូស្វាគមន៍មនុស្សទាំងអស់ រហូតដល់ពួកមនុស្សពុតត្បុតដូចជាពួកផារីស៊ី នៅក្នុងកណ្ឌគម្ពីរម៉ាថាយ ២៣ ។ លោកអេលីយ៉ា បានចំអកដល់ពួកហោរានៃព្រះបាល[4] ។ អ្នកនិពន្ធទំនុកតម្កើងបានស្តីបន្ទោសដល់ពួកល្ងីល្ងើ ដែលមិនជឿថា មានព្រះសោះ[5] ។ លោក ប៉ូល បានហៅ អេលីម៉ាស់ ថាជា "កូននៃអារក្សសាតាំង និង ជាខ្មាំងសត្រូវនៃរបស់គ្រប់យ៉ាងដែលត្រឹមត្រូវ"[6] (មិនមែនជាពាក្យគួរសម ឬ ពាក្យសម្តែង "ពីការគោរពនោះឡើយ") ។ នៅក្នុងករណីទាំងនេះ ចំពោះអស់អ្នកដែលគាំទ្រដល់គំនិតខុសឆ្គងដោយស្មោះត្រង់អស់ពីចិត្ត និង បង្ហាញយ៉ាងច្បាស់ថា គេពិតជាយល់ស្របទាំងស្រុងលើជំនឿដែលគេជឿនោះ មនុស្សបែបនោះគឺ ពិបាកក្នុងការញែកគេដាច់ចេញពីជំនឿរបស់គេណាស់ ហើយ យើងត្រូវតែប្រឆាំងដាច់ខាត ។ លោក ប៉ូល បានប្រាប់ដល់អ្នកក្រុង អាថែន ថា សាសនារបស់គេនោះមិនត្រឹមត្រូវឡើយ និង ជំរុញឲ្យមានការប្រែចិត្ត ចេញពី"ការល្ងិតល្ងង់"បែបហ្នឹង[7] ។ គ្រីស្តបរិស័ទដ៏ល្អនោះមិនញញឹមយ៉ាងសុភាពដាក់ការខុសឆ្គងផ្នែកទេវសាស្ត្រ ដែលនឹងនាំឲ្យមានបញ្ហាធ្ងន់ធ្ងរនៅថ្ងៃខាងមុខ គឺដូចជាវេជ្ជបណ្ឌិតដ៏ល្អ មិនយល់

---

[4] ១ ពង្សាវ. ១៨:២៧

[5] ទំនុក. ១៤:៥៣

[6] កិច្ចការ ១៣:១០

[7] កិច្ចការ ១៧:២៩-៣០

ស្របតាមការព្យាបាលដោយកាត់បង្ហូរឈាមនោះសោះឡើយ គឺត្រូវការប្រើថ្នាំវិញ ។ ដូចដែលលោក ស្តុត បានសង្កេតឃើញថា ដើម្បីសម្របយ៉ាងវៃឆ្លាតទៅនឹងគំនិតផ្សេងៗ ដែលយើងដឹងថាខុសឆ្គងនោះ គឺជា "ទម្លាប់មួយដែលគ្មានគោលការណ៍ច្បាស់លាស់ល្អនោះឡើយ"[៨] ។

មានបម្រាមពីរយ៉ាងសម្រាប់គ្រីស្ទបរិស័ទ ។ ទីមួយ យើងត្រូវទទួលស្គាល់ថា ការបដិសេធមិនទទួលជំនឿសាសនា (ឬរបៀបព្យាបាល) របស់អ្នកណាម្នាក់ គឺមិនចាំបាច់អីឲ្យយើងបដិសេធចោលនូវអ្វីៗទាំងអស់ និងការប្រព្រឹត្តិទាំងឡាយរបស់បុគ្គលនោះឡើយ ។ មានការល្អយ៉ាងច្រើននៅក្នុងពួកអ្នកមិនជឿ និង ក្នុងទំនៀមទម្លាប់របស់គេ ហើយនិងមានតម្លៃសមនឹងទទួលនូវការអបអរទៀតផង ។ ដូចបានជំរាបជូនរួចហើយថា យើងអាចទុកចិត្ត និង ទទួលការគោរពរាប់អាន សូម្បីតែរាប់ទុកជាមិត្តសម្លាញ់ដែលអាចពឹងពាក់បាន សូម្បីតែសមាជិកនៃក្រុមទស្សនវិជ្ជាដែលជឿថា ផែនដីសំប៉ែត ក៏យើងត្រូវរាប់អានគេដែរ ទោះបីជាយើងដឹងថាទស្សនៈផ្នែកផែនភពនៃចក្រវាឡរបស់គេមិនសូវត្រឹមត្រូវក៏ដោយ[៩] ។ មានពុទ្ធសាសនិក ពួកមូស្លីម ពួកហិណ្ឌូ និង អ្នកមិនជឿព្រះយេស៊ូជាច្រើនដែលមានគំនិតស្មារសហាគមន៍ មានសីលធម៌ខ្ពស់ គួរជាទីរាប់អានយ៉ាងកក់ក្តៅទៀតផង ។ ការបដិសេធន៍មិនព្រមទទួលជំនឿរបស់គេនោះ គឺមិនមែនបានសេចក្តីថា យើងបដិសេធគេចោលក្នុងឋានៈគេជាមនុស្សដូចយើង ឬក៏ប្រាានចោលអស់នូវជំនឿដទៃរបស់គេនោះឡើយ ។

---

[៨]*លោក ចន ស្តុត*, *Involvement: Being a Responsible Christian in a Non-Christian Society,* vol. 1 (Old Tappan, New Jersey: Revell, 1985), 78.

[៩]*លោក ប៉ូល ហ្គ្រីហ្វីត និង ដែលម៉ាស ឡឺវីស*, "On Grading Religions, Seeking Truth, and Being Nice to People-A Reply to Professor Hick," *Religious Studies* 19 (1983): 79.

មានមនុស្សជាច្រើននៅក្នុងលោកយើងសព្វថ្ងៃនេះស្ថិតនៅក្នុងការឈឺចាប់យ៉ាងខ្លាំងសម្បើម ជារឿយៗបណ្ដាលមកពីសកម្មភាពរបស់មនុស្សដទៃ ។ អ្នកដែលគ្មានអំណាចតែងតែទទួលរងឈឺចាប់ក្រោមដៃរបស់អ្នកដទៃទៀត ។ គេប៉ាន់ប្រមាណឃើញថា មានក្មេងអាយុក្រោម៥ឆ្នាំប្រមាណ ១៥ លាននាក់ស្លាប់ជារៀងរាល់ឆ្នាំ ដោយសារតែខ្វះចំណីអាហារ ទឹក និងសេវាថែទាំសុខភាព ហើយចំពោះក្មេងទាំងនោះភាគច្រើន ដែលបានរួចជីវិតពីសេចក្ដីស្លាប់ដូចបានពោលខាងលើត្រូវរងនូវការកេងប្រវ័ញ្ចផ្នែកផ្លូវភេទ និងបង្ខំឲ្យធ្វើការធ្ងន់ ។ ចំនួនក្មេងអនាថាដែលគេមិនប្រាប់ឲ្យយើងដឹងនោះ នគរបាលនៅតាមមូលដ្ឋានទាំងនោះប្រើអំណាចរំលោភឬសម្លាប់ ។ មានជនភៀសខ្លួន និងជនសុំសិទ្ធិជ្រកកោនរាប់លាននាក់កំពុងស្ថិតនៅក្រោមស្ថានភាពអមនុស្សធម៌ ។ នៅក្នុងរយៈពេល ១០០ឆ្នាំចុងក្រោយនេះ មានព្រឹត្តិការណ៍ជាច្រើនដែលបង្ហាញឲ្យឃើញភាពអមនុស្សធម៌របស់មនុស្ស ដែលមនុស្សបានធ្វើចំពោះមនុស្ស ។ នៅក្នុង

អំឡុងពេលសង្គ្រាមលោកទាំងពីរលើក មានមនុស្សស្លាប់ប្រហែល ៦០ លាននាក់ ។ មានមនុស្សយ៉ាងច្រើនសន្ធឹក ដែលបានស្លាប់នៅក្រោមកណ្ដាប់ដៃនៃអ្នកដឹកនាំរបស់គេផ្ទាល់នៅក្នុងប្រទេស រុស្ស៊ី កម្ពុជា យូហ្គាន់ដា និងប្រទេសចិន ដូចគ្នាដែរនៅក្នុងបណ្ដាប្រទេសជាច្រើននៅក្នុងអាមេរិកឡាទីន ។

តើមនុស្សត្រូវឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ ដោយរបៀបណា? នៅក្នុងសតវត្សចុងក្រោយនេះ មានការកើតឡើងនៃការយល់ដឹង និងលើកស្ទួយផ្នែកសិទ្ធិមនុស្ស ។ ផ្នត់គំនិតដែលគិតពីសិទ្ធិមនុស្សនោះ មិនមែនជារឿងថ្មីឡើយ ។ គឺមានប្រកាសប្រាប់នៅក្នុងព្រះគម្ពីររាប់ពាន់ឆ្នាំរួចទៅហើយ ។ ការធ្វើបដិវត្តន៍របស់អង់គ្លេស បារាំង និង អាមេរិក ប៉ុនប៉ងដើម្បីការពារភាពថ្លៃថ្នូររបស់មនុស្ស និងការពារមនុស្សមិនឲ្យគេរងនូវការរំលោភសិទ្ធិនៅក្រោមកណ្ដាប់ដៃនៃពួកអ្នកដឹកនាំ និងអ្នកមានអំណាចទាំងឡាយនោះ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីសង្គ្រាមលោកទាំងពីរលើកចប់នៅក្នុងសតវត្សទី ២០ គេបានសម្រេចចិត្តថា ខំធ្វើឲ្យបានសម្រេចថែមទៀតនោះ គឺការពារឲ្យមានសន្តិភាព និងសិទ្ធិមនុស្ស ។ អិកឡានតែន៍ ចេប ដែលជាអ្នកជឿព្រះបានឃើញផ្ទាល់នឹងភ្នែក ចំពោះការរងឈឺចាប់របស់កុមារ នៅក្នុងសង្គ្រាមលោកលើកទី១ និងមានតួនាទីសំខាន់នៅក្នុងសេចក្ដីព្រាងច្បាប់នៅឆ្នាំ ១៩២៤ ស្ដីពីការប្រកាសច្បាប់សិទ្ធិកុមារ ។ សង្គ្រាមលោកលើកទី២ ជាហេតុនាំឲ្យគេបង្កើតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៤៥ និងការប្រកាសចេញច្បាប់អន្តរជាតិនៃច្បាប់សិទ្ធិមនុស្សនៅក្នុងឆ្នាំ ១៩៤៨ ។ ពួកអ្នកគាំទ្រសិទ្ធិមនុស្សមានការអះអាងផ្សេងៗជាច្រើន ។ ទីមួយ ពួកអ្នកគាំទ្រសិទ្ធិមនុស្សដែលមកពីភូមិភាគបស្ចិម មានសាវតាជាអ្នកប្រកាន់ភាពឯកត្តបុគ្គល បានប្រកាសអះអាងពីសិទ្ធិឯកត្តបុគ្គល ដូចជាសិទ្ធិនៃការរស់នៅ

សិទ្ធិសេរីភាពនៃការគិត ការបញ្ចេញយោបល់ មនសិការ និង សាសនា សិទ្ធិនៅក្នុងការចូលរួមក្នុងការបោះឆ្នោតដោយសេរី សិទ្ធិស្មើភាព (សមភាព) សិទ្ធិរក្សាភាពជាឯកជន និងទទួលនូវភាពយុត្តិធម៌នៅចំពោះមុខច្បាប់ និងមានសិទ្ធិនៃការហាមប្រាមចំពោះការធ្វើទារុណកម្ម ទាសភាព និង ការប្រើអំណាចរំលោភបំពាន ។ ពួកអ្នកគាំទ្រដែលមានសាវតាលំអៀងទៅរកបែបអ្នកសង្គមនិយមបានសង្កត់ធ្ងន់លើសិទ្ធិការងារ និងការបង់ប្រាក់ខែត្រឹមត្រូវ សិទ្ធិក្នុងការឈប់សម្រាកកាយ និងសិទ្ធិក្នុងការបង្កើតសហជីព ។ សិទ្ធិផ្សេងទៀតដែលបានអះអាងដោយមនុស្សជាច្រើនទៀត មកពីជំនឿផ្សេងៗ រួមទាំងសិទ្ធិក្នុងការអប់រំ សិទ្ធិក្នុងការទទួលការព្យាបាលត្រឹមត្រូវ និង សិទ្ធិក្នុងសន្តិសុខគ្រប់គ្រាន់នៅក្នុងសង្គម ។

ទោះជាយ៉ាងណាក៏ដោយសន្ទុះនៃចលនាគាំទ្រសិទ្ធិមនុស្សកាលពីប៉ុន្មាន ៥០ ឆ្នាំកន្លងមកនេះ នៅតែមានការទទួលរងនូវការឈឺចាប់ និងការរំលោភសិទ្ធិមនុស្សយ៉ាងសម្បើម និងចំនួនច្រើនធំធេងនៅឡើយ ។ តើអ្វីទៅដែលជាវិធីសាស្ត្ររបស់គ្រីស្ទបរិស័ទ ដើម្បីដោះស្រាយរឿងនេះ? តើការប្រកាសពីសិទ្ធិមនុស្សគឺជាវិធីត្រឹមត្រូវឬទេ? តើយើងយល់ស្របទាំងស្រុងលើអ្វីដែលពួកអ្នកគាំទ្រសិទ្ធិមនុស្សបានប្រកាសឬទេ? តើចលនាគាំទ្រសិទ្ធិមនុស្សជ្រុលហួសពីអ្វីដែលសមរម្យឬ? អត្ថបទនេះនឹងស្វែងរកនូវការបង្ហាញថា តើគ្រីស្ទបរិស័ទគួរចាប់អារម្មណ៍ចំពោះសិទ្ធិមនុស្ស ទោះបីជាយើងត្រូវធ្វើការកែតម្រូវខ្លះៗនោះក៏ដោយ ។ ឧទាហរណ៍ យើងមិនយល់ស្របតាមសិទ្ធិដែលគេបានប្រកាសនោះ ហើយយើងគួរកែតម្រូវតុល្យភាពរវាង *សិទ្ធិមនុស្ស* និង *ការទទួលខុសត្រូវ របស់មនុស្ស* ។ លើសពីនោះទៅទៀត ព្រះគម្ពីរក៏បានបញ្ជាក់ផងដែរ ពីសិទ្ធិរបស់ព្រះជាម្ចាស់ក្នុងការដែលព្រះអង្គគ្រប់គ្រងពីលើយើងនោះ ។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីការគិតរបស់យើងនេះ យើងត្រូវពឹងលើគតិលោក ដែលយកគំរូតាមព្រះគម្ពីរ

ដើម្បីស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងរបស់ពិភពលោកនេះ តាមរយៈសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ។

## គតិលោកតាមបែបព្រះគម្ពីរ

លោកុប្បត្តិជំពូកមួយ និងជំពូកពីរបង្រៀនយើងថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ និងព្រះអង្គគ្រប់គ្រងទាំងអស់ ។ ព្រះអង្គបានបង្កើតបុរសនិងស្រីនៅក្នុងរូបអង្គទ្រង់ ហើយព្រះអង្គបានមានព្រះបន្ទូលមកកាន់ពួកគេតាមរបៀបមួយដែលមានទំនាក់ទំនងដ៏ល្អ ។ ព្រះអង្គបានបង្រៀនដល់ពួកគេតាមបែបមួយជារបៀបបង្គាប់បញ្ជា ។ គឺគេ "ត្រូវបង្កើតកូនពូនជាចៅ ហើយចំរើនឡើងដើម្បីបំពេញផែនដី និងគ្រប់គ្រងលើផែនដីនោះទៀតផង ។ គ្រប់គ្រងលើត្រីសមុទ្រ សត្វស្លាបនៅលើអាកាស ព្រមទាំងសត្វគ្រប់ប្រភេទទាំងអស់ដែលនៅលើដី"[១] ។ ព្រះជាម្ចាស់បានបញ្ជាឲ្យមនុស្សមើលថែសួន ។[២] សេចក្ដីពិតដែលប្រមូលបានពីជំពូកទាំងនេះ គឺមានចំណែកយ៉ាងធំ ដើម្បីបង្រៀនយើងចំពោះបញ្ហានៅចំពោះមុខ ។ ព្រះជាម្ចាស់បានបង្កើតយើងមកឲ្យមានទំនាក់ទំនងបីយ៉ាង ។

១. ទីមួយជាមួយព្រះជាម្ចាស់ ។ ព្រះជាម្ចាស់បង្កើតយើងមកដើម្បីធ្វើការប្រកបទាក់ទងជាមួយព្រះអង្គ ស្រឡាញ់ព្រះអង្គ[៣] ឲ្យស្ដាប់បង្គាប់ព្រះអង្គ ថ្វាយបង្គំព្រះអង្គ ។ល។
២. ព្រះជាម្ចាស់ក៏បង្កើតយើងមក ដើម្បីឲ្យយើងប្រកបទាក់ទងនឹងខ្លួនយើងផ្ទាល់ និងមនុស្សដូចគ្នា ។ យើងត្រូវស្រឡាញ់

---

[១] *លោកុ. ១:២៦*
[២] *លោកុ. ២:១៥*
[៣] *ម៉ាថាយ ២២:៣៧*

មនុស្សលោក ។[៤]

៣. ទំនាក់ទំនងជាមួយធម្មជាតិ ។ តួនាទីរបស់យើងត្រូវបង្កើតកូនពូនជាចៅនៅពេញពាសនៅលើផែនដី គ្រប់គ្រងផែនដី សប្បាយរីករាយជាមួយនិងផលផ្លែរបស់ផែនដី និងមើលថែផែនដីឲ្យបានល្អ ។[៥]

ចំពោះទំនាក់ទំនងទាំងអស់នេះព្រះជាម្ចាស់បានប្រទានមកឲ្យយើង *ផ្នែកទទួលខុសត្រូវរបស់មនុស្ស* ។ យើងមាន*ការទទួលខុសត្រូវ*ក្នុងការស្រឡាញ់ និងស្តាប់បង្គាប់ព្រះជាម្ចាស់ មាន*ការទទួលខុសត្រូវ*ក្នុងការស្រឡាញ់អ្នកជិតខាងរបស់យើង មាន*ការទទួលខុសត្រូវ*ត្រួតត្រា និងមើលថែផែនដី ។ លើសពីនេះទៅទៀត សេចក្តីពិតទាំងនេះប្រាប់យើងពី*សិទ្ធិរបស់ព្រះជាម្ចាស់* ក្នុងការដែលព្រះអង្គគ្រប់គ្រងលើយើង ។ ព្រះជាម្ចាស់មានសិទ្ធិបញ្ជាយើង មានសិទ្ធិក្នុងការប្រទានឲ្យ មានសិទ្ធិក្នុងដកយកវិញ និងមានសិទ្ធិក្នុងការជំនុំជំរះកាត់ក្តី ។[៦] សេចក្តីជំនុំជំរះនៅថ្ងៃចុងក្រោយគឺជាការប្រកាសដ៏ធំសម្បើមពីសេចក្តីពិតទាំងនេះ ។ ការទទួលខុសត្រូវជាមួយគ្នាក៏មានការព្រមចុះចូលទទួលខុសត្រូវនោះមកដែរ ។ ព្រះជាម្ចាស់ជំនុំជំរះមនុស្សលោកទាំងអស់ ការនោះប្រកាសពីសិទ្ធិរបស់ព្រះជាម្ចាស់ដែលព្រះអង្គគ្រប់គ្រងលើយើង និងទាមទារនូវការទទួលខុសត្រូវដែលព្រះអង្គប្រគល់មកឲ្យយើងទទួលខុសត្រូវនោះឯង ។ ហេតុដូច្នេះហើយនៅក្នុងព្រះគម្ពីរទាំងមូលមានចែងសង្កត់ធ្ងន់ លើការទទួលខុសត្រូវរបស់មនុស្ស ។

នៅក្នុងពេលជាមួយគ្នានេះដែរ ព្រះគម្ពីរក៏បានផ្តល់នូវគ្រឹះដ៏ពិតប្រាកដ

---

[៤] *ម៉ាថាយ ២២:៣៨*

[៥] *លោកុ. ១:២៨, ២:១៥*

[៦] *សូមមើលយ៉ូប ៣៣:៤, ទំនុក. ៦៨:៣៥*

ចំពោះសិទ្ធិមនុស្ស ។ ហេតុដែលព្រះជាម្ចាស់បង្កើតយើងមកក្នុងរូបអង្គទ្រង់នោះ គឺផ្តល់នូវភាពថ្លៃថ្នូរ និងតម្លៃចំពោះមនុស្សលោក ។ ការសម្លាប់គឺជាអំពើអាក្រក់បំផុត ពីព្រោះគឺជាការសម្លាប់អ្នកដែលព្រះជាម្ចាស់បង្កើតគេមកនៅក្នុងរូបអង្គទ្រង់នោះឯង[៧] ។ ទម្លាប់នៃការគាំទ្រសិទ្ធិមនុស្សនោះបានព្យាយាមពឹងផ្អែកលើភាពថ្លៃថ្នូរ ឬ លើតម្លៃរបស់មនុស្ស ។ យើងបានដឹងពីព្រះគម្ពីរហើយ ដោយហេតុថាមនុស្សព្រះជាម្ចាស់បង្កើតមកក្នុងរូបអង្គទ្រង់នោះទើបមនុស្សមានតម្លៃក្នុងការបង្កើតនូវការគាំទ្រសិទ្ធមនុស្ស ។ មានបញ្ហាមួយនៅក្នុងទំលាប់នៃការគាំទ្រសិទ្ធិមនុស្សនៅក្នុងសតវត្សទី២០នេះគឺចេញមកពីគតិលោកមួយបែប ដែលនិយាយថាមនុស្សមិនមែនបានបង្កើតមកនៅក្នុងរូបអង្គទ្រង់នោះឡើយ ប៉ុន្តែមនុស្សគ្រាន់ជាការកើតឡើងពីប្រតិកម្មនៃសារធាតុគីមីដោយចៃដន្យកាលពីដើមតែប៉ុណ្ណោះ គឺគ្មានន័យនិងគ្មានគោលដៅអ្វីទាំងអស់ ។ បើសិនការនោះជាការពិតមែន អ៊ីចឹងហេតុអ្វីបានជាមនុស្សគួរមានតម្លៃនោះ? ហេតុអ្វីបានជាមនុស្សត្រូវមានសិទ្ធិច្រើនជាងឆ្កែ ឬជ្រូ? សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរឲ្យយើងបានដឹងថាព្រះជាម្ចាស់បានបង្កើតយើងមកនៅក្នុងរូបអង្គទ្រង់ គឺបានផ្តល់នូវគ្រឹះសំខាន់ចំពោះភាពថ្លៃថ្នូរ និងសិទ្ធិរបស់មនុស្ស ។ គ្រឹះសំខាន់សំរាប់សិទ្ធិមនុស្សនោះ គឺទាក់ទងទៅនឹងការកកើត ។ មនុស្សមិនចាំបាច់ត្រូវការសិទ្ធិទាំងអស់នោះ ឬត្រូវការឲ្យរដ្ឋាភិបាលណាមួយ ឬសិទ្ធអំណាចណាមួយផ្តល់សិទ្ធិនោះឲ្យឡើយ ព្រោះមនុស្សមានសិទ្ធិនោះរួចទៅហើយ ។ យូរៗម្តងរដ្ឋាភិបាលនានា និងសិទ្ធិអំណាចនៃអាជ្ញាធរនានា ក៏ព្រមទទួលស្គាល់នូវភាពថ្លៃថ្នូរ និងសិទ្ធិដែលព្រះជាម្ចាស់បានផ្តល់ឲ្យមកមនុស្សរួចហើយនោះខ្លះដែរ (ទោះបីជាគេមិនបានឲ្យ តម្លៃចំពោះការនោះថ្វាយទៅព្រះជាម្ចាស់ក៏ដោយចុះ) ។

---

[៧] លោកុ.៩:៦

## សេចក្តីបង្រៀនរបស់ព្រះគម្ពីរស្តីពីការការពារសិទ្ធិមនុស្ស

មានអត្ថបទគម្ពីរមួយចំនួនដែលទាក់ទងជាពិសេសជាមួយសិទ្ធិមនុស្ស ។[៨] នៅពេលដែលយើងបានអានខគម្ពីរទាំងនេះ យើងឃើញថាព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ដល់អ្នកដែលទន់ខ្សោយ ។ តាមប្រវត្តិសាស្ត្រមនុស្សជាតិបង្ហាញថា អស់អ្នកដែលមានអំណាចបានទទួលនូវការកេងយកប្រយោជន៍ពីអ្នកដែលគ្មានអំណាច ។ ហេតុនេះទើបបានជាពួកអ្នកមានកេងយកប្រយោជន៍ពួកអ្នកក្រ ។ ពួកមនុស្សពេញវ័យកេងយកចំណេញចំពោះកុមារ ជារឿយៗតែងមានភាពអយុត្តិធម៌ជាច្រើន ។ ព្រះជាម្ចាស់គឺជាព្រះដែលប្រកបទៅដោយសេចក្តីយុត្តិធម៌ ព្រះអង្គមានព្រះហឫទ័យទុកដាក់ចំពោះរបស់សព្វសារពើដែលព្រះអង្គបានបង្កើតមកទាំងអស់ ។ ហេតុដូច្នេះហើយភាពអយុត្តិធម៌នេះ ធ្វើឲ្យព្រះអង្គមិនសព្វព្រះហឫទ័យឡើយ ហើយជាការត្រឹមត្រូវណាស់ដែលយើងត្រូវការពារអ្នកក្រីក្រ អ្នកដែលគេជិះជាន់ អ្នកទន់ខ្សោយដែលគ្មានអំណាចនោះ ។ គម្ពីររ៉ូមជំពូក ១៣ បានបង្រៀនយើងឲ្យដឹងថា ព្រះជាម្ចាស់ជាអ្នកបង្កើតរដ្ឋាភិបាល និងអាជ្ញាធរ ដើម្បីឲ្យគេជាលើកកំពស់ផ្នែកផ្លូវច្បាប់ និងផ្នែកសណ្តាប់ធ្នាប់សង្គម ជួយលើកកំពស់សេចក្តីសុចរិត និងសេចក្តីយុត្តិធម៌ ។ ហេតុដូច្នេះហើយ គ្រីស្តបរិស័ទត្រូវតែយកចិត្តទុកដាក់ ចំពោះអាជ្ញាធរទាំងឡាយដែលនឹងជួយលើកកំពស់ការទាំងអស់នេះ និងមិនមែនប្រើអំណាចរបស់ខ្លួនទៅជិះជាន់សង្កត់សង្កិនចំពោះអ្នកទន់ខ្សោយក្រក្រី និងមិនមែនបង្កើតច្បាប់មិនយុត្តិធម៌សំរាប់ពួកគេនោះឡើយ ។

---

[៨] *ទំនុក. ៨២:១-៤, សុភាសិត ២២:២២-២៣; ៣១:៨-៩, សាស្តា ៥:៨-១០: អេសាយ ១០:១-៤; យេរេមា ៥:២៦-២៩*

## ចំណុចខ្សោយនៅក្នុងចលនាគាំទ្រសិទ្ធិមនុស្ស

ទោះបីជាព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ ចំពោះសិទ្ធិមនុស្សក៏ដោយ ដូចដែលយើងបានឃើញនៅខាងលើនេះស្រាប់ មានការខ្វល់ខ្វាយមួយចំនួនដែលគ្រីស្តបរិស័ទត្រូវតែមានចំណែកជាមួយចលនាគាំទ្រសិទ្ធិមនុស្ស ។ មានបញ្ជីរាយប្រាប់ពីការខ្វល់ខ្វាយទាំងនោះដូចខាងក្រោមនេះគឺៈ

ការប្រើពាក្យ "សិទ្ធិមនុស្ស" ច្រើនជ្រុល ។

ចូរពិចារណាមើលពីករណីពីរយ៉ាងដូចខាងក្រោមនេះ ។

ក. នៅប្រទេសខ្លះចំពោះបញ្ហាការពន្លូតកូន គឺជាពិភាក្សាតវ៉ាគ្នាយ៉ាងខ្លាំង។ ចំពោះអ្នកដែលគាំទ្រចំពោះការពន្លូតកូន និយាយថាស្ត្រីមានសិទ្ធិក្នុងការជ្រើសរើស ដែលមានន័យថាគេអាចមានសិទ្ធិក្នុងការសម្លាប់កូននៅក្នុងផ្ទៃរបស់ខ្លួន បើសិនជាគេជ្រើសរើសធ្វើបែបនោះ ។ ទាក់ទងទៅរឿងនេះ តើយើងជាគ្រីស្តបរិស័ទជឿដូចម្តេចដែរ? តើមនុស្សគ្រប់រូបមានសិទ្ធិធ្វើបែបនេះមែនឬ? តើយើងកំពុងរំលោភសិទ្ធិរបស់ស្ត្រី បើសិនជាយើងថាស្ត្រីមិនអាចមានសិទ្ធិក្នុងការធ្វើបែបនោះឡើយ? បើដូច្នោះមែនតើត្រឹមត្រូវដែរឬចំពោះការរំលោភសិទ្ធិរបស់ស្ត្រីនោះ? គឺជាការមួយដែលមានប្រយោជន៍ណាស់ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវយើងចងចាំពីគតិលោករបស់ព្រះគម្ពីរដែលយើងបានរៀនរួចមកហើយ ។ ព្រះជាម្ចាស់មានសិទ្ធិក្នុងការបង្គាប់យើងឲ្យធ្វើអ្វីនោះ ។ យើងគ្មានសិទ្ធិក្នុងការបះបោរប្រឆាំងទាស់នឹងព្រះជាម្ចាស់ឡើយ តែព្រះជាម្ចាស់ទេដែលផ្តល់ឲ្យយើងមានការទទួលខុសត្រូវ ដើម្បីឲ្យយើងស្តាប់បង្គាប់ដល់ព្រះអង្គ ។ បើសិនព្រះជាម្ចាស់មិនបានផ្តល់សិទ្ធិដល់ស្ត្រីឲ្យសម្លាប់កូនដែលនៅក្នុងផ្ទៃរបស់ខ្លួនទេនោះ ស្ត្រីក៏គ្មានសិទ្ធិធ្វើបែបនោះដែរ ។ គ្រីស្តបរិស័ទត្រូវការពារសិទ្ធិ

ទារកមិនទាន់កើត ព្រោះគេក៏ជារូបអង្គព្រះជាម្ចាស់ដែរ ។

ការពិភាក្សាដេញដោលចំពោះបញ្ហាដែលទាក់ទងចំពោះការពន្លូតកូន និង ការប្រើថ្នាំពន្យារកំណើតអាចជាបញ្ហាស្មុគស្មាញមែនទែន ។ ចុះតើយើងត្រូវធ្វើអ្វីទៅ នៅក្នុងស្ថានភាពដែលទារកជាមូលហេតុគំរាមដល់អាយុជីវិតរបស់ម្ដាយនោះ? រឿងនេះគឺវាហួសពីសមត្ថភាពដែលអត្ថបទនេះដោះស្រាយឲ្យស៊ីជម្រៅចំពោះបញ្ហានេះ ។ ទោះបីជាយ៉ាងក៏ដោយ ទោះជាយើងឈរលើជំហរបែបណានោះ គោលបំណងនៃការព្យាយាមបញ្ជាក់បង្ហាញនោះនៅតែដដែល ។ គ្រីស្ទបរិស័ទទាំងអស់ត្រូវតែយល់ព្រមចំពោះរឿងនេះ នៅពេលដែលយើងទើបប្រទះចំពោះបញ្ហានេះ យើងត្រូវធ្វើការនេះនៅវង្វង់នៃការទទួលខុសត្រូវរបស់យើងជាមនុស្សនៅចំពោះព្រះជាម្ចាស់ មិនមែនត្រូវផ្អែកលើសិទ្ធិផ្ទាល់ខ្លួនរបស់យើងម្នាក់ៗនោះឡើយ។ ទោះបីជាយើងត្រូវនិយាយអំពីសិទ្ធិមនុស្សក៏ដោយ យើងមិនត្រូវគ្រាន់តែគិតពីសិទ្ធិរបស់ស្ត្រីនោះឡើយ តែត្រូវគិតពីសិទ្ធិរបស់ទារកដែលគេមិនទាន់កើតនោះផង ។ ស្ត្រីមានផ្ទៃពោះនោះមិនមែនជាមនុស្សតែម្នាក់នោះទេ គឺជាមនុស្សពីរនាក់ ។ យើងបានដឹងហើយថាព្រះជាម្ចាស់ការពារអ្នកដែលមិនអាចការពារខ្លួនឯងបាន ។ តើមានអ្នកណាទៀតដែលមិនអាចការពារខ្លួនឯងបាន ក្រៅពីទារកដែលនៅក្នុងផ្ទៃនោះដែលគេមើលមិនឃើញ និងយំមិនឮនោះ?

ខ. សិទ្ធិមនុស្សមួយបែបទៀត ដែលតែងតែអះអាងថា ជាសិទ្ធិសាសនា ។ ឧបមាថា លោកអ្នកផ្សាយដំណឹងល្អនរណាម្នាក់ ប៉ុន្តែគេឆ្លើយថាគេមានសិទ្ធិនឹងជឿតាមសាសនារបស់គេផ្ទាល់ដែរ ។ តើលោកអ្នកនឹងឆ្លើយតបយ៉ាងណា? តាមរបៀបខ្លះត្រឹមត្រូវ ហើយដែលអាចនិយាយពីសិទ្ធិសាសនានោះគឺជាសិទ្ធិមនុស្ស ។ មនុស្សគ្រប់រូបមានសិទ្ធិនឹងធ្វើតាមសម្បជញ្ញៈរបស់ខ្លួន ដែលទាក់ទងជាមួយនឹងសាសនាដោយគ្មានទទួល

នូវការបៀតបៀន ឬវាយដំបង្ខំឲ្យបោះបង់ជំនឿរបស់ខ្លួន ហើយទៅជឿតាមជំនឿសាសនាផ្សេងនោះឡើយ ។ មនុស្សមានសិទ្ធិក្នុងការសម្រេចចិត្តរបស់ខ្លួន ។

ប៉ុន្តែក្នុងន័យមួយទៀតនោះចង់និយាយថា មនុស្សម្នាក់ៗមានសិទ្ធិនឹងជឿតាមសាសនារបស់ខ្លួនផ្ទាល់គឺមិនមែននាំទៅរកផ្លូវខុស ។ យើងសូមលើកឡើងមកជំរាបជូនម្តងទៀតពី គោលគំនិតនៃការទទួលខុសត្រូវរបស់មនុស្ស ។ ជំរើសនៃការទទួលជឿលើសាសនានោះមិនមែនជាសិទ្ធិមនុស្សតែមួយនោះឡើយ គឺជាការទទួលខុសត្រូវរបស់មនុស្សដែរ ។ ដោយហេតុនោះ យើងនឹងត្រូវទទួលខុសត្រូវចំពោះព្រះជាម្ចាស់នូវអ្វីដែលយើងបានធ្វើការសម្រេចនោះ ។ បើសិនយើងជ្រើសរើសការថ្វាយបង្គំរូបព្រះនោះ យើងនឹងជាប់ពិរុទ្ធចំពោះព្រះជាម្ចាស់ហើយ ។ បើសិនយើងជ្រើសរើសយកព្រះពិតដើម្បីថ្វាយបង្គំ ដូចដែលគម្ពីរបានចែងនោះ យើងនឹងទទួលបានព្រះពរពីព្រះជាម្ចាស់ជាក់ជាមិនខាន ។ គំរូដ៏អស្ចារ្យអំពីការនេះយើងបានឃើញនៅក្នុងកណ្ឌគម្ពីរ យ៉ូស្វេ ២៤:១-២៤ ។ (សូមអានបួនប្រាំផង) ។ យ៉ូស្វេជាអ្នកដឹកនាំរបស់ពួកបណ្តាជន ហេតុដូច្នេះហើយបានជាគាត់មានសិទ្ធិអំណាចលើពួកគេ ។ ថ្វីដ្បិតតែគាត់មានសិទ្ធិអំណាចនេះក៏ដោយចុះ ក៏គាត់មិនបានប្រើអំណាចបង្ខំគេឲ្យជឿនិងដើរតាមព្រះជាម្ចាស់ដែរ ។ គាត់បានលើកទឹកចិត្តគេឲ្យគេបំរើព្រះពិត ប៉ុន្តែក៏បានប្រាប់គេដែរសូមឲ្យគេធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ គាត់បានព្រមានគេថាពួកគេត្រូវតែទទួលខុសត្រូវនូវអ្វីដែលគេបានធ្វើការសម្រេចចិត្តនោះ បើសិនគេសម្រេចចិត្តថ្វាយបង្គំរូបព្រះ គេនឹងទទួលនូវសេចក្តីជំនុំជំរះពីព្រះជាម្ចាស់ ។ ដូចគ្នានេះដែរ យើងមិនអាចបង្ខំមនុស្សណាម្នាក់ឲ្យក្លាយជាគ្រីស្ទបរិស័ទឡើយ ។ តែគឺជាការទទួលខុសត្រូវរបស់យើងក្នុងការធ្វើបន្ទាល់អំពី ព្រះពិតហើយនិងប្រាប់គេនូវអ្វីដែលព្រះអង្គបានធ្វើតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ

គឺព្រះយេស៊ូនោះឯងហើយ គឺជាការទទួលខុសត្រូវរបស់គេ ចំពោះការឆ្លើយតបថាគេព្រមទទួល និងព្រមជឿឬយ៉ាងណានោះ។

## គ្រោះថ្នាក់ចំពោះការប្រកាសពីសិទ្ធិមនុស្ស ដោយគ្មានការនិយាយយោងទៅដល់ព្រះជាម្ចាស់

គំរូនៅក្នុងចំណុចលេខមួយខាងលើ បង្ហាញឲ្យឃើញពីគ្រោះថ្នាក់នៃការប្រកាសអំពីស្ដីពីសិទ្ធិមនុស្ស ដោយមិនបានគិតពីការបើកសម្ដែងនៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ ទំលាប់របស់អ្នកប្រកាន់ខ្ជាប់សិទ្ធិមនុស្សខ្លះ ជឿថាគ្មានសិទ្ធិអំណាចណាដែលខ្ពស់ជាងមនុស្សនោះឡើយដែលបង្គាប់យើងឲ្យធ្វើអ្វី និងជឿលើអ្វីនោះ ។ បើសិនការនោះពិតមែននោះ អ៊ីចឹងនរណាអាចសម្រេចថាអ្វីខុស និងអ្វីត្រូវ? តើនរណាអាចសម្រេចថាអ្វីជាគ្រឹះស្ថានពិតប្រាកដស្ដីពីសិទ្ធិមនុស្ស? ចំពោះការគ្មានសិទ្ធិអំណាចនៅពីលើយើងនោះ ការប្រកាសពីសិទ្ធិមនុស្សនឹងឆ្លុះបញ្ចាំងឲ្យឃើញពីមនុស្សដែលជាអ្នកប្រកាសនោះថាជាអ្នកមានតម្លៃ ។ ពិតប្រាកដណាស់ហើយ គ្រោះថ្នាក់កន្លែងនេះបង្ហាញយ៉ាងច្បាស់ពីតម្លៃនៃមនុស្សទាំងនេះ ដែលអាចធ្វើទៅមានការយល់ខុសដោយព្រោះគ្មានសិទ្ធិអំណាចណាខ្ពស់ជាងនេះមកជំរុញចំពោះការយល់ ដឹងរបស់គេនោះឯង ។ គ្រីស្ទបរិស័ទបានដឹងថា ព្រះអាទិកររបស់យើងបានមានបន្ទូលប្រកបដោយសិទ្ធិអំណាចនៅក្នុងព្រះគម្ពីរ ហើយយើងត្រូវចុះចូលចំពោះមាត្រដ្ឋានដ៏សំខាន់របស់ព្រះអាទិករនេះ ។ ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជើងរបស់យើង ដើម្បីការពារជើងរបស់យើងមិនឲ្យដើរចូលទៅក្នុងសេចក្ដីងងឹតនៃសីលធម៌ច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ ។

## ការប្រកាសសិទ្ធិមនុស្សដែលឥតប្រយោជន៍ ដោយព្រោះការមិនបានបំពេញតួនាទីទទួលខុសត្រូវរបស់មនុស្ស

ចូរយើងពិចារណាស្ដីពីការអប់រំ ។ មានមនុស្សជាច្រើន បានប្រកាសអះអាងថាកុមារ មិនថាប្រុស ឬស្រីនោះឡើយ គឺមានសិទ្ធិទទួលនូវការអប់រំដូចគ្នា ។ តាមពិតទៅការនេះពិតប្រាកដ ហើយសំខាន់ណាស់ទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ ការអប់រំនោះមិនមែនគ្រាន់តែជាសិទ្ធិនោះប៉ុណ្ណោះទេ តែវាជាការទទួលខុសត្រូវ ។ គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការផ្ដល់ថវិកាគ្រប់គ្រាន់ក្នុងវិស័យអប់រំ ជាការទទួលខុសត្រូវរបស់គ្រូបង្រៀន និងមាតាបិតាក្នុងការបង្រៀនកុមារ និងលើកទឹកចិត្តឲ្យគេខំរៀន ។ វាក៏ជាការទទួលខុសត្រូវរបស់កុមារដែរ ក្នុងការប្រើគំនិតដែលព្រះជាម្ចាស់ប្រទានឲ្យគេដោយយកគំនិតទៅរៀនសូត្រ ។ បើសិនជាការប្រកាសសិទ្ធិនៃការទទួលនូវការអប់រំយូរៗម្ដង តែមនុស្សមិនបានបំពេញនូវការទទួលខុសត្រូវរបស់ខ្លួននោះ អ៊ីចឹងការនោះមិនអាចមានភាពប្រសើរឡើងបានទេ ។ ទោះជាយ៉ាងណាក៏ដោយ បើសិនការប្រកាសសិទ្ធិនូវការទទួលការអប់រំនោះនាំឲ្យមនុស្សបានសម្រេចនូវការទទួលខុសត្រូវរបស់ខ្លួន អ៊ីចឹងការរីកចំរើននោះនឹងអាចកើតមានឡើងមែន សូមអរគុណចំពោះការប្រកាសអំពីសិទ្ធិមនុស្សនោះឯង ។

## គ្រោះថ្នាក់នៃការប្រកាសសិទ្ធិមនុស្ស នៅពេលដែលយុទ្ធសាស្ត្រសមរម្យនោះ គឺការទទួលខុសត្រូវរបស់មនុស្សនោះ តែបែរជាមិនប្រើ

បើសិនជាយើងមើលម្ដងទៀតនូវអត្ថបទនៅក្នុងព្រះគម្ពីរ ដែលរាយក្នុងបញ្ជីដែលទាក់ទងទៅនឹងសិទ្ធិមនុស្សនៅខាងដើមនោះ លោកអ្នកអាច

មើលឃើញចំណុចទាំងនោះបង្រៀនយើងឲ្យដឹងថា យើងត្រូវការពារសិទ្ធិរបស់អ្នកដទៃ ។ ព្រះជាម្ចាស់មិនបានត្រាស់ហៅយើងមកឲ្យការពារសិទ្ធិរបស់ខ្លួនឯងឡើយ តែតាមពិតទៅ ជួនកាលព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យលះបង់សិទ្ធិរបស់ខ្លួនដែរ ។[៩] អត្ថបទគម្ពីរទាំងពីរដែលបានលើកឡើងនោះ និយាយពីសេចក្តីស្រឡាញ់ ។ បញ្ញត្តិដ៏ធំសំខាន់ទាំងពីរនោះគឺត្រូវស្រឡាញ់ព្រះជាម្ចាស់និងអ្នកជិតខាងរបស់ខ្លួន។ ចំពោះការស្រឡាញ់អ្នកដទៃនោះ យើងត្រូវគិតពីការទទួលខុសត្រូវរបស់យើងចំពោះគេ ។ ចំពោះការស្រឡាញ់អ្នកដទៃ យើងជួនកាលត្រូវការពារសិទ្ធិរបស់គេ ហើយលះបង់សិទ្ធិរបស់យើងផ្ទាល់ ។ នៅក្នុងការធ្វើឲ្យមានទំនាក់ទំនងជិតស្និទ្ធនោះគឺជាការសំខាន់បំផុត ។

សូមពិចារណាពីទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតរវាងមនុស្សនិងមនុស្សគឺ: អាពាហ៍ពិពាហ៍ ។ សូមឲ្យយើងមើលទៅដំបូន្មានដែលលោកប៉ូលបានផ្តល់ឲ្យប្តីនិងប្រពន្ធនៅក្នុង អេភេសូរ ៥:២១-៣១ (សូមអានអត្ថបទគម្ពីរនោះ) ។ លោកប៉ូលមិនបានប្រាប់ប្តី ឬប្រពន្ធឲ្យការពារសិទ្ធិរបស់ខ្លួននោះឡើយ ។ គាត់មិនបានបង្រៀនប្រពន្ធឲ្យប្រាប់ប្តីឲ្យបំពេញតួនាទីទទួលខុសត្រូវរបស់ខ្លួនទេ ឬក៏មិនបានប្រាប់ប្តីឲ្យទៅប្រាប់ប្រពន្ធឲ្យបំពេញតួនាទីរបស់ខ្លួនឡើយ ។ (ត្រង់នេះមិនមែនបានសេចក្តីថា ប្តីឬប្រពន្ធមិនអាចស្តីបន្ទោសគ្នាបាននោះឡើយ) ។ សេចក្តីទូន្មានរបស់លោកប៉ូលចំពោះអ្នកដែលមានប្តីមានប្រពន្ធនោះគឺថា ម្នាក់ៗត្រូវដឹងច្បាស់ពីតួនាទីទទួលខុសត្រូវរបស់ខ្លួនដែលខ្លួនត្រូវបំពេញ ចំពោះដៃគូរបស់ខ្លួននោះ ។ នេះគឺជាដំបូន្មានមួយដ៏ប្រពៃបំផុត ។ ដំបូន្មាននេះនឹងផ្តល់អត្ថប្រយោជន៍សំខាន់ចំពោះអ្នកដែលមានគូស្រករហើយ បើម្នាក់ៗព្យាយាមស្មោះត្រង់

---

[៩] *ឧទាហរណ៍ សូមមើលនៅក្នុងម៉ាថាយ ៥:៣៨-៤៨; ១កូរិន. ៨:១-៩:២៣។*

ចំពោះការទទួលខុសត្រូវរបស់ខ្លួនដោយគិតដល់ដៃគូរបស់ខ្លួន ជាជាងគិតអំពីសិទ្ធិរបស់ខ្លួនផ្ទាល់ ។

នៅពេលដែលយើងពិចារណាមើលទំនាក់ទំនងមួយទៀត នៅក្នុងផ្ទះ គឺរវាងឪពុកម្ដាយនិងកូន យើងអាចឃើញពីគ្រោះថ្នាក់នៃការប្រកាសសិទ្ធិមនុស្សដែលប្រឆាំងនឹងការទទួលខុសត្រូវរបស់មនុស្ស ។ អង្គសមាជនៃអង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្ស ដែលមានទាក់ទងទៅនឹងការលើកកំពស់ដល់សិទ្ធិកុមារ ។ សិទ្ធិកុមារត្រូវការជាចាំបាច់ដើម្បីការពារ ទោះបីយ៉ាងណាក៏ដោយក្រុមអ្នកកាន់សាសនា បានបង្ហាញពីការខ្វល់ខ្វាយដែលទាក់ទងនឹងការប្រកាសសិទ្ធិកុមារ នឹងធ្វើឲ្យសិទ្ធិ និងការទទួលខុសត្រូវរបស់ឪពុកម្ដាយ ចំពោះបីបាច់ថែទាំកូន បង្រៀន អភិវឌ្ឍ ហើយប្រដៅតម្រង់កូនបែរជាចុះខ្សោយ ។ ឧទាហរណ៍ ឪពុកម្ដាយប្រដៅកូនដោយវាយតប់នោះ ប្រហែលជាអាចចោទប្រកាន់ថារំលោភលើសិទ្ធិកុមារ ។ ចំពោះឪពុកម្ដាយផ្ដល់នូវការបង្រៀនដល់កូនចៅរបស់ខ្លួន តាមសាសនានោះអាចទទួលនូវការពិចារណាពីអ្នកដទៃថា ជាការរំលោភលើសិទ្ធិកូនដែរដោយកូនមិនជ្រើសរើសតាមគំនិតរបស់ខ្លួនផ្ទាល់ ។ គ្រីស្ទបរិស័ទត្រូវប្រុងប្រយ័ត្ន ចំពោះការកើតរឿងបែបនេះថ្ងៃអនាគត ។

## និស្ស័យរបស់មនុស្ស

យើងឃើញហើយថា គ្រីស្ទបរិស័ទត្រូវលើកកំពស់សិទ្ធិមនុស្ស ។ យើងសង្ឃឹមថាការលើកកំពស់សិទ្ធិមនុស្សនឹងជួយពិភពលោកនេះមានភាពប្រសើរឡើង ។ តែនៅពេលជាមួយគ្នានេះដែរ យើងមិនត្រូវគិតថានេះជាដំណោះស្រាយតែមួយគត់ ចំពោះបញ្ហាទាំងឡាយដែលមនុស្សទាំងអស់កំពុងជួបប្រទះនូវបញ្ហានោះឡើយ ។ មានមនុស្សជាច្រើនជឿថាទាំងអស់ល្អតាមលក្ខណៈនិស្ស័យរបស់ខ្លួន ហើយហេតុដូច្នេះគេមាន

សុទិដ្ឋិនិយមចំពោះលទ្ធផលពីសកម្មភាពសិទ្ធិមនុស្ស ដូចជាការប្រកាសស្តីពីសិទ្ធិ មនុស្ស ។ គ្រីស្តបរិស័ទមិនត្រូវមានជំនឿខុសលើបែបនោះឡើយ។ ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ថាមនុស្សយើងមាននិស្ស័យបាប ហើយយើងមិនអាចមានសមត្ថភាពជួយសង្គ្រោះខ្លួនឯងបានឡើយ ក្រៅពីទទួលទណ្ឌកម្ម ដោយព្រោះអំពើបាបរបស់យើងនោះឡើយ ប៉ុន្តែអំពើបាបក៏មានអំណាចលើយើងដែរ ។[១០] ដំណោះស្រាយរបស់មនុស្សមិនអាចកែខៃបញ្ហារបស់ពិភពលោកនេះបានឡើយ ។ ប៉ុន្តែព្រះជាម្ចាស់បានធ្វើការនោះតាមរយៈព្រះយេស៊ូ ដើម្បីសង្គ្រោះយើងឲ្យរួចពីបាបរបស់យើង ។ ដំណោះស្រាយចំពោះបញ្ហានៅក្នុងលោកនេះគឺជាដំណឹងល្អ ។ នៅក្នុងដំណឹងល្អព្រះជាម្ចាស់មិនគ្រាន់តែអត់ទោសបាបឲ្យយើងប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គប្រទានជីវិតថ្មី ដើម្បីឲ្យយើងអាចស្តាប់បង្គាប់ដល់ព្រះអង្គទៀតផង ។ ការនេះផ្តល់នូវសេចក្តីសង្ឃឹមពិតសំរាប់សង្គមដ៏ប្រសើរ ។ យើងក៏នឹងត្រូវរង់ចាំទទួលពិភពលោកនៅថ្ងៃអនាគត នៅពេលដែលអ្វីទាំងអស់បានធ្វើឲ្យបានប្រសើរឡើង ។

## សរុបសេចក្តី

ប្រឈមមុខទៅនឹងការទទួលរងនូវការឈឺចាប់យ៉ាងច្រើននៅក្នុងលោកីយ៍នេះ គ្រីស្តបរិស័ទត្រូវការពារសិទ្ធិរបស់ពួកអ្នកក្រីក្រ អ្នកទន់ខ្សោយ និងអ្នកដែលត្រូវគេជិះជាន់សង្កត់សង្កិន ។ យើងត្រូវខំកែទម្រង់រដ្ឋាភិបាល ប្រព័ន្ធចាត់ចែងការងារផ្សេងៗ ប្រព័ន្ធច្បាប់ ក្រុមហ៊ុនជាដើម។ល។ ប្រយោជន៍ឲ្យមនុស្សទាំងអស់បានទទួលនូវភាពយុត្តិធម៌សមរម្យ ។

---

[១០] *សូមមើលរ៉ូម ៧:៧-២៤; អេភេសូរ ២:១-៣; យេរេមា ១៣:២៣; ១៧:៩ ។*

តែទោះជាយ៉ាងក៏ដោយ គ្រីស្ទបរិស័ទត្រូវប្រយ័ត្នផងដែរ ចំពោះការប្រើពាក្យ "សិទ្ធិមនុស្ស" ច្រើនហួសពេក ។ គ្រីស្ទបរិស័ទដែលធ្វើការជាមួយអង្គការមិនមែនជាគ្រីស្ទបរិស័ទ ត្រូវប្រុងប្រយ័ត្នដើម្បីពិនិត្យមើលនូវអ្វីដែលគេពុនោះ តើវាស្របទៅនឹងព្រះគម្ពីរឬអត់ ។

នៅពេលដែលយើងពិនិត្យមើលផ្ទៀងផ្ទាត់ជាមួយព្រះគម្ពីរ ទើបយើងដឹងថាមានសង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់មនុស្ស នៅចំពោះព្រះជាម្ចាស់ ។ យើងត្រូវប្រកាសអះអាងឲ្យលោកីយ៍នេះដឹងថា គេត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលគេបានធ្វើចំពោះព្រះជាម្ចាស់ ដ្បិតការទទួលខុសត្រូវនោះ ព្រះអង្គបានផ្តល់គេនៅក្នុងទំនាក់ទំនងទាំងបីខាងលើដែលយើងបានលើកមកនិយាយរួចហើយនោះ ។ គ្មានអ្វីអាចលាក់កំបាំងពីព្រះអង្គបានឡើយ ព្រះអង្គទតឃើញគ្រប់ទាំងអស់នូវអ្វីដែលមាននៅក្នុងចិត្តរបស់យើង ។ លោកីយ៍ទាំងមូលនេះបានបះបោរទាស់ទទឹងនឹងព្រះជាម្ចាស់ ហេតុដូច្នេះហើយទើបលោកីយ៍នេះត្រូវស្ថិតនៅក្រោមការជំនុំជំរះរបស់ព្រះអង្គ ។ យើងមិនអាចមានសមត្ថភាពដោះស្រាយបញ្ហានេះ ដោយពឹងផ្អែកលើដំណោះស្រាយរបស់មនុស្ស ឬដោយពឹងផ្អែកលើសាសានារបស់មនុស្សនោះបានទេ ។ ប៉ុន្តែព្រះជាម្ចាស់ធ្វើការសង្គ្រោះយើងតាម រយៈព្រះយេស៊ូជាពិសេសតាមរយៈអ្វីដែលព្រះអង្គបានសម្រេចនៅកាលដែលព្រះអង្គសុគត និងមានព្រះជន្មរស់ឡើងវិញ ។ នៅក្នុងដំណឹងល្អព្រះជាម្ចាស់បានហៅមនុស្សឲ្យមកលន់តួនូវអំពើខុសឆ្គងដែលគេបានប្រព្រឹត្ត និងត្រូវព្រមទទួលជឿលើព្រះយេស៊ូ ។ ការនេះមិនគ្រាន់តែជួយឲ្យមានការសង្គ្រោះផ្ទាល់ខ្លួនឡើយ តែនាំឲ្យមានការផ្លាស់ប្រែសង្គមថែមទៀតផង ។

HONEYCOMB 3/1 (January 2002): 72–80



# Jonah—The Reluctant Missionary

*Russell H. BOWERS, Jr.*

What Christian can't identify with Jonah? His story captures the contrasts of the life of faith. Jonah's actions display his human weakness, yet God's activities are so miraculous that many readers doubt the story's historicity. Jonah loves God but hates people. He serves faithfully in one role but shuns another. He believes in God's omnipresence yet tries to run from him. He celebrates the grace God shows him but begrudges it to the Ninevites. Surely the speckled character of this prophet—countered by God's patience and grace toward him—should encourage our confidence in the Bible: the picture it paints of us is all too true. Few whom God uses are unblemished saints.

Jonah prophesied in Israel about the time of Jeroboam II (793–753 BC). His successful prediction of the restoration of Israel's boundaries[1] accredited him as a true prophet and qualified him for God's call to a new task. Jeroboam II ruled during a period of Assyrian weakness between the death of Adadnirari III in 782 and the usurpation of the throne by Tiglathpileser III in 745. This may help explain

---

[1] 2 Ki 14:25.

both Jeroboam's ability to restore Israel's borders, as well as a sense of vulnerability within Assyria which helped prompt her repentance under Jonah's preaching.

## Chapter One: Jonah Goes From God

The story of chapter one is simply told. God calls Jonah to preach against Nineveh. Jonah flees in the opposite direction. God sends a storm that threatens to scuttle his ship. The sailors throw the runaway overboard, and the sea calms.

God's call to preach against Nineveh introduces an important theme of the book. Yahweh is not the God of Israel only, he also cares for her pagan neighbors. This truth Jonah fights to the end. Nineveh, situated about 800 kilometers northeast of the prophet's hometown of Gath Hepher, was one of the main administrative cities of the Assyrian Empire. Assyria was noted for its cruelty.[2] Jonah, a Galilean patriot, had prophesied that his own land would be strengthened, but was displeased that God should seek the welfare of an enemy, particularly one so wicked and cruel. One can imagine a similar reluctance many Christians today might feel toward a call to minister to the Khmer Rouge. They treated our families and neighbors here with the most heartless cruelty. Surely God does not wish them well! Surely any doom hanging over their heads is well deserved! Surely we should do nothing to help them avert it!

But God cares even for such wicked people, and commissioned his prophet to preach to them. Jonah could not agree, and fled in the opposite direction.

---

[2]One king boasted after a successful battle, "The nobles I flayed. Three thousand captives I burned with fire. I left not one hostage alive. I cut off the hands and feet of some. I cut off the noses, ears, and fingers of others. The eyes of numerous soldiers I put out. Maidens I burned as a holocaust." Another says of his enemy, "I took him alive in the midst of battle. In Nineveh, my capital, I slowly tore off his skin." Such atrocities help us understand Nahum's closing words, "Everyone who hears the news about you claps his hands at your fall, for who has not felt your endless cruelty?"

This leads us to a second theme of the book. Sometimes everyone and everything obeys God except his own people. God hurled[3] a great wind; it obeyed by churning the sea with gusto, and both crescendoed and quieted on cue (1:4, 11, 15). God appointed[4] a fish, a vine, a worm, and a scorching east wind (1:17; 4:6–8), that swallowed, sprang up, gnawed, and blew as directed. When God spoke[5] to the fish, it vomited its meal (2:10). When God spoke to the Ninevites through Jonah's preaching, they repented. The only one to disobey the Lord was his prophet, who ran the other way (1:3) and griped about God's grace (4:2–3).

Pagan people in particular are presented as more pious than God's prophet in this story. Jonah seems untroubled as he flees from "Yahweh, the God of heaven, who made the sea and the land"—he is sufficiently relaxed to fall into a deep sleep as he does. By contrast, the sailors were terrified when they learned from whom he was fleeing (1:10). They did their best to try to save Jonah from a watery grave, and when they at last reluctantly prepared to fling him into the waves they implored God's pardon and acknowledged his sovereignty (1:14). When the sea calmed these non-Jews feared Yahweh, offered a sacrifice, and vowed vows (1:16). Later, when Nineveh's king heard Jonah's warning, he repented and commanded his subjects do the same. Although Jonah *says* that he fears[6] "Yahweh, the God of heaven, who made the sea and the land," it is the pagan sailors and the Ninevites who actually *do* so.

---

[3]טול, a forceful word. Four of its fourteen occurrences in the Hebrew Old Testament occur in Jonah 1 (verses 4, 5, 12, 15).

[4]מָנָה, another relatively uncommon word used four times in Jonah (1:17 [2:1 in Hebrew]; 4:6, 7, 8, translated "provided" in the NIV). The sense of "assigning someone a responsibility" may be seen in the word's occurrences in the book of Daniel (1:5, 10, 11; 2:24; 49; 3:12; 5:26).

[5]אָמַר, a common word meaning "say" or "utter," but sometimes with the sense of "command."

[6]יָרֵא, translated "worship" in the NIV, v. 9.

This is not the only occasion in scripture when the actions of outsiders outshine those of God's people. Judah acknowledged that Tamar had acted more righteously than he (Gen 38:26); Abimelech scolded Abraham (Gen 20:9); many from east and west will enter the kingdom while its subjects are thrown outside (Matt 8:11f). Why is it that sometimes those who should know God act worse than those we imagine to be ignorant of him?

So Jonah's rejection of God's love for his enemies and refusal to seek their salvation start him on a disastrous downward descent. He goes down to Joppa,[7] down into the ship, down below deck to sleep, down in the sea "to the roots of the mountains,"[8] and down in the belly of the fish. He only starts back up after his repentance in chapter two.

## Chapter Two: Jonah Goes To God

It is amazing how trouble prompts God's people to repent and pray. Jonah had thought he could hide from God by going to a far city. God has reacted by hiding him more profoundly than he had planned. What is more hidden from view than the stomach of a fish swimming beneath the waves? Yet from that "hidden" place Jonah goes to God in prayer, confident now that even from there God sees and hears him. Somehow his theology of omniscience and omnipresence had changed. In fleeing to Tarshish the prophet was disobeying God; now he promises, "What I have vowed I will make good" (2:10).

What prompted these changes of heart and action? Trouble. "In my *distress* I call to Yahweh. . . . From the *depths of the grave* I called for help" (2:2). Trouble caused him to turn. Jonah's situation is not unique. David acknowledges, "Before I was afflicted I went astray, but now I obey your word."[9] Israel's historical pattern has

---

[7]Present-day Jaffa. This was not the port closest to Jonah's town, but it was one where long-distance ships anchored. Jonah was preparing to flee as far as he could.

[8]יָרַד "go down, descend" is used in 1:3 (twice), 5; 2:7.

[9]Ps 119:67.

been to require distress to drive her to God,[10] and it will require the distress of the future tribulation period to convince the nation to "look on me, the one they have pierced, and . . . mourn for him,"[11] welcoming Jesus as their messiah at last.

But why wait for trouble? Why not seek and serve the Lord when things are going well? Then perhaps he won't have to send us the trouble. That's the idea behind 1 Corinthians 11:31—"But if we judged ourselves, we would not come under judgment." God "does not willingly bring affliction or grief to the children of men,"[12] only what is required to punish us (though not fully) for our sins and turn us back to the right path. But why not walk the right path in the first place? Why go through all that pain to force us eventually to do what we could have freely and more enjoyably done?

But at least Jonah turned. That is a further example for us. When God chastens let us learn the needed lessons and be healed, rather than either continue to rebel or lose heart and give up. Jonah illustrates the precepts of Hebrews 12:4–13. It is a shame that he required the loss of his boat fare and the possessions he had with him in the ship—to say nothing of three days lost inside a fish's slimy stomach—but at least he learned.

Some people object to Jonah because they find incredible the story of a man's being swallowed by a whale and surviving. The Hebrew text does not specify the species, but uses the word for "fish."[13] Whether it was fish or whale, there have been documented cases in modern times where sailors have been swallowed and recovered alive by their shipmates after many hours.

---

[10]E.g., Jud 10:9–10.

[11]Zech 12:10; cf. her trouble in v.3.

[12]Lam 3:33.

[13]דָּג twice in 1:17 [Heb 2:1] and once in 2:10 [Heb 2:11]; דָּגָה in 2:1 [Heb 2:2]. The LXX translates with κῆτος ("sea monster, large fish," including spouting *cetacea*) in all four places. Matt 12:40 also uses κῆτος.

## Chapter Three: Jonah Goes For God

Jonah has wasted time, lost resources, and physically suffered. But he has gained nothing. After all his struggles and losses he hears the same commission.[14]

Nothing is gained when God's people resist his will. Often he simply brings them through deep waters back to the very place they first left the path. This was Israel's experience after the exodus. God brought his people to Kadesh-Barnea and instructed them to fight a people stronger than they and take their land. The nation failed to believe and obey. The result was God's chastening the nation with forty years of wandering—they wasted time, lost resources, and physically suffered. At the end they were brought to another entry point but given essentially the same command—fight a people stronger than they and take their land. Centuries later Israel rejected Jesus as her messiah. But God did not change his deepest plans for Jesus or for them because of their unbelief. Israel has lost time, wasted resources, and physically suffered over the centuries (and will do so even more during the tribulation period). But she will gain nothing through her rebellion, but simply be brought through suffering to the place where she is again offered the messianic rule of Jesus, but this time finally says, "Blessed is he who comes in the name of the Lord."[15]

At his second opportunity Jonah "obeyed the word of Yahweh and went" (3:3). Because Jonah apparently preached periodically as he penetrated Nineveh, his visit would require three days. Or perhaps the time notation includes the city's suburbs. At any rate he proclaimed God's message of impending judgment.

Some people who have survived hours in a fish's stomach have emerged with their skin bleached a deathly white or greenish-white by the stomach acids. The victim's hair may fall out. In 763

---

[14]קוּם לֵךְ אֶל־נִינְוֵה הָעִיר הַגְּדוֹלָה וּקְרָא עָלֶיהָ/אֵלֶיהָ 1:2; 3:2. The identity of the words [עָלֶיהָ in 1:2 is often interchangeable with אֵלֶיהָ in 3:2] is lost in the NIV translation.

[15]Matt 23:37–39.

B.C. Assyria had an eclipse of the sun, an event often viewed as ominous by superstitious people. As noted earlier, the years 782–745 B.C. included military decline and threat.[16] A combination of a green, hairless stranger predicting doom at a time when the sun had been eclipsed and the empire appeared vulnerable may have inclined the population to take the prophet's warning seriously.

But for whatever reason, the city repented. The king decreed that even the animals should fast, and that all people should stop their wickedness and call on God. It was one of the most comprehensive responses in religious history.

God was pleased. When he saw how they turned he had compassion on them and waived the threatened punishment.

Compassion.(Sanskrit, *karuna*) is central to Buddhism. The story of his enlightenment teaches that, after perceiving that existence is without substance, Siddhartha filled with compassion for all living things as they suffered in ignorance. He resolved to share his newly-discovered wisdom with the world, a pledge which is repeated in the vow of the bodhisattva: "However innumerable the sentient beings, I vow to save them all." To be enlightened includes having compassion on all sentient beings and seeking to bring them together with oneself to enlightenment. Wisdom and compassion are inseparable. Because of its centrality, compassion in Buddhism parallels love in Christianity.

But, as mentioned above, God is compassionate too. His compassion moved him to warn the Ninevites through Jonah in the first place. When they repented, God's compassion moved him to "not bring upon them the destruction he had threatened." God forgave; Nineveh was spared; Jonah's prediction failed.

## Chapter Four: Will Jonah Go With God?

But does God's servant share God's compassion? Does Jonah celebrate Nineveh's pardon, or would the patriot prefer to watch the

---

[16]Assyria struggled during these years against mountain tribes from the north, who had encroached to within 150 kilometers of Nineveh.

wasting of his foes? Will Jonah retain the nationalistic pride that prompted him to run rather than preach, or will he now "go with God" and share God's compassion for the lost?

Verse one gives the answer: "Jonah was greatly displeased and became angry." He wanted to die.

God is not as interested in dealing out death as people in the book seem to be in trying to find it. He is "a gracious and compassionate God, slow to anger and abounding in love, a God who relents from sending calamity."[17] He will prove as gracious in turning his prophet from death as he was in turning the Ninevites. He will not allow people to persist in their rebellion and its judgment without warning. Since Jonah does not seem to listen to words, God reverts, as in chapter one, to an object lesson.

Jonah had probably entered Nineveh from the west, traveled through it as he preached, and arrived on its eastern edge. Leaving the city he sat outside, apparently hoping for its destruction. The episode of the vine, the worm, and the east wind riled Jonah for a second time to the point of his wishing to die. The withered vine provided the illustration by which God could make his point.

Jonah had been greatly concerned for the vine. He valued it and was glad it was there.[18] This was true even though Jonah had neither planted nor tended the vine. When it died he grieved. By contrast, God *had* made the inhabitants of Nineveh. These included 120,000 humans and many cattle, not merely one vine. In the light of

---

[17]4:2. In this verse Jonah essentially quotes God's self-description given to Moses in Ex 34:6–7 and repeated in such passages as Num 14:18; Neh 9:17; Ps 86:15; 103:8; 145:8; and Joel 2:13. He is objecting to a central attribute of God's character, and forgets that he himself has benefited from God's gracious forgiveness.

[18]The mean maximum temperature in Mesopotamia's hot season is 43° C. During a "sirocco" east wind the temperature rises 8–12° C. above the average. The heat bakes so much moisture from the air so that one's skin feels drawn tight. During sirocco days people tend to be irritable and quick to seek shelter. It is easy to see why Jonah valued the vine.

these contrasts, can Jonah see how God should be concerned[19] for Nineveh, so that its demise would displease him? Will Jonah repent of his narrow, hard-hearted sectarianism and actively share God's universal, compassionate concern?

The book ends with this question. We don't know Jonah's response. That is probably good, because in this way the question now confronts each reader. What will I do about the lost who face God's judgment? Withhold my heart and help in lofty disdain? Or share the love and compassion that should arise from grace and enlightenment, and work to dissuade them from their delusions and demise?

---

[19]The same word (חוס *pity, look upon with compassion*) is used of Jonah's concern for the vine and God's for Nineveh.

សំណុំឌីកឃុំ ៣/១ (មករា ២០០២)៖ ៨១-៩៧



# យ៉ូណាស-បេសកជនដែលរារែក

*លោក រ៉ាស់សែល បាវឌើស៍*

អ្វីដែលគ្រីស្ទបរិស័ទ មិនអាចកំណត់រកឲ្យឃើញច្បាស់ជាមួយនឹងយ៉ូណាសនោះ? រឿងរបស់គាត់បានក្រសោបយកនូវភាពផ្ទុយគ្នានៃជីវិតរបស់ជំនឿ ។ សកម្មភាពរបស់មនុស្សបង្ហាញឲ្យឃើញនូវភាពកំខ្សោយនៅក្នុងនិស្ស័យជាមនុស្សរបស់គាត់ តែទោះជាយ៉ាងណាក៏ដោយ ព្រះរាជសកម្មភាពរបស់ព្រះជាម្ចាស់គឺមានភាពអស្ចារ្យ ដែលជាហេតុបណ្តាលឲ្យមនុស្សជាច្រើនឆ្ងល់នូវប្រវិត្តិនៃរឿងទាំងឡាយនោះ ។ លោកយ៉ូណាសស្រឡាញ់ព្រះជាម្ចាស់ ប៉ុន្តែគាត់ស្អប់មនុស្ស ។ គាត់បំរើយ៉ាងស្មោះត្រង់ចំពោះកិច្ចការក្នុងតួនាទីមួយតែធ្វើមិនបានពេញដៃពេញជើង ចំពោះកិច្ចការមួយទៀត ។ គាត់ជឿចំពោះការគង់នៅសព្វទីកន្លែងរបស់ព្រះជាម្ចាស់ តែទោះជាជឿបែបនោះក៏ដោយក៏ខំព្យាយាមរត់គេចពីព្រះអង្គដែរ ។ គាត់បានអបអរចំពោះព្រះគុណរបស់ព្រះជាម្ចាស់ ចំពោះការដែលព្រះអង្គបានបង្ហាញមកឲ្យគាត់ ប៉ុន្តែគាត់បែរជាមិនអរសប្បាយចំពោះព្រះគុណរបស់ព្រះជាម្ចាស់ដែលព្រះអង្គមាន ចំពោះអ្នកទីក្រុងនីនីវេទៅវិញ ។ ពិតមែនហើយចរិកលក្ខណៈដ៏ចម្លែកនៃព្យាការីម្នាក់នេះ គឺថាគាត់បានជួបនឹង សេចក្តីអត់ធ្មត់

និងព្រះជាម្ចាស់ចំពោះគាត់ ការនេះគួរជាទីជំរុញលើកទឹកចិត្តរបស់យើងឲ្យទុកចិត្តដល់ព្រះគម្ពីរថា៖ រូបភាពនេះពិតជាឆ្លុះបញ្ចាំងពីជីវិតពិតរបស់យើងទាំងអស់គ្នាមែន ។ មានពួកបរិសុទ្ធតិចណាស់ដែលព្រះជាម្ចាស់ប្រើហើយគ្មានកន្លែងដែលគេចាប់កំហុសមិនបាននោះ ។

យ៉ូណាសបានថ្លែងទំនាយ នៅក្នុងប្រទេសអ៊ីស្រាអែលស្ថិតីរជ្ជកាលនៃព្រះបាទយេរ៉ូបោមទី២ (៧៩៣-៧៥៣ មុនគ្រីស្តសករាជ) ។ ទំនាយទាយពីការទទួលជោគជ័យនៃការស្តារឲ្យមានព្រំប្រទល់[១] ប្រទេសឡើងវិញបង្ហាញគ្រប់លក្ខណៈថាគាត់ជាព្យាការីដ៏ពិតប្រាកដ និងធ្វើឲ្យគាត់មានគុណសម្បត្តិគ្រប់គ្រាន់ចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដើម្បីទទួលការងារថ្មីនេះ ។ ស្តេចយេរ៉ូបោមទី២គ្រប់គ្រងប្រទេសក្នុងអំឡុងពេលដែលពួកអាស៊ីរី(អាស៊ើរ)មានភាពទន់ខ្សោយនៅចន្លោះពេលនៃការសុគតរបស់ស្តេចអាដាដនីរ៉ារី ទី៣ នៅក្នុងឆ្នាំ៧៨២ និងការទម្លាក់រាជ្យរបស់ស្តេចទីក្លាភីលីស័រទី៣ នៅឆ្នាំ៧៤៥ ។ ការនេះអាចពន្យល់ពីសមត្ថភាពរបស់ស្តេចយេរ៉ូបោមក្នុងការ ស្តារព្រំប្រទល់នៃប្រទេសអ៊ីស្រាអែល ក៏ដូចគ្នានឹងភាពងាយរងគ្រោះនៅក្នុងអាណាចក្រ អាស៊ីរី ដែលជួយធ្វើឲ្យប្រទេសនេះមានការប្រែចិត្តដោយព្រោះការប្រកាសរបស់លោកយ៉ូណាស ។

## ជំពូកមួយ : យ៉ូណាសរត់ចេញពីព្រះជាម្ចាស់

សាច់រឿងនៅក្នុងជំពូកមួយបានប្រាប់ពីលក្ខណៈសាមញ្ញ ។ ព្រះជាម្ចាស់បានត្រាស់ហៅយ៉ូណាសឲ្យទៅអធិប្បាយទាស់នឹងក្រុងនីនីវេ ។ យ៉ូណាសបានរត់ទៅផ្លូវផ្សេង ផ្ទុយពីផ្លូវដែលព្រះជាម្ចាស់ចាត់ឲ្យទៅ ។ ព្រះជាម្ចាស់ធ្វើឲ្យមានខ្យល់ព្យុះយ៉ាងខ្លាំង ដែលគំរាមនឹងធ្វើឲ្យលិចសំពៅ

---

[១] *២ពង្សាវតារក្សត្រ ១៤:២៥*

ដែលយ៉ូណាសជិះ ។ ពួកអ្នកសំពៅបានបោះយ៉ូណាសចេញពីសំពៅ ហើយពេលនោះសមុទ្រក៏ស្ងប់ទៅ ។

ការត្រាស់ហៅរបស់ព្រះជាម្ចាស់គឺឲ្យយ៉ូណាសទៅអធិប្បាយទាស់នឹងពួកអ្នកទីក្រុងនីនីវេនោះ គឺបង្ហាញឲ្យឃើញពីសារៈសំខាន់នៃខ្លឹមសាររបស់កណ្ឌគម្ពីរនេះ ។ ព្រះយេហូវ៉ាគឺមិនគ្រាន់តែជាព្រះជាម្ចាស់នៃប្រទេសអ៊ីស្រាអែលប៉ុណ្ណោះទេ គឺព្រះអង្គយកព្រះហឫទ័យទុកដាក់ថែទាំដល់សាសន៍ដទៃ ដែលនៅក្បែរខាងរបស់ប្រទេសអ៊ីស្រាអែលផងដែរ ។ សេចក្តីពិតនេះឯង ដែលធ្វើលោកយ៉ូណាសប្រឆាំងតវ៉ារហូតដល់ទីចុងបញ្ចប់ ។ ទីក្រុងនីនីវេស្ថិតនៅប្រហែលជា ៨០០គីឡូម៉ែត្រប៉ែកឦសាននៃទីក្រុងរបស់លោកយ៉ូណាស ដែលជាទីក្រុងកំណើតរបស់គាត់ឈ្មោះ កាថ ហិបភើ គឺជាទីក្រុងមួយក្នុងចំណោមទីក្រុងដែលចាត់ចែងបានល្អប្រសើរបំផុតនៃចក្រភពអាស៊ីរី ។ អាស៊ីរីត្រូវគេបានទទួលស្គាល់ថា ជាទីក្រុងដែលប្រកបទៅដោយអំពើឃោរឃៅ[២] ។ លោកយ៉ូណាសគឺជាអ្នកស្រុកកាលីឡេស្នេហាជាតិ ដែលបានថ្លែងទំនាយថា ទឹកដីរបស់គាត់ផ្ទាល់គួរតែពង្រឹងឲ្យរឹងប៉ឹងឡើង ប៉ុន្តែគាត់មិនសប្បាយចិត្តឡើយដោយព្រោះព្រះជាម្ចាស់

*[២] មានស្តេចមួយអង្គបានអួតពីជ័យជំនះរបស់ខ្លួនទៅលើសមរភូមិ "ខ្ញុំបានបន្ទាត់ស្បែកពួកនាម៉ឺន ហើយខ្ញុំបានដុតពួកឈ្លើយសឹកបីពាន់នាក់ថែមទៀត ។ ខ្ញុំមិនបានទុកចំណាប់ខ្មាំងណាម្នាក់ឲ្យនៅរស់រាន មានជីវិតឡើយ ។ ខ្ញុំបានកាត់ដៃកាត់ជើងអ្នកខ្លះ និងបានកាត់ច្រមុះ និង ត្រចៀកអ្នកដទៃ ។ ខ្ញុំបានខ្វេះភ្នែកទាហានអស់ជាច្រើននាក់ ។ ខ្ញុំបានដុត ពលសេះស្លាប់យ៉ាងច្រើនសន្ធឹក" ។ មានម្នាក់ទៀតនិយាយពីសត្រូវ របស់ខ្លួនថា៖ "ខ្ញុំបានចាប់គេទាំងរស់នៅក្នុងសារមភូមិ ។ នៅក្នុងទីក្រុង នីនីវេជាក្រុងរបស់ខ្ញុំ ខ្ញុំបានហែកស្បែករបស់គាត់ម្តងបន្តិចៗ" ។ អំពើឃោរឃៅបែបនេះ ជួយ ឲ្យយើងយល់ពីពាក្យសំដីរបស់លោកណាហ៊ុម "អស់អ្នកដែលឮដំណឹងពីឯង គេទះដៃអរ ដ្បិតតើមានអ្នកឯណាដែលមិនត្រូវអំពើកំណាចរបស់ឯងជានិច្ចនោះ?"។*

គិតគូរដល់សុខមាលភាពរបស់សត្រូវរបស់លោកទៅវិញនោះ ជាពិសេស គឺសត្រូវដែលកំណាច និងឃោរឃៅបំផុតនោះ ។ គេអាចគិតឃើញពីភាព ស្មាក់ស្មើរនៃគ្រីស្តបរិស័ទភាគច្រើន នៅពេលសម័យសព្វថ្ងៃនេះ ប្រហែល ជាអាចមានអារម្មណ៍បែបនោះ ចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ចាត់ ឲ្យទៅផ្សាយដំណឹងដល់ពួកខ្មែរក្រហម ។ ពួកគេបានប្រព្រឹត្តអំពើព្រៃផ្សៃ ជាទីបំផុតចំពោះគ្រួសារ និងអ្នកជិតខាងរបស់យើង ។ ពិតមែនហើយ ព្រះជាម្ចាស់មិនមានបំណងប្រាថ្នាចង់ឲ្យគេមានការរីកចំរើននោះឡើយ! គឺប្រាកដជាមានរឿងរ៉ាវអាក្រក់ៗព្យួរចំពីលើក្បាលគេ ដែលពួកគេសក្តិសម នឹងទទួលយក! ពិតមែនហើយ យើងមិនចាំបាច់ជួយធ្វើអ្វីឲ្យការនេះបាន សម្រេចចំពោះពួកគេឡើយ!

ប៉ុន្តែព្រះជាម្ចាស់ថែរក្សា សូម្បីតែមនុស្សកំណាចឃោរឃៅបែបហ្នឹង ក៏ព្រះអង្គថែរក្សាគេដែរ ហើយថែមទាំងព្រះអង្គបានចាត់បញ្ជូនព្យាការីរបស់ ព្រះអង្គឲ្យទៅប្រកាសដំណឹងឲ្យគេបានដឹងទៀតផង ។ លោកយ៉ូណាសមិន ព្រមយល់ស្របតាមព្រះជាម្ចាស់ ហើយក៏បានរត់គេចទៅ ទិសដៅផ្សេង ។

ការនេះនាំឲ្យយើងដឹងពីខ្លឹមសារទីពីរនៃកណ្ឌគម្ពីរនេះ ។ ជួនកាល មនុស្សគ្រប់រូប និងគ្រប់ទាំងរបស់សព្វសារពើស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ តែបែរជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ផ្ទាល់ទៅវិញទេ ដែលមិនស្តាប់ បង្គាប់ដល់ព្រះអង្គ ។ ព្រះជាម្ចាស់ធ្វើឲ្យ[៣] មានខ្យល់ព្យុះយ៉ាងខ្លាំង គឺខ្យល់ព្យុះ នោះព្រមស្តាប់បង្គាប់ព្រះអង្គ ដោយការច្របល់ទឹកសមុទ្រឲ្យមានរលកពុះ កញ្ជ្រោលយ៉ាងខ្លាំង ហើយក្រោយមកក៏ស្ងប់ឈឹងទៅវិញ (១:៤, ១១, ១៥)។

---

*[៣] ពាក្យដែលបន្ទី ។ ពាក្យបួនម៉ាត់នៅក្នុងចំណោមពាក្យទាំង១៤ជង់ នៅ ក្នុងភាសាហេព្រើរ នៅក្នុងកណ្ឌគម្ពីរយ៉ូណាសជំពូក១ (ក្នុងខ ៤, ៥, ១២, ១៥) ។*

ព្រះជាម្ចាស់[៤] បានចាត់តាំងឲ្យមានត្រីមួយយ៉ាងធំ មានវល្លិ មានដង្កូវ និងខ្យល់បក់នាំកំដៅមកពីទិសខាងកើតមក (២:១៧; ៤:៦-៨) ដែលត្រីនោះមកលេបវល្លិនោះក៏លាស់ឡើង ដង្កូវស៊ីវល្លិនោះ និងខ្យល់នោះបក់មកចំទិសដៅដែលព្រះអង្គតម្រូវឲ្យបក់ ។ នៅពេលដែលព្រះមានបន្ទូល[៥] ទៅកាន់ត្រីនោះ ត្រីក៏ក្អួរយ៉ូណាសចេញមក (២:១១) ។ នៅពេលដែលព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកនៅក្នុងទីក្រុងនីនីវេ តាមរយៈលោកយ៉ូណាស ពួកគេក៏ប្រែចិត្ត ។ មានតែម្នាក់គត់ដែលមិនស្តាប់បង្គាប់ព្រះអង្គ នោះគឺជាព្យាការីរបស់ព្រះអង្គនោះឯង ដែលបានរត់គេចទៅផ្លូវមួយផ្សេងទៀត (១:៣) និងរអ៊ូរទាំពីព្រះគុណរបស់ព្រះជាម្ចាស់ (៤:២-៣) ។

ជាពិសេសរាស្ត្រនៃសាសន៍ដទៃបានបង្ហាញថា មានការគោរពកោតខ្លាចព្រះជាម្ចាស់ខ្លាំងជាងហោរារបស់ព្រះជាម្ចាស់ នៅក្នុងសាច់រឿងនេះ ។ លោកយ៉ូណាហាក់បីដូចជាគ្មានស្មារតីសោះ នៅពេលដែលគាត់បានរត់គេចចេញពីព្រះយេហូវ៉ា ជាព្រះជាម្ចាស់នៃស្ថានសួគ៌ដែលបានបង្កើតសមុទ្រ និងផែនដី "គឺមានន័យថា ពេលនោះលោកយ៉ូណាសសំរាកលង់លក់យ៉ាងស្កប់ស្កល់នៅក្នុងពេលដែលគាត់កំពុងតែរត់គេចពីព្រះជាម្ចាស់នោះ ។ តែផ្ទុយទៅវិញពួកអ្នកសំពៅភ័យញ័ររន្ធត់ នៅពេលគេបានដឹងថាយ៉ូណាស

---

*[៤] ពាក្យមួយទៀតនេះ គឺជាពាក្យមិនសូវប្រើជាសាមញ្ញទេ ដែលគេបានប្រើ៤ដង នៅក្នុងកណ្ឌគម្ពីរយ៉ូណាស (១:១៧ [២:១ នៅក្នុងកណ្ឌ គម្ពីរហេព្រើរ] ៤:៦, ៧, ៨ បានបកប្រែហើយ "ផ្តល់ឲ្យ" នៅក្នុង NIV) ។ អត្ថន័យនៃការ "តែងតាំងនរណាម្នាក់នូវការទទួលខុស ត្រូវអ្វីមួយ" អាចឃើញនៅក្នុងពាក្យដែលបានលេចឡើងនៅក្នុងកណ្ឌគម្ពីរ ដានីយ៉ែល (១:៥, ១០, ១១; ២:២៤; ៤៩; ៣:១២; ៥:២៦) ។*

*[៥] គឺជាពាក្យធម្មតាដែលមានន័យថា "និយាយថា" ឬ"បញ្ចេញ សម្លេង" ប៉ុន្តែជួនកាលមានន័យថា "បញ្ជា" ។*

បានរត់គេចចេញពីនរណាមកនោះ (១:១០) ។ ពួកគេបានព្យាយាមយ៉ាងអស់ពីសមត្ថភាព ដើម្បីជួយសង្គ្រោះយ៉ូណាសឲ្យរួចពីក្តីមរណានៅក្នុងទឹកសមុទ្រនោះ នៅពេលទីចុងបំផុតពួកគេមានការស្ទាក់ស្ទើរយ៉ាងខ្លាំងក្នុងការគ្រវែងយ៉ូណាសបោះទៅក្នុងសមុទ្រដែលកំពុងមានរលកធំៗនោះ សមុទ្រក៏ស្ងប់ដោយបានបញ្ជាក់ពីសេចក្តីក្រោធរបស់ ព្រះជាម្ចាស់បានស្ងប់ដែរ ហើយពួកអ្នកសំពៅក៏ព្រមទទួលស្គាល់នូវព្រះអធិបតេយ្យភាពរបស់ព្រះអង្គ (១:១៤) ។ នៅពេលដែលសមុទ្រស្ងប់ស្ងាត់ទៅវិញ ពួកគេទាំងអស់គ្នាកោតខ្លាចដល់ព្រះយេហូវ៉ាយ៉ាងខ្លាំងដោយបានថ្វាយតង្វាយ និងបានបន់ស្រន់ដល់ព្រះអង្គ(១:១៦) ។ នៅពេលក្រោយមក ពេលដែលស្តេចរបស់ក្រុងនីនីវេបានឮពីសេចក្តីព្រមានរបស់លោកយ៉ូណាស ស្តេចអង្គនោះបានប្រែចិត្តនិងបានបញ្ជាឲ្យប្រជានុរាស្ត្រនៅក្នុងអាណាចក្ររបស់ព្រះអង្គឲ្យប្រែចិត្តដែរ ។ ទោះបីជាលោកយ៉ូណាសនិយាយថា គាត់កោតខ្លាចព្រះជាម្ចាស់[៦] "ព្រះយេហូវ៉ា ជាព្រះជាម្ចាស់នៃស្ថានសួគ៌ដែលបានបង្កើតផ្ទៃមេឃ និងផែនដី" ក៏ដោយចុះ តែពួកអ្នកសំពៅ និងអ្នកទីក្រុងនីនីវេជាសាសន៍ដទៃឯណោះវិញទេ ដែលពិតជាកោតខ្លាចដល់ព្រះជាម្ចាស់ពិតប្រាកដមែន ។

ការនេះមិនគ្រាន់តែមួយលើកប៉ុណ្ណោះទេ ដែលមានបញ្ជាក់នៅក្នុងបទគម្ពីរចំពោះសកម្មភាពរបស់អ្នកដែលជាសាសន៍ដទៃ កោតខ្លាចព្រះជាម្ចាស់ខ្លាំងជាងរាស្ត្ររបស់ព្រះជាម្ចាស់ទៅទៀត ។ លោក យូដា បានទទួលស្គាល់ថា នាងតាម៉ា បានប្រព្រឹត្តសុចរិតជាងគាត់ទៅទៀត (លោកុប្បត្តិ ៣៨:២៦) អ័ប៊ីម៉្មាឡិច បានស្តីបន្ទោសដល់អាប្រាហាំ (លោកុប្បត្តិ ២០:៩) មានមនុស្សជាច្រើនពីទិសខាងកើត និងទិសខាងលិចនឹងបានចូលមកក្នុង

---

៦ *ពាក្យនេះ បកប្រែថា "ថ្វាយបង្គំ" នៅក្នុងព្រះគម្ពីរ NIV នៅក្នុង ១៩គ*

នគរស្ថានសួគ៌ តែអស់មនុស្សទាំងនគរនោះនឹងត្រូវបោះចោលទៅក្នុងសេចក្តីងងឹតខាងក្រៅវិញ...(ម៉ាថាយ៨:១១) ។ ហេតុអ្វីបានជាអស់អ្នកដែលជួនកាលគេគិតថា ស្គាល់ព្រះជាម្ចាស់នោះប្រព្រឹត្តអាក្រក់ជាងអ្នកដែលយើងគិតថាគេមិនស្គាល់ព្រះនោះទៅវិញ?

ដូច្នេះការបដិសេធន៍ចោលរបស់លោកយ៉ូណាស ចំពោះសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលព្រះអង្គមានចំពោះសាសន៍ដទៃដែលជាសត្រូវរបស់គាត់នោះ គាត់បានបដិសេធមិនព្រមស្វែងរកនូវការផ្តល់ឱកាសឲ្យគេស្វែងរកនូវសេចក្តីសង្គ្រោះរបស់គេនោះ គឺបណ្តាលឲ្យគាត់ជួបនូវគ្រោះមហន្តរាយមួយធ្លាក់ដល់ក៏រិតធ្ងន់ធ្ងរមែនទែន ។ គាត់បានទៅកាន់ យ៉ូប៉េ[៧] ដោយចុះសំពៅ ចុះទៅបាតសំពៅដើម្បីសម្ងំដេក ចុះទៅបាតសមុទ្រ "ទៅឫសភ្នំទាំងឡាយ"[៨] ហើយនិងគាត់ត្រូវត្រីលេបបាត់ចូលក្នុងពោះ ។ គាត់ចាប់ផ្តើមវិលត្រឡប់មកវិញ នោះគឺដោយសារតែការប្រែចិត្តរបស់គាត់ នៅក្នុងជំពូក ២ ។

## ជំពូក២ : យ៉ូណាស វិលទៅរកព្រះជាម្ចាស់វិញ

នេះជាការអស្ចារ្យណាស់ដែលធ្វើឲ្យរាស្ត្ររបស់ព្រះជាម្ចាស់ប្រែចិត្តហើយអធិស្ឋាន ។ យ៉ូណាសបានគិតថា គាត់អាចពួនពីព្រះជាម្ចាស់បានដោយសាររត់ទៅទីក្រុងឆ្ងាយ ។ ព្រះជាម្ចាស់បានមានប្រតិកម្មតបវិញដោយបានធ្វើឲ្យគាត់ទៅពួនកាន់តែជ្រៅជាងអ្វីដែលគាត់គិតទៅទៀត ។ តើមាន

---

*[៧] សម័យសព្វថ្ងៃនេះឈ្មោះ ថា យ៉ាហ្វា ។ នេះមិនមែនជាកំពង់ផែដែលនៅជិតទីក្រុងរបស់លោកយ៉ូណាសឡើយ ប៉ុន្តែជាកន្លែងសំពៅ ធ្វើដំណើរផ្លូវឆ្ងាយសំចតនៅ ។ យ៉ូណាសរៀបចំខ្លួនដើម្បីរត់គេចឲ្យបានឆ្ងាយតាមដែលគាត់អាចធ្វើបាន ។*

*[៨] "ចុះទៅក្រោម ចុះទៅទីជម្រៅ" គឺគេប្រើនៅជំពូក១:៣(ពីរដង), ៥; ២:៧។*

អ្វីដែលពួនមានជ្រៅជាងក្នុងពោះត្រី ដែលហែលនៅក្រោមទឹករលកទៅទៀតនោះ? តែទោះជាយ៉ាងណាក៏ដោយការ "ពួន" នៅក្នុងកន្លែងជ្រៅបែបនោះ ធ្វើឲ្យយ៉ូណាសវិលមករកព្រះវិញដោយការអធិស្ឋាន ដែលដឹងពិតប្រាកដថា សូម្បីពីកន្លែងនោះព្រះជាម្ចាស់ក៏ព្រះអង្គអាចទតឃើញ និងស្តាប់ឮអ្វីដែលគាត់អធិស្ឋានដែរ ។ មិនដឹងជាយ៉ាងម៉េចទេ ចំណេះដឹងផ្នែកទេវសាស្ត្រចំពោះសេចក្តីសព្វញ្ញូញាណ និងសព្វវត្តមានរបស់ព្រះជាម្ចាស់ស្រាប់តែប្តូរផ្លាស់ទៅវិញ ។ ចំពោះការរត់គេចទៅ តើសុស ព្យាការីរូបនេះ គឺបានប្រព្រឹត្តចំពោះការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ឥឡូវនេះគាត់សន្យាថា៖ "អ្វីដែលទូលបង្គំបន់ ទូលបង្គំនឹងលាបំណាន់របស់ទូលបង្គំផង" (២:១០)។

តើអ្វីដែលធ្វើឲ្យមានការផ្លាល់ប្តូរចិត្ត និងសកម្មភាពនោះ? គឺជាបញ្ហា ។ "ទូលបង្គំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយព្រោះទុក្ខលំបាករបស់ទូលបង្គំ...នៅក្នុងពោះនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយទ្រង់បានឮសម្លេងរបស់ទូលបង្គំដែលបានអំពាវនាវសុំឲ្យព្រះអង្គជួយ" (២:៣) ។ បញ្ហានោះឯងដែលនាំឲ្យគាត់វិលបែរមករកព្រះជាម្ចាស់វិញ ។ ស្ថានភាពរបស់យ៉ូណាសមិនមែនជារឿងចម្លែកឡើយ ។ ព្រះបាទដាវីឌក៏ទទួលស្គាល់ថា៖ "កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ នោះទូលបង្គំបានវង្វេងទៅ តែឥឡូវនេះទូលបង្គំកាន់តាមព្រះបន្ទូលរបស់ព្រះអង្គ"[៩] ។ គំរូនៃប្រវត្តិសាស្ត្ររបស់ប្រទេសអ៊ីស្រាអែលដែលតម្រូវឲ្យមានការរងទុក្ខវេទនា ដើម្បីធ្វើឲ្យរាស្ត្រអ៊ីស្រាអែលនៅជាប់ជាមួយព្រះជាម្ចាស់[១០] ហើយតម្រូវឲ្យមានការរងទុក្ខវេទនានៅថ្ងៃអនាគតដែលជាពេលរងទុក្ខនោះ ដើម្បីបង្ហាញឲ្យប្រជាជាតិ

---

*[៩] ទំនុកតម្កើង ១១៩:៦៧*

*[១០] ចៅហ្វាយ ១០:៩-១០*

នោះ“ងាកបែរមករកអញ អ្នកដែលគេបានចាក់ ហើយយំសោក”[១១] ដែល ស្វាគមន៍ព្រមទទួលព្រះយេស៊ូជាព្រះមេស្ស៊ីរបស់ខ្លួននៅពេលចុងក្រោយ ។

ប៉ុន្តែហេតុអ្វីត្រូវចាំបាច់រង់ចាំឲ្យមានបញ្ហា? ហេតុអ្វីបានជាមិនស្វែងរកការបំរើព្រះជាម្ចាស់នៅពេលដែលមិនមានបញ្ហាទៅ? ពេលនោះប្រហែលព្រះអង្គមិនបណ្តាលឲ្យយើងមានបញ្ហាទេ ។ នេះជាគំនិតដែលបង្កប់ពីក្រោយកំណ្ឌគម្ពីរ ១កូរិនថូស ១១:៣១ ដែលថា “បើសិនជាយើងរាល់គ្នាពិចារណាមើលក្នុងខ្លួនយើង នោះយើងមិនត្រូវជាប់ជំនុំជំរះទេ” ព្រះជាម្ចាស់ “មិនធ្វើទុក្ខ ឬឲ្យមនុស្សជាតិត្រូវវេទនាដោយស្ម័គ្រពីព្រះហឫទ័យទេ”[១២] ហេតុផលតែមួយគត់ដែលព្រះអង្គដាក់ទណ្ឌកម្មយើង (ទោះបីមិនពេញលេញក៏ដោយ) ដ្បិតអំពើបាបរបស់យើង ហើយចង់ឲ្យយើងវិលបែរមករកផ្លូវត្រឹមត្រូវវិញ ។ ប៉ុន្តែ ហេតុអ្វីក៏មិនដើរនៅក្នុងផ្លូវត្រូវតាំងពីដើមដំបូងទៅ? ហេតុអ្វីបានជាយើងត្រូវឆ្លងកាត់នូវការរងទុក្ខឈឺចាប់ ដែលបង្ខំយើងឲ្យធ្វើនូវអ្វីដែលយើងអាចធ្វើបានតាំងពីដំបូងដោយសេរីឥតមានអ្នកណាបង្ខំ និងយើងអាចធ្វើដោយសប្បាយរីករាយទៀត ផងនោះ?

ប៉ុន្តែយ៉ាងហោចណាស់លោកយ៉ូណាសបានវិលបែរមករកព្រះវិញ ។ នោះឯងជាគំរូមួយសំរាប់យើង ។ នៅពេលដែលព្រះជាម្ចាស់ប្រដៅតម្រង់យើង ចូរឲ្យយើងរៀននូវមេរៀនដ៏ចាំបាច់នោះ ហើយគួរតែដឹងខ្លួនជាជាងបន្តនូវការប៉ះបោរប្រឆាំងនឹងព្រះអង្គ ឬក៏ធ្លាក់ទឹកចិត្ត និងបោះបង់ចោលព្រះអង្គនោះឡើយ ។ យ៉ូណាសគូសបង្ហាញពីគោលគំនិតរបស់កំណ្ឌគម្ពីរហេព្រើរ ១២:៤-១៣ ។ គឺជារឿងមួយគួរឲ្យខ្មាសដែលតម្រូវឲ្យគាត់បាត់បង់លុយថ្លៃសំពៅ និងរបស់របរដែលគាត់មានយកមកជាមួយនៅពេល

---

[១១] *សាការី ១២:១០ បញ្ហារបស់អ៊ីស្រាអែលនោះ នៅត្រង់ ១ ៣*
[១២] *បរិទេវ ៣:៣៣*

ជិះសំពៅនោះ ដោយមិនបាននិយាយអ្វីបន្តិចអស់រយៈពេលបីថ្ងៃ វង្វេងនៅក្នុងពោះត្រីដែលចង្អៀតនោះ តែយ៉ាងហោចណាស់គាត់បានរៀនមេរៀនមួយដែលគួរចងចាំ ។

មនុស្សខ្លះបដិសេធមិនព្រមជឿរឿងរបស់លោកយ៉ូណាស ពីព្រោះជារឿងហួសនិស្ស័យនឹងជឿ ដែលមនុស្សម្នាក់ត្រូវត្រីមួយដ៏ធំលេបចូលទៅក្នុងពោះហើយ នៅតែមានជីវិតរស់នៅទៀតនោះ ។ អត្ថបទជាភាសាហេព្រើរមិនបានរៀបរាប់ពីចំណុចជាក់លាក់ណាមួយនោះឡើយ តែគ្រាន់តែប្រើពាក្យ "ត្រី"[១៣] ។ មិនថាតើជាត្រី ឬត្រីបាឡែននោះឡើយ មានឯកសារចងក្រងនៅសម័យទំនើបនេះ ដែលថាមានពួកអ្នកសំពៅបានទទួលរងគ្រោះដោយសារត្រីលេប ហើយនៅមានជីវិតរស់នៅ បន្ទាប់ពីមានការជួយសង្គ្រោះពីពួកអ្នកសំពៅដូចគ្នាអស់រយៈពេលជាច្រើនម៉ោងក្រោយមកនោះ ។

## ជំពូកបី : លោកយ៉ូណាសចេញទៅដោយព្រោះបុព្វហេតុព្រះជាម្ចាស់

យ៉ូណាសត្រូវខាតបង់ពេលវេលា បាត់បង់របស់របរ និងត្រូវរងឈឺចាប់ផ្នែករាងកាយ ។ ប៉ុន្តែគាត់មិនបានទទួលចំណេញអ្វីបន្តិចសោះ ។ បន្ទាប់ពីរឿងរ៉ាវនៃបញ្ហា និងការបាត់បង់ទាំងអស់របស់គាត់មក គាត់បានស្តាប់ព្រះបេសកកម្មដដែល គឺជាបេសកកម្មដែលព្រះជាម្ចាស់ប្រើគាត់ពីលើកមុននោះ [១៤] ។

---

*[១៣] ពាក្យនេះ ពីរដង នៅក្នុងជំពូក១:១៧ (ហេព្រើរ ២:១) ហើយ និង ម្តង នៅក្នុងជំពូក ២:១០ (ហេព្រើរ ២:១១) នៅក្នុងជំពូក ២:១ (ហេព្រើរ ២:២)*

[១៤] קוּם לֵךְ אֶל־נִינְוֵה הָעִיר הַגְּדוֹלָה וּקְרָא עָלֶיהָ/אֵלֶיהָ 1:2; 3:2. The identity of the words [עָלֶיהָ in 1:2 is often interchangeable with אֵלֶיהָ in 3:2] is lost in the NIV translation.

គ្មានបានអ្វីដែលចំណេញឡើយ នៅពេលដែលរាស្ត្ររបស់ព្រះជាម្ចាស់តតាំងនឹងបំណងព្រះហឫទ័យរបស់ព្រះអង្គនោះ ។ ជារឿយៗ ព្រះជាម្ចាស់នាំគេកាត់ទឹកជ្រៅ វិលត្រឡប់មកកន្លែងដែលគេចាប់ផ្តើមចេញដំណើរនៅពេលដំបូងនោះ ។ នេះជាបទពិសោធន៍ដែលប្រជារាស្ត្រអ៊ីស្រាអែលទទួល បន្ទាប់ពីរយៈពេលចេញពីប្រទេសអេស៊ីព្ទ ហើយដើរកាត់វាលរហោស្ថាននោះ ។ ព្រះជាម្ចាស់បាននាំរាស្ត្ររបស់អង្គមកដល់កន្លែងមួយឈ្មោះ កាដេស បានា ហើយព្រះអង្គបង្គាប់គេឲ្យធ្វើសង្គ្រាមជាមួយមនុស្សដែលខ្លាំងរឹងមាំជាងពួករាស្ត្រនោះ ហើយបន្ទាប់មកគេត្រូវដណ្តើមយកទឹកដីនោះមកធ្វើជាទឹកដីរបស់ខ្លួន ។ ប្រជាជាតិនោះមិនបានជឿដល់ព្រះអង្គនិងព្រមស្តាប់បង្គាប់ដល់ព្រះអង្គឡើយ ។ ដោយហេតុនោះហើយទើបព្រះអង្គវាយផ្ចាល់ប្រជាជាតិនេះ គឺត្រូវដើរត្រេចរង្កាត់អស់រយៈពេល៤០ឆ្នាំនៅក្នុងវាលរហោស្ថាន គឺគេត្រូវចំណាយពេលឥតប្រយោជន៍ បាត់បង់របស់របរដែលជាសម្បត្តិរបស់ខ្លួន រងទុក្ខវេទនាផ្នែករាងកាយ ។ នៅពេលចុងក្រោយព្រះជាម្ចាស់នាំគេទៅចំណុចចូលក្នុងទឹកដីសន្យាមួយកន្លែងទៀត ប៉ុន្តែព្រះអង្គនៅតែបង្គាប់ដល់គេនូវព្រះរាជបង្គាប់សំខាន់ដដែលនោះគឺឲ្យចូលទៅធ្វើសង្គ្រាមជាមួយពួកមនុស្សខ្លាំងពូកែ ហើយដណ្តើមយកទឹកដីរបស់គេយកមកធ្វើជាទឹកដីរបស់ខ្លួន ។ រាប់សតវត្សក្រោយមករាស្ត្រអ៊ីស្រាអែលបានបដិសេធព្រះយេស៊ូដែលគេធ្លាប់ចាត់ទុកជាព្រះមេស្ស៊ីរបស់គេនោះ ។ ប៉ុន្តែព្រះជាម្ចាស់មិនបានផ្លាស់ប្តូរព្រះរាជផែនការដ៏ជ្រាលជ្រៅសំរាប់ព្រះយេស៊ូរបស់ព្រះអង្គ ឬ សំរាប់ពួកគេ ដោយព្រោះតែការគ្មានជំនឿរបស់គេនោះឡើយ ។ អ៊ីស្រាអែលបានខាតបង់ពេលវេលា បាត់បង់ធនធាននិងរងឈឺចាប់ផ្នែករាងកាយអស់រយៈរាប់សតវត្ស (ហើយនិងរងទុក្ខកាន់តែខ្លាំងឡើងទៀត នៅក្នុងរយៈពេលនៃការរងទុក្ខ ) ។ ប៉ុន្តែអ៊ីស្រាអែលមិនបានទទួលចំណេញអ្វីពីការដែលខ្លួនបះបោរទាស់ទទឹងជាមួយព្រះជាម្ចាស់

នោះឡើយ តែបែរជាទទួលរងនូវការឈឺចាប់ ដែលជាហេតុរាស្ត្រនេះទៅដល់កន្លែងដែលរាស្ត្រនេះ ត្រូវជួបនឹងការផ្តល់ឲ្យនូវក្រឹត្យច្បាប់របស់ព្រះមេស្ស៊ីនៃព្រះយេស៊ូ ប៉ុន្តែនៅពេលនេះជាទីចុងបំផុតបានថែងថា៖ "មានពរហើយអស់អ្នកណាដែលមកដោយនូវព្រះនាមព្រះអម្ចាស់" [១៥]

នៅក្នុងឱកាសទីពីររបស់គាត់ យ៉ូណាស "ព្រមស្តាប់បង្គាប់ព្រះបន្ទូលព្រះយេហូវ៉ា ហើយក៏ចេញទៅ" (៣:៣) ។ ពីព្រោះលោកយ៉ូណាសត្រូវប្រកាសយ៉ាងញឹកញាប់ ក្នុងខណៈដែលគាត់ចូលនៅក្នុងទីក្រុងនីនីវេ ដំណើរទស្សនកិច្ចរបស់គាត់នោះតម្រូវការរយៈពេលបីថ្ងៃ ។ ប្រហែលចំពោះការកត់សំគាល់នៃពេលវេលានោះអាចមានន័យថា រួមបញ្ចូលទាំងនៅជាយក្រុងនីនីវេផង ។ មិនថាមានអ្វីកើតឡើងនោះឡើយ គាត់ប្រកាសព្រះរាជសាររបស់ព្រះជាម្ចាស់អំពីសេចក្តីជំនុំជំរះដែលបំរុងនឹងកើតឡើង ចំពោះអ្នកក្រុងនីនីវេ។

ចំពោះមនុស្សដែលបានរស់រានមានជីវិតរួចពីពោះត្រីអស់រយៈពេលរាប់ម៉ោងនោះ យើងសង្កេតឃើញស្បែកឡើងពណ៌សស្លេក ឬក៏មានពណ៌សរាំងលាយបៃតង ព្រោះដោយសារជាតិអាស៊ីដនៅក្នុងក្រពះត្រីទើបធ្វើឲ្យមានពណ៌ដូច្នោះ ។ សក់របស់ជនរងគ្រោះអាចរុះ ។ នៅក្នុងឆ្នាំ ៧៤៥ មុនគ្រីស្តសករាជ នៅក្នុងអាណាចក្រអាស៊ីរីមានសួរ្យគ្រាស ព្រឹត្តិការណ៍បែបនោះមនុស្សមួយចំនួនដែលជឿលើព្រេងសំណាងនោះ គេថាជាប្រផ្នូលអាក្រក់។ ដូចដែលលោកអ្នកសំគាល់ឃើញខាងដើមហើយថា នៅក្នុងឆ្នាំ ៧៨០-៧៤៥ មុនគ្រីស្តសករាជរួមបញ្ចូលទាំងការធ្លាក់ចុះ និងការគំរាមកំហែងផ្នែកយោធា។[១៦] ជនចម្លែកមុខដែលមានសម្បុរបៃតង ហើយដុះសក់រុយៗ

---

*[១៥] ម៉ាថាយ ២៣:៣៧-៣៩*

*[១៦] អាណាចក្រអាស៊ីរី ទទួលរងនូវការប្រឆាំងតបតពីពួកកុលសម្ព័ន្ធនៅតាមតំបន់ភ្នំពីភូមិភាគខាងត្បូង ដែលបានចូលមកលុកលុយនៅ ជុំវិញ ១៥០គីឡូម៉ែត្រនៃទីក្រុងនីនីវេ ។*

(មិនស្លូវមានសក់)នោះ គឺជាអ្នកដែលមានប្រផ្នូលអាក្រក់កាលពីសម័យនោះ នៅពេលដែលព្រះអាទិត្យត្រូវរាហូចាប់នោះ មានន័យថាអធិរាជត្រូវរលំរលាយ មនុស្សម្នាកាលនោះ គេចាត់ទុករឿងនោះជារឿងមួយដែលគេជឿយ៉ាងខ្លាំង ។

ប៉ុន្តែមិនដឹងមកពីមូលហេតុអ្វីបានជាមនុស្សទូទាំងទីក្រុងទទួលបាននូវការប្រែចិត្ត ។ ស្តេចបានចេញរាជក្រឹត្យដល់បណ្តាជនគ្រប់រូបតមអាហារ សូម្បីតែសត្វក៏ត្រូវតមចំណីដែរ ហើយបញ្ជាឲ្យមនុស្សទាំងអស់បញ្ឈប់នូវការប្រព្រឹត្តិអំពើអាក្រក់របស់ពួកគេ ហើយឲ្យគេអំពាវនាវដល់ព្រះជាម្ចាស់ ។ គឺជាការឆ្លើយតបមួយដែលប្រកបដោយវិចារណញាណ នៅក្នុងប្រវត្តិសាស្ត្រសាសនា ។

ព្រះជាម្ចាស់គាប់ព្រះហឫទ័យយ៉ាងក្រៃលែង ។ នៅពេលដែលព្រះអង្គទតឃើញការកែប្រែចិត្តរបស់គេនោះ ព្រះអង្គមានព្រះហឫទ័យក្តួលអាណិតចំពោះគេ ហើយព្រះអង្គក៏លុបចោលនូវការដាក់ទណ្ឌកម្មនោះចោលចេញ ។

សេចក្តីក្តួលអាណិត(ជាភាសាសំស្ក្រឹតថា ករុណា) គឺជាចំណុចសំខាន់របស់លទ្ធិពុទ្ធនិយម ។ រឿងរ៉ាវនៃការត្រាស់ដឹងរបស់ព្រះពុទ្ធបានបង្រៀនយើងឲ្យដឹងថា បន្ទាប់ពីការចាប់ជាតិកំណើតមក សិទ្ធត្ថកុមារមានសេចក្តីមេត្តាករុណាចំពោះសត្វលោកទាំងឡាយ ដោយហេតុតែគេទទួលរងកម្មដោយមិនបានដឹងអ្វីទាំងអស់នោះ ។ ព្រះពុទ្ធចែករំលែកនូវការត្រាស់ដឹងនូវគតិបណ្ឌិតដែលព្រះអង្គទើបនឹងរកឃើញនៅក្នុងលោកយើងនេះ ដែលសន្យាថា៖ "ទោះបីជារូបសត្វលោកដែលមានញាណយ៉ាងច្រើនរាប់មិនអស់យ៉ាងណាក៏ដោយ ក៏អាត្មាអញសន្យាថានឹងជួយសង្គ្រោះគេទាំងអស់ដែរ" ដើម្បីត្រាស់ដឹងនោះ រួមបញ្ចូលទាំងការមានសេចក្តីមេត្តាករុណាចំពោះសត្វលោកទាំងអស់ ហើយនិងស្វែងរកផ្លូវក្នុងការបង្រួបបង្រួមគេជាមួយគ្នាដោយការត្រាស់របស់ខ្លួន ។ គតិបណ្ឌិត និងសេចក្តីមេត្តាករុណា នោះមិន

អាចបំបែកពីគ្នាបាន ។ ពីព្រោះ តែខ្លឹមសារបស់ពាក្យនោះ សេចក្តីមេត្តាករុណានៅក្នុងលទ្ធិពុទ្ធនិយម ដើរស្របគ្នានឹងសេចក្តីស្រឡាញ់នៅក្នុងជំនឿរបស់គ្រីស្តបរិស័ទ ។

ប៉ុន្តែដូចបានជំរាបជូនខាងលើរួចហើយ ព្រះជាម្ចាស់ព្រះអង្គក៏មានព្រះហឫទ័យក្តួលអាណិតដែរ ។ សេចក្តីក្តួលអាណិតរបស់ព្រះអង្គនោះហើយ ដែលធ្វើឲ្យព្រះអង្គព្រមានដល់អ្នកទីក្រុងនីនីវេ តាមរយៈការងាររបស់លោកយ៉ូណាសកាលពីដំបូង ។ នៅពេលដែលគេព្រមកែប្រែចិត្ត សេចក្តីក្តួលអាណិតរបស់ព្រះអង្គដែលធ្វើឲ្យព្រះអង្គ លែងចង់ដាក់ទណ្ឌកម្មចំពោះការដែលព្រះអង្គបានព្រមានដល់គេថានឹងជំនុំជំរះដល់គេនោះចោលចេញ" ។ ព្រះជាម្ចាស់បានអត់ទោសឲ្យគេ អ្នកក្រុងនីនីវេបានរួចខ្លួន ទំនាយទាំងប៉ុន្មានដែលលោកយ៉ូណាសថ្លែងប្រាប់គេនោះ បែរជាមិនបានសម្រេចទៅវិញ ។

## ជំពូកបួន : តើលោកយ៉ូណាសនៅជាមួយព្រះជាម្ចាស់ឬ?

ប៉ុន្តែតើអ្នកបំរើរបស់ព្រះជាម្ចាស់រួមចំណែកក្នុងសេចក្តីមេត្តាករុណានោះដែរឬ? តើលោកយ៉ូណាសអបអរនឹងការដែលព្រះជាម្ចាស់ព្រមលើកលែងទោសឲ្យអ្នកក្រុងនីនីវេ ឬក៏អ្នកស្នេហាជាតិសុខចិត្តឈរមើលការចុះខ្សោយនៃខ្មាំងសត្រូវរបស់ព្រះអង្គ? តើយ៉ូណាសនៅតែមានមោទនភាពជាអ្នកជាតិនិយមដែលធ្វើឲ្យគាត់រត់គេច ជាជាងការដែលគាត់ត្រូវប្រកាស ឬ តើគាត់ព្រម"ទៅតាមផែនការព្រះ" និងព្រមរួមចំណែកក្នុងសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ក្នុងការជួយដល់មនុស្សដែលកំពុងបាត់បង់?

នៅក្នុង ៤ មួយ ផ្តល់ចម្លើយឲ្យយើងគឺថា៖ "លោកយ៉ូណាសមិនសប្បាយចិត្តឡើយ និងថែមទាំងខឹងទៀតផង" គឺ គាត់ចង់ស្លាប់ ។

ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យ ចំពោះការដោះស្រាយបញ្ហាដោយ

ប្រើសេចក្ដីស្លាប់មកជំនុំជំរះប៉ុន្មានទេ ដូចមនុស្សនៅក្នុងក័ណ្ឌគម្ពីរ នេះហាក់ដូចជាព្យាយាមទំរកសេចក្ដីស្លាប់នោះឡើយ ។ ព្រះអង្គជា "ព្រះដែលមានព្រះទ័យមេត្ដាករុណា និងសុភាពស្លូតបូត យឺតនឹងខ្ញាល់ និងមានសេចក្ដីស្រឡាញ់យ៉ាងពេញបរិបូណ៌ ព្រះអង្គជាព្រះដែលមិនងាយនឹងបញ្ជូនវិនាសកម្មទៅលើអ្នកណាឡើយ"[១៧] ។ ព្រះអង្គនឹងបង្ហាញនូវសេចក្ដីសុភាពទន់ភ្លន់ជួយសង្គ្រោះហោរារបស់ព្រះអង្គពីសេចក្ដីស្លាប់ នៅពេលដែលហោរានោះព្រមបង្វែរអ្នកក្រុងនីនីវេឲ្យវិលបែរមករកព្រះវិញ ។ ព្រះអង្គនឹងមិនអនុញ្ញាតឲ្យមនុស្ស នៅតែបន្ដប្រព្រឹត្តទាស់ទទឹងនឹងព្រះអង្គ ដោយមិនបានធ្វើការព្រមានចំពោះការដែលគេបះបោរ និងការដែលគេត្រូវទទួលនូវសេចក្ដីជំនុំជំរះនោះឡើយ ។ ដោយហេតុថាយ៉ូណាសមិនទំនងជាស្ដាប់តាមព្រះបន្ទូលនោះ ព្រះជាម្ចាស់បង្វែរទៅជាមេរៀនដែលមានវត្ថុតាងទៅវិញ ដូចជានៅក្នុងជំពូកមួយ ។

យ៉ូណាសប្រហែលជាចូលទៅក្នុង ក្រុងនីនីវេពីទិសខាងលិច ដោយបានធ្វើដំណើរកាត់ទីក្រុងនៅពេលដែលគាត់អធិប្បាយព្រះបន្ទូលរបស់ព្រះអង្គនោះឯង ហើយក៏បានទៅជាយក្រុងខាងកើត ។ ពេលដែលចាកចេញពីទីក្រុង គាត់បានអង្គុយខាងក្រៅទីក្រុងដោយសង្ឃឹមចង់ឃើញទីក្រុងនោះទទួលរងនូវការបំផ្លាញ ។ វត្ថុស្ដីពីវល្លិ ដង្កូវ និងខ្យល់ជំនោរ

---

*[១៧] ៤:២ នៅក្នុងខនេះ យ៉ូណាសបានដកស្រង់ផ្នែកសំខាន់ដែលព្រះជាម្ចាស់ពណ៌នាពីព្រះអង្គផ្ទាល់ដែលព្រះអង្គបានផ្ដល់ឲ្យទៅលោកម៉ូសេ ក្នុង និក្ខមនំ ៣៤:៦-៧ និង លើកមកនិយាយម្ដងទៀតនៅក្នុងគម្ពីរជេន គណនា ១៤:១៨ នេហេមា ៩:១៧; ទំនុក ៨៦:១៥; ១០៣:៨; ១៤៥:៨; និង យ៉ូអែល ២:១៣ ។ គាត់កំពុងតែមិនព្រមទទួលស្គាល់ចំណុចសំខាន់នៃ បុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ និងភ្លេចថាខ្លួនគាត់ផ្ទាល់មានទទួល គុណប្រយោជន៍ពីការអត់ទោសរបស់ព្រះជាម្ចាស់ដែរ ។*

ពីទិសខាងកើត បានធ្វើឲ្យយ៉ូណាសខឹងជាលើកទីពីរ រហូតធ្វើឲ្យគាត់ចង់ស្លាប់ទៀត ។ វល្លិស្វិតនោះបើកឱកាសឲ្យព្រះជាម្ចាស់បង្ហាញពីចំណុចដែលព្រះអង្គចង់បង្រៀនដល់យ៉ូណាសវិញ ។

យ៉ូណាសគិតខ្វល់ខ្វាយយ៉ាងខ្លាំងចំពោះវល្លិនោះ ។ គាត់ឲ្យតម្លៃវល្លិនោះ និងសប្បាយរីករាយដោយព្រោះឃើញវល្លិនោះដុះនៅទីនោះ[១៨] នេះជាការពិត ទោះបីជាយ៉ូណាសមិនដាំ ឬមិនស្រោចទឹកក៏ដោយចុះ ។ នៅពេលដែលវល្លិនោះងាប់ គាត់មិនសប្បាយចិត្តឡើយ ។ តែផ្ទុយទៅវិញព្រះជាម្ចាស់ជាអ្នកបង្កើតមនុស្សដែលរស់នៅក្នុងទីក្រុងនីនីវេ ។ ចំនួនមនុស្សទាំងអស់នេះសរុបទៅ ១២០,០០០នាក់ និងរួមទាំងសត្វយ៉ាងច្រើនសន្ធឹកទៀតនោះ ដែលមានតម្លៃសរុបលើសពីវល្លិមួយដើមទៅទៀត ។ ចំពោះការផ្ទុយគ្នានេះ តើលោកយ៉ូណាសអាចយល់ឃើញពីព្រះហឫទ័យខ្វល់ខ្វាយរបស់ព្រះជាម្ចាស់[១៩] ចំពោះអ្នកក្រុងនីនីវេវិញទេ ដោយហេតុថាការស្លាប់តែហោងរបស់អ្នកទីក្រុងនោះព្រះអង្គមិនគាប់ព្រះហឫទ័យឡើយមែនទេ? តើយ៉ូណាសព្រមប្រែចិត្តគំនិតចង្អៀតចង្អល់ រឹងរូសប្រកាន់ជ្រុល និងព្រមរួមចំណែកជាមួយការខ្វល់ព្រួយដែលមេត្តាករុណាដល់មនុស្សលោក

---

*[១៨] សីតុណ្ហភាពកំរិតខ្ពស់បំផុតរដូវក្តៅ ក្នុង ម៉េសូប៉ូតាមី មានកំដៅ ៤៣ អង្សា ។ នៅក្នុង"រដូវខ្យល់បក់" មកពីទិសខាងកើត សីតុណ្ហភាពឡើង ដល់ ៨-១២ អង្សា លើសពីចំនួនមធ្យមភាគ ។ កំដៅដុតរោលជាតុ សំណើមនៅក្នុងលំហ ហេតុដូច្នេះស្បែកមនុស្សម្នាក់ត្រូវឡើងតឹង ។ នៅក្នុងរដូវខ្យល់បក់មនុស្សម្នាងាយនឹងមានអារម្មណ៍មួម៉ៅ ហើយនិងប្រញាប់នឹងដើររកជំរកជ្រក ។ គឺជាងាយយល់ណាស់ ដែលយ៉ូណាសឲ្យតម្លៃលើដើមវល្លិមួយដើម ដែលផ្តល់ម្លប់ឲ្យគាត់នោះ ។*

*[១៩] ពាក្យដដែលនោះ ( អាណិត, មើលទៅដោយមានចិត្តក្តួលអាណិត) គេយកពាក្យនេះទៅប្រើនៅក្នុងការខ្វល់ខ្វាយរបស់លោកយ៉ូណាស ចំពោះដើមវល្លិនិង ការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់ ចំពោះអ្នកទីក្រុងនីនីវេ ។*

ជាទូទៅរបស់ព្រះជាម្ចាស់ឬអត់?

កណ្ឌគម្ពីរនេះបញ្ចប់ដោយសំណួរបែបនេះ ។ យើងមិនបានដឹង តើយ៉ូណាសឆ្លើយតបមកយ៉ាងណានោះទេ ។ សំណួរនេះប្រហែលជាល្អ ពីព្រោះវាកំពុងប្រឈមមុខជាមួយអ្នកអានគ្រប់គ្នា ។ តើខ្ញុំត្រូវធ្វើអ្វីចំពោះ មនុស្សដែលកំពុងវង្វេងបាត់បង់ហើយត្រូវរងនូវសេចក្ដីជំនុំជំរះរបស់ព្រះ ជាម្ចាស់នោះ? តើយើងត្រូវទប់ចិត្តរបស់យើង ហើយជួយទាំងទើស ទាល់ឬយ៉ាងណា? ឬក៏ត្រូវរួមចំណែកដោយសេចក្ដីស្រឡាញ់ ហើយនិង សេចក្ដីមេត្តាករុណាដែលផុលចេញមកពីព្រះគុណ និងការឈ្វេងយល់ ហើយធ្វើការបបួលពួកអ្នកកំពុងវង្វេងបាត់ឲ្យគេចពីផ្លូវអាក្រក់របស់គេទៅ?

HONEYCOMB 3/1 (January 2002): 98–102



*Debbi MAHER*

# Meet Yourng Soth



*YOURNG Soth*

In 1946 a faithful Christian woman in Kompong Thom named Touch Hin gave birth to a son, naming him Yourng Soth. The neighbors looked down on the family because of their beliefs, and excluded them from most areas of community life.

There were no pastors or churches at that time in Kompong Thom, although occasionally a pastor went down to Kadam Ha village in Khum Chhouk Kasarch Baray district. Therefore his mother took him to attend the annual conference at Takmau Bible School in Phnom Penh. Sometimes his father would take him to the local wat. Although Yourng Soth was thus raised in a home with Christian influences and was familiar with many Bible stories and spiritual songs, he did not yet believe. His mother would faithfully pray that one day he would become a strong leader in the Christian church. He would hear those prayers and consider it highly unlikely.

After high school Soth went to Kompong Cham to study. He was excited to be on his own together with other youth, and to finally be free of the "Christian family" stigma. Although his friends were typical college students looking for thrills and excitement, his mother's influence somehow led him to live a responsible and restrained college life.

After finishing school in 1968 he married Kang Koeung. The marriage had been arranged by Soth's mother, who was pleased that Koeung was a Christian.

Soth soon left to begin his government-issued rubber-manufacturing job in Ratanakiri. That malaria-plagued province proved a difficult place to live, and the job itself was hard. He was not happy and decided to walk out on his contract—a dangerous move to make.

He managed to find a taxi heading back to Kompong Thom. When the taxi approached one of the checkpoints, the driver asked him to get out, circle around, and meet them up ahead. Soth would have needed travel permission forms, as contract workers were expected to remain in their work locale except during certain holidays. But the driver did not wait for him. So Soth was forced to travel out of sight in a dense and dangerous forest, infested with tigers, snakes, and other sinister creatures, for nearly one full morning. He was petrified. His fear of death turned this into a dreadful day.

Soth stripped off his hat and shoes and knelt down and cried out to God for forgiveness. He promised to serve God if he lived, and pleaded that God would receive him if he died. A great peace enveloped him, and Soth suddenly realized that this moment was the answer to his mother's prayers. It also marked the beginning of his seeing God's grace and provision in his life.

He put on his hat and shoes and began walking out of the forest—no longer afraid, no longer alone. In ten minutes he came to a road. Rolling toward him was a man on a bicycle. Soth simultaneously felt relieved and suspicious. This person might know that he was fleeing and have him arrested. He wanted to ask if he had been following him, but did not. The man offered Soth a ride, and told him he had no reason to fear. Soth still felt uneasy, but grew amazed that as they talked the man would answer his questions before Soth asked them as

if the man were anticipating them. This was reassuring. They rode for hours.

The mysterious stranger spoke of the various modes of transportation up ahead. He assured Soth that should the taxi be unavailable or refuse to take him, then Soth would be welcome to stay at his place for the night. He pointed to a beautifully painted house not far away. It was clear that he was a man of wealth.

Then the bicycler pointed to a waiting taxi—the same that had stranded him before! "Go and ask if they will allow you to ride with them," said the man. Soth dismounted and dashed off to the taxi, which had stopped for repairs. When he reached it, the taxi was fixed. Immediately the other passengers pushed him in without giving him a chance to say goodbye. The driver explained that he had been forced to leave without Soth because the security officers would have shot at the taxi had they seen the driver pick up a man without papers. Soth felt so sorry for not being able to say goodbye to the man on the bike and thank him. To his amazement, the man was nowhere in sight and the house did not exist! He was amazed in his heart and he thought that man must be God's angel.

Before coming to Phnom Penh in 1969, Soth and his wife did some farming in Kompong Thom. This was difficult at first because he was an inexperienced student. But despite opposition, theft of crops, and ridicule because of their faith, his family learned how to grow various kinds of crops. This was a bittersweet period, as on the one hand they watched the Lord miraculously bless their harvest, but on the other Kang Koeung's mother passionately opposed her daughter's marriage to a Christian. She hated Christians. She threatened to take all of her daughter's possessions if she did not leave her husband and renounce her faith. Koeung decided to return everything her mother had ever given her, (such as necklaces, bangles, *hole,* and *pharmourng* [two kinds of Cambodian cloth]) and trust fully in the Lord for her needs.

In 1970 Yourng Soth attended Bethany International Church. Norman and Marie Ens were missionaries there and influenced him greatly. In 1972, he began a three-year course of study at the Takmau Bible College. Soth later became an assistant to the pastor in Zarephath

church, helping with the youth and evangelism. By now there were many churches in Cambodia, as well as faithful missionaries such as Andy Bishop (WVI), Mel Gravan, Jean Hall, Alice Compain (OMF), and Don Cormack.

A few days before the fall of Phnom Penh, warnings arrived from friends outside the country. When the Khmer Rouge entered the city and it was clear that the foreigners would be leaving, Yourng Soth's immediate family was offered the chance to leave as well. He decided that if all of his family couldn't leave then he too must stay.

He was encouraged by a dear friend to leave all nonessentials behind, including medical supplies, literature, clothing, and food. God would provide all that he needed. This advice probably saved his life. As he was being relocated to his native Kompong Thom, Soth's simple dress and his listing farming skills as his background removed suspicion from him. Although many Cambodian Christians died for their beliefs, Soth's relocation officers never asked about his religion.

Because he had returned to his native Kompong Thom, Soth was known to be a Christian. His home village told him that he and his family would not live because he had served the American imperialist! This frightened him, and he did nothing but pray that God would spare his and his family's lives so that they could serve him. At that time he was able to hide his Bible and read it daily because he was working as a sugar palm worker. He kept God's word tucked inside his pillowcase. Reading it strengthened and encouraged him during this tragic period in Cambodian history.

When asked how the Khmer Rouge years affected his faith, Soth replied that it made it stronger. His most intense time was when one official—Comrade Cheng, a leader of the collective in Kadam Ha, Chhouk Kasarch, Baray—plotted to kill him. Everybody knew about it and warned Soth to be wary. Soth prayed to God for protection. One day another group of Khmer Rouge caught Comrade Cheng and put him to death. Now Soth and his family could breathe easily. This was the way God spared his life. At that time he led three people to Christ—Khiev Vanlong, Dith Savy and Moeung Lamoeuy.

Today Yourng Soth is the leader of the Khmer Evangelical Church throughout the country. He has held leadership positions in

this church since 1990. He and Koeung have eight children ranging in age from fifteen to thirty-two. His children have followed in their parents' faith and serve in various ministries in Phnom Penh. The church has outreach programs for youth, for their immediate neighborhood, and for the provinces. Local congregations of the Khmer Evangelical Church each have men's, women's, youth, and children's groups, to help them accomplish their goal that each congregation plant a new church annually.

Soth believes the greatest asset of the Cambodian church is that it is strong and has a good structural foundation. As Christians develop good study habits and scriptural discernment, they will continue to grow and not become confused by the cults that bring false messages to Cambodia. Prayer with those who have been led astray is also essential.

In discussing how new missionaries can best support the Cambodian church, he says that those who work alongside existing Cambodian congregations and those who seek wisdom and input from Cambodian Christians are probably the most effective. Others who arrive and start churches with foreign pastors, bypassing cultural and historical wisdom, will have a tougher time adjusting. These latter will also be easily deceived by Cambodians who offer to assist their ministries for wrong and often selfish reasons.

Yourng Soth's prayer for Cambodia is that God would give Christians clear understanding of his word and of the true meaning of service. He prays that God would share his light and wisdom and that Cambodians would seek God's will. He also prays for religious freedom, and that the politicians would not make laws that prohibit religious freedom and worship.

Yourng Soth has seen the Lord's hand of protection, provision, and miraculous grace. He has also witnessed the amazing outcomes of a faithful mother's prayer.

សំណុំឯកសារ ៣/១ (មករា ២០០២): ១០៣-១១១



# ជួបជាមួយលោកគ្រូ យង់ សុត

លោកស្រី ដេប៊ី ម៉ាហឺ



*លោក គ្រូ យង់ សុទ្ធ*

នៅក្នុងឆ្នាំ១៩៤៦ ស្ត្រីគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ម្នាក់ឈ្មោះ តូច ហ៊ិន បង្កើតបានកូនប្រុសម្នាក់ បានដាក់ឈ្មោះកូនប្រុសនោះថា យង់ សុត ។ អ្នកនៅជិតខាងមើលងាយចំពោះគ្រួសារនោះខ្លាំងណាស់ដោយព្រោះតែជំនឿរបស់ខ្លួន និងគេមិនសូវរាប់រកប៉ុន្មានទេ នៅក្នុងសហគមន៍ដែលគ្រួសារនោះរស់នៅ ។

នៅពេលនោះមិនមានគ្រូគង្វាល ឬព្រះវិហារនៅខេត្តកំពង់ធំឡើយ គឺយូរៗម្តងមានគ្រូចុះទៅភូមិក្តាមហារ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ នៅក្នុងខេត្តកំពង់ធំ ដូច្នេះម្តាយរបស់គាត់តែងនាំគាត់ទៅចូលរួមធ្វើមហាសន្និបាតស្ទើរតែរាល់ឆ្នាំ នៅសាលារៀនព្រះគម្ពីរតាខ្មៅក្រុងភ្នំពេញ ។ ជួនកាលឪពុករបស់គាត់នាំគាត់ទៅឯវត្ត នៅក្នុងភូមិកំណើតរបស់គាត់រស់នៅនោះផងដែរ។

ទោះបីជាលោកគ្រូ យង់ សុត រស់នៅក្នុងគ្រួសារគ្រីស្ដបរិស័ទ និងបានដឹងរឿងរ៉ាវជាច្រើននៅក្នុងព្រះគម្ពីរ និងចេះច្រៀងចំរៀងសរសើរតម្កើងព្រះក៏ដោយក៏គាត់នៅមិនទាន់ដឹងពិតប្រាកដនៅក្នុងខ្លួនដែរ។ ម្ដាយរបស់គាត់តែងតែអធិស្ឋានសូមឲ្យថ្ងៃមួយ គាត់បានក្លាយជាអ្នកដឹកនាំម្នាក់ដ៏រឹងមាំនៅក្នុងក្រុមជំនុំគ្រីស្ដបរិស័ទ ។ គាត់ស្ដាប់ឮសេចក្ដីអធិស្ឋាននោះ និងពិចារណាចំពោះការងារនោះឯង ហើយមិនចង់ក្លាយជាអ្នកបំរើព្រះឡើយ ។

គាត់បានទៅរៀនបន្តនៅឯកំពង់ចាម ។ គាត់សប្បាយចិត្តណាស់ដោយគាត់បាននៅជាមួយមិត្តភក្តិដែលជាយុវជនដទៃទៀត ហើយនិងទីបំផុតបានរួចខ្លួនចេញពីគ្រួសារគ្រីស្ដបរិស័ទ ។ ទោះបីជាយ៉ាងណាមិត្តសម្លាញ់របស់គាត់ គេគិតតែពីចង់សប្បាយតាមបែបមួយនៃជីវិតជាយុវសិស្សនៅវិទ្យាល័យការស្ដីប្រដៅរបស់ម្ដាយរបស់គាត់ គឺនាំឲ្យជីវិតរបស់គាត់រស់នៅក្នុងជីវិតមួយដែលមានការទទួលខុសត្រូវ និងធ្វើឲ្យគាត់គិតឃើញថាគាត់មិនត្រូវរស់នៅក្នុងជីវិតជាយុវសិស្សនៅក្នុងវិទ្យាល័យ ដែលគ្មានការទទួលខុសត្រូវនោះទេ ។

បន្ទាប់ពីបញ្ចប់ការសិក្សានៅក្នុងឆ្នាំ ១៩៦៨ គាត់បានរៀបការជាមួយស្ត្រីម្នាក់ឈ្មោះ កង គីង ។ ការរៀបចំឲ្យមានប្រពន្ធនោះ គឺម្ដាយរបស់លោកគ្រូសុតជាអ្នករៀបចំទុកដាក់ឲ្យ ព្រោះគាត់ពេញចិត្តចំពោះអ្នកស្រី គីងជាអ្នកជឿលើព្រះយេស៊ូ ។

មិនយូរប៉ុន្មាន លោកគ្រូ សុត បានចេញទៅធ្វើការងារនៅចំការកៅស៊ូនៅខេត្តរតនៈគិរី ។ នៅក្នុងខេត្តនោះគឺជាកន្លែងពិបាករស់នៅ ដោយព្រោះជម្ងឺគ្រុនចាញ់ ហើយឯការងារនោះទៀតសោត ក៏លំបាកណាស់ដែរ ។ គាត់មិនសប្បាយចិត្តក៏សម្រេចចិត្តរត់ចោលការងារនោះ ដែលជាការសម្រេចចិត្តបែបនោះប្រកបដោយគ្រោះថ្នាក់មែនទែន ។

គាត់បានរកឡានឈ្នួល ដើម្បីជិះវិលត្រឡប់មកកំពង់ធំវិញ ។ នៅពេល

ឡានមកជិតដល់កន្លែងឆែកឆេរមួយកន្លែង អ្នកបើកឡានបានសុំឲ្យគាត់ចុះចេញពីឡាន ដើម្បីដើរវាងកន្លែងឆែកឆេរនោះ ហើយណាត់គ្នាទៅជួបនៅខាងមុខ ។ លោកគ្រូសុតត្រូវតែមានសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរក្នុងនាមគាត់ជាកម្មករដែលជាប់ក្នុងកិច្ចសន្យាបំរើការងារនៅក្នុងតំបន់នោះ លើកលែងតែថ្ងៃបុណ្យ ឬ ថ្ងៃឈប់សំរាកទើបគាត់អាចធ្វើដំណើរបាន ។ ប៉ុន្តែពេលនោះអ្នកបើកឡានមិនបានរង់ចាំគាត់ទេ ព្រោះគេខ្លាចទាហានយាមសង្ស័យទើបគេទៅចោលគាត់ ។ ដូច្នេះលោកគ្រូសុតត្រូវបង្ខំចិត្តធ្វើដំណើរវាងកាត់ចូលក្នុងព្រៃយ៉ាងក្រាស់ ដើម្បីគេចពីភ្នែកកងយាមល្បាត ហើយនៅក្នុងព្រៃក្រាស់នោះពោរពេញដោយគ្រោះថ្នាក់ជាទីបំផុត ដូចជា ខ្លា ពស់ និងសត្វសាហាវផ្សេងៗទៀត គាត់ដើរកាត់ព្រៃ កាត់កន្លែងគ្រោះថ្នាក់អស់រយៈពេលជិតមួយព្រឹក ។ គាត់ភ័យខ្លាចយ៉ាងខ្លាំង រកគិតអ្វីមិនឃើញឡើយ ។ សេចក្ដីភ័យខ្លាចចំពោះសេចក្ដីស្លាប់នោះ បានធ្វើឲ្យថ្ងៃមួយជាថ្ងៃដ៏គួរឲ្យរន្ធត់យ៉ាងខ្លាំង ។

គាត់បានដោះមួក ស្បែកជើង ហើយគាត់បានលុតជង្គង់ចុះ អំពាវនាវរកព្រះជាម្ចាស់ដើម្បីសុំការអត់ទោស ។ គាត់បានសន្យាជាមួយព្រះជាម្ចាស់ថាគាត់នឹងបំរើព្រះអង្គ បើសិនជាគាត់មានជីវិតរស់នៅ ព្រមទាំងទូលសូមឲ្យព្រះអង្គទទួលគាត់ផង បើគាត់ស្លាប់ទៅនោះ ។ ស្រាប់តែគាត់មានសេចក្ដីសុខនៅក្នុងចិត្តភ្លាមមួយរំពេច ហើយគាត់បានដឹងភ្លាមថា ពេលនោះ គឺជាពេលដែលព្រះឆ្លើយតបចំពោះសេចក្ដីអធិស្ឋានរបស់ម្ដាយរបស់គាត់ ។ ឱកាសនោះក៏ជាចំណុចចាប់ផ្ដើមធ្វើឲ្យគាត់នឹកឃើញព្រះគុណរបស់ព្រះ និងការផ្គត់ផ្គង់របស់ព្រះអង្គចំពោះជីវិតរបស់គាត់ ។

គាត់ពាក់មួក ស្បែកជើង ហើយដើរចេញពីព្រៃ លែងមានសេចក្ដីភ័យខ្លាច លែងគិតថាគាត់កំពុងនៅតែឯងទៀតឡើយ ។ នៅពេលប្រហែលដប់នាទី គាត់បានឃើញផ្លូវមួយ ហើយនៅតាមផ្លូវនោះ គាត់បានឃើញបុរស

ម្នាក់កំពុងជិះកង់នៅពីក្រោយគាត់ ។ ពេលនោះ លោកគ្រូ សុត ចាប់ផ្ដើមមានអារម្មណ៍ធូរស្រាលបន្តិច ហើយក៏ចាប់ផ្ដើមសង្ស័យថា បុរសម្នាក់នេះប្រហែលជាដឹងថា គាត់រត់ចោលការងារ ហើយមកចាប់គាត់ឲ្យត្រឡប់ទៅវិញទេដឹង ។ គាត់ចង់សួរបុរសនោះថាតើលោក មកតាមខ្ញុំឲ្យទៅវិញ ប៉ុន្តែគាត់មិនសួរទេ ។ បុរសម្នាក់នោះក៏បបួលឲ្យ លោកគ្រូ សុត ឡើងជិះកង់ជាមួយគាត់ ហើយប្រាប់ទៀតថាមិនបាច់ខ្លាចទេ ។ លោកគ្រូ សុត នៅតែមានអារម្មណ៍មិនសូវស្រួលក្នុងចិត្តដដែល ប៉ុន្តែគាត់អស្ចារ្យក្នុង ចិត្តមែនទែននៅពេលដែលគាត់និយាយគ្នាជាមួយបុរសនោះ ហាក់បីដូចជាបុរសនោះដឹងមុនថា គាត់បំរុងសួរអ្វីទៅហើយ ។ គាត់នេះធ្វើឲ្យគាត់កាន់តែមានទំនុកចិត្ត ហើយគាត់ក៏ព្រមឡើងជិះកង់ជាមួយបុរសនោះ ។ ពួកគាត់ទាំងពីរធ្វើដំណើរដោយជិះកង់នោះអស់រយៈពេលជាច្រើនម៉ោង ។

បុរសចម្លែកដ៏អាថ៌កំបាំងនោះបាននិយាយប្រាប់ពីរបៀបធ្វើដំណើរតាមបែបផ្សេងៗប្រាប់ដល់គាត់ជាមុន ។ គាត់បាននិយាយអះអាងប្រាប់ដល់លោកគ្រូ សុត ថា បើឡានជិះមិនបាន ឬបើឡានគេមិនព្រមឲ្យគាត់ជិះនោះគាត់អាចស្នាក់នៅមួយយប់ នៅក្នុងកន្លែងរបស់បុរសអាថ៌កំបាំងនោះបាន នេះជាការអះអាងដែលគាត់បានឮបុរសនោះប្រាប់គាត់ ។ បុរសនោះបានលើកដៃចង្អុលបង្ហាញពីផ្ទះ មានលាបពណ៌ស្អាតមួយ ដែលនៅមិនឆ្ងាយប៉ុន្មាននៅតាមផ្លូវនោះ ។ បុរសអាថ៌កំបាំងនោះក៏ចង្អុលបង្ហាញឡានដែលឈប់នៅខាងមុខនោះភ្លាម "នុ៎ះឡាន ទៅសួរគេមើល តើគេឲ្យទៅទេ?" ពេលនោះលោកគ្រូ សុត ចុះពីលើកង់រត់សំដៅទៅឡាននោះភ្លាម ដោយគិតថាចាំសួរឲ្យដឹងពីម្ចាស់ឡានថាតើគេព្រមឲ្យគាត់ទៅឬក៏អត់ សឹមមកលាបុរសនោះវិញ ។ គ្រាន់តែទៅដល់ឡានភ្លាម គេក៏ជួសជុលឡាននោះរួចភ្លាមដែរ ហើយគាត់បានសួរម្ចាស់ឡានថា " ម៉េចមកចោលខ្ញុំ?" បើមិនឲ្យមកចោលយ៉ាងម៉េច ព្រោះបើហ៊ានឈប់នៅចាំជាក់ប្លួនឯង ទាហានដែលនៅយាម

ទីនោះគេនឹងបាញ់បំបែកកង់ឡាន" ពេលនោះគេក៏រុញលោកគ្រូ សុត ឲ្យឡើងជិះឡានដោយគាត់មិនបានមានឱកាសមកជំរាបលាបុរសនោះសោះ ។ ប៉ុន្តែដល់លោកគ្រូសុតខំងាករកមើលទាំងចិត្តសោកស្តាយដោយមិនបានជំរាបលាបុរសនោះ ស្រាប់តែបាត់ស្រមោលបុរសជិះកង់នោះ ព្រមទាំងផ្ទះដែលគាត់បង្ហាញនោះក៏លែងមើលឃើញទៀត មើលឃើញតែជាខ្ទមតូចៗនៅតាមបណ្តោយថ្នល់ទៅវិញ ។ ពេលនោះលោកគ្រូសុតនឹកស្ងើចអស្ចារ្យក្នុងចិត្តតែម្នាក់ឯង ដោយគិតថាបុរសនោះប្រាកដជាទេវតារបស់ព្រះជាម្ចាស់ហើយ ។

មុនពេលមកនៅក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៦៩ លោកគ្រូសុតនិងប្រពន្ធរបស់គាត់បានធ្វើស្រែនៅក្នុងខេត្តកំពង់ធំ ។ ការនេះមុនដំបូងគាត់មានការពិបាក ពីព្រោះគាត់ជាសិស្សសាលាដែលគ្មានបទពិសោធន៍ក្នុងការធ្វើស្រែចំការនោះប៉ុន្មានទេ ។ ប៉ុន្តែទោះបីជាមានការប្រឆាំង មានចោរលួចច្រូតដើមស្រូវឲ្យគោក្របីស៊ី និងមានការចំអកឡកឡឺយដោយព្រោះជំនឿរបស់ខ្លួនពីសំណាក់ពួកអ្នកស្រុកក៏ដោយ គ្រួសាររបស់គាត់ចេះរបៀបដាំដំណាំផ្សេងៗ ។ មានពេលមួយមានការសប្បាយលាយទុក្ខ នៅពេលដែលកំពុងសប្បាយនូវអ្វីដែលព្រះជាម្ចាស់ប្រទានពរឲ្យគាត់ដ៏អស្ចារ្យបំផុតនៅពេលរដូវចំរូត តែផ្ទុយទៅវិញម្តាយក្មេករបស់គាត់មិនសូវសប្បាយចិត្តឲ្យកូនស្រីរបស់គាត់រៀបការជាមួយអ្នកជឿព្រះយេស៊ូប៉ុន្មានទេ ។ គាត់មិនសូវចូលចិត្តអ្នកជឿព្រះយេស៊ូ ។ ម្តាយក្មេកគំរាមនឹងដោះយករបស់របរពីកូនស្រីរបស់គាត់ បើកូននោះមិនព្រមចាកចេញពីប្តី និងមិនព្រមលះបង់ជំនឿទេនោះ ។ អ្នកស្រី គីង ព្រមប្រគល់នូវអ្វីៗទាំងអស់ដែលជារបស់របរ (ដូចជាខ្សែក កងដៃ កងជើង ហូល ផាមួង) ដែលម្តាយចែកឲ្យនោះទៅឲ្យម្តាយវិញ ហើយទុកចិត្តព្រះអម្ចាស់ពេញទីសំរាប់សេចក្តីត្រូវការផ្សេងៗរបស់គាត់ ។

នៅក្នុងឆ្នាំ១៩៧០ លោកគ្រូ យង់ សុត បានចូលថ្វាយបង្គំព្រះ នៅ

ព្រះវិហារ បេថានីអន្តរជាតិ ។ នៅទីនោះលោក នរម៉ាន អិនទ្ស និង ម៉ារីអិន ជាបេសកជន និងជាគ្រូគង្វាលព្រះវិហារបេថានីខាងផ្នែកក្រុមជំនុំអន្តរជាតិ ហើយលោកទាំងពីរជំរុញលើកទឹកចិត្តលោកគ្រូសុតយ៉ាងខ្លាំង ។ នៅក្នុងឆ្នាំ ១៩៧២ គាត់ចាប់ផ្តើមចូលរៀនសាលាព្រះគម្ពីរនៅក្រុងតាខ្មៅរយៈពេលបី ឆ្នាំ។ ក្រោយមកគាត់ជាក្លាយជាគ្រូជំនួយនៅក្នុងក្រុមជំនុំ សារិបតា ដែលជួយផ្នែកការងារយុវជន និងផ្នែកផ្សាយដំណឹងល្អ ។ នៅពេលនោះក្រុមជំនុំជាច្រើននៅក្នុងប្រទេសកម្ពុជា ហើយក៏មានបេសកជនដែលមានជំនឿយ៉ាងស្មោះត្រង់ដូចជា លោកអេឌី បឺសប់(អង្គការទស្សនៈ ពិភពលោក) មែល គ្រេវិន លោក ជីន ហាល អាលីស កុំបាំង (OMF) ហើយនិង ដន កុំម៉ាក ។

មុនពេលទីក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ខ្មែរក្រហមពីរបីថ្ងៃ មានមិត្តភក្តិនៅខាងក្រៅប្រទេសបានព្រមានប្រាប់ឲ្យដឹងពីរឿងនេះ ។ នៅពេលដែលខ្មែរក្រហមចូលទៅក្នុងទីក្រុងនោះ យើងដឹងច្បាស់ថា ជនបរទេសត្រូវចាកចេញពីប្រទេស នៅពេលនោះគ្រួសាររបស់លោកគ្រូ សុត បានទទួលនូវការអញ្ជើញឲ្យចេញក្រៅប្រទេសដែរ ។ គាត់បានសម្រេចចិត្តថា បើសិនក្រុមគ្រួសាររបស់គាត់ទាំងអស់បានទៅទាំងអស់គ្នា ទើបគាត់ព្រមទៅ តែបើមិនអាចទៅទាំងឪពុកម្តាយរបស់គាត់ទេនោះ គាត់សម្រេចថា គាត់មិនព្រមទៅទេ ។

មិត្តសម្លាញ់របស់គាត់បានជំរុញលើកទឹកចិត្តឲ្យគាត់ចោលរបស់របរទាំងប៉ុន្មានកុំឲ្យខ្វល់ខ្វាយអ្វីឡើយ ដូចជាថ្នាំពេទ្យ ខិត្តប័ណ្ណ សម្លៀកបំពាក់ និងចំណីអាហារ ។ ព្រះជាម្ចាស់នឹងប្រទានឲ្យនូវអ្វីដែលគាត់ត្រូវការ ។ ការផ្តល់ដំបូន្មាននេះអាចជួយឲ្យសង្គ្រោះជីវិតរបស់គាត់បាន ។ នៅពេលដែលគាត់វិលត្រឡប់ទៅដល់ស្រុកកំណើតរបស់គាត់នៅឯកំពង់ធំវិញ គាត់នៅសល់តែសម្លៀកបំពាក់សាមញ្ញ ហើយគាត់បានចុះឈ្មោះជាអ្នកធ្វើ

ស្រែចំការ ដោយការដែលគាត់មានជំនាញក្នុងការធ្វើស្រែចំការនោះ ទើបខ្មែរក្រហមមិនសង្ស័យគាត់ជាអ្នកធ្វើការនៅភ្នំពេញ ។ ទោះជាយ៉ាងណាក៏ដោយ គ្រីស្ទបរិស័ទខ្មែរជាច្រើននាក់បានស្លាប់ ដោយព្រោះតែជំនឿរបស់ខ្លួន តែចំពោះគាត់មេកងរបស់គាត់ គេមិនដែលសួរនាំគាត់អំពីជំនឿសាសនារបស់គាត់ឡើយ ។

ដោយសារតែអ្នកស្រុកកំណើតរបស់គាត់ គេស្គាល់ថា គ្រូសុត ជាអ្នកជឿព្រះយេស៊ូនោះ គ្រាន់តែគាត់ និងក្រុមគ្រួសារទៅដល់ភូមិកំណើតភ្លាម មានគេមកប្រាប់ថា គ្រួសារសុតឯងមិនរស់ទេ! ព្រោះគេដឹងថាគ្រួសារសុតឯងជាអ្នកបំរើឲ្យចក្រពត្តិអាមេរិក! ។ គ្រាន់តែឮពាក្យនេះភ្លាមគ្រូសុត និងគ្រួសារភ័យជាខ្លាំង ហើយពួកគាត់តែងតែអធិស្ឋានសូមព្រះជួយការពារ និងទុកជីវិតដើម្បីបានរស់នៅបំរើព្រះអង្គ ។ កាលណោះគ្រូសុតបានលាក់គម្ពីរទុកក្នុងស្រោមខ្នើយ ហើយគាត់អាចមានឱកាសអានព្រះបន្ទូលរៀងរាល់ថ្ងៃ ព្រោះគាត់ជាអ្នកធ្វើត្នោត ។

នៅពេលដែលយើងសួរគាត់ថា តើនៅសម័យខ្មែរក្រហមមានអ្វីដែលធ្វើឲ្យមានការប៉ះពាល់ដល់ជំនឿរបស់គាត់ទេ គាត់ឆ្លើយរយៈពេលនោះកាន់តែធ្វើឲ្យគាត់មានជំនឿកាន់តែរឹងមាំឡើងថែមទៀត ។ ពេលដ៏លំបាកយ៉ាប់យឺតបំផុតរបស់គាត់នោះ នៅពេលដែលមេខ្មែរម្នាក់ព្យាយាមរកសម្លាប់គាត់ ។ អ្នកនោះឈ្មោះ សម ចេង ជាប្រធានសហករណ៍ក្តាមហារ ឃុំ ឈូកខ្សាច់ ស្រុក បារាយនោះ ហើយពេលនោះ សមមិត្ត ចេង រៀបចំគម្រោងការសម្លាប់គ្រូសុត មានប្រជាជនមូលដ្ឋានបានដឹងពីការនោះ គេបានមកប្រាប់គាត់ឲ្យប្រយត្ន័ខ្លួន ។ ប៉ុន្តែគ្រូសុតមានតែការអធិស្ឋានសុំឲ្យព្រះជួយ។ នៅថ្ងៃមួយមានខ្មែរក្រហមថ្នាក់លើមួយក្រុមទៀត មកចាប់មិត្តចេង យកទៅសម្លាប់បាត់ទៅ ទើបពេលនោះគ្រូសុត និងគ្រួសារអាចមានជីវិតរស់នៅរហូតមក ។ នេះគឺជាព្រះអម្ចាស់បានការពារគាត់យ៉ាងពិតប្រាកដ ។ នៅក្នុង

ពេលនោះគ្រូ សុត ក៏បាននាំបងប្អូនថ្វាយខ្លួនជឿដល់ព្រះចំនួនបីនាក់ដែរ គឺលោក ខៀវ វ៉ាន់ឡុង អ្នកគ្រូ ឱត សារី និង អ្នកស្រី មឿងឡាមើយ ។

សព្វថ្ងៃនេះលោកគ្រូ យង់ សុត ជាអ្នកដឹកនាំដល់ក្រុមជំនុំដំណឹងល្អខ្មែរទូទាំងប្រទេស ។ គាត់មានតួនាទីជាអ្នកដឹកនាំ តាំងពីឆ្នាំ ១៩៩០ ។ គាត់ព្រមទាំងប្រពន្ធគាត់ មានកូន៨នាក់ ដែលមានអាយុពី ១៥ រហូតដល់អាយុ ៣២ឆ្នាំ ។ កូនរបស់គាត់ទាំងអស់សុទ្ធជាអ្នកជឿព្រះយេស៊ូ ហើយមានព័ន្ធកិច្ចផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ ។ ក្រុមជំនុំមានកម្មវិធីសំរាប់ផ្សាយដំណឹងល្អដល់យុវជន សំរាប់អ្នកនៅជិតខាង និងនៅតាមបណ្ដាខេត្តនានា ។ ក្រុមជំនុំគ្រីស្ទបរិស័ទដំណឹងល្អខ្មែរ ក៏មានរចនាសម្ព័ន្ធជាក្រុមស្ត្រី ក្រុមបុរស ក្រុមយុវជន និងក្រុមកុមារផងដែរ ដើម្បីសម្រេចផែនការផ្សាយដំណឹងល្អ បង្កើតក្រុមជំនុំថ្មីថែមទៀតរាល់ឆ្នាំ ។

លោកគ្រូ សុត ជឿលើភាពរឹងមាំរបស់ក្រុមជំនុំខ្មែរ ត្រង់ចំណុចរឹងមាំ និងអាចឈរនៅជាក្រុមជុំនុំរៀបរយបាន ។ ក្នុងនាមជាគ្រីស្ទបរិស័ទត្រូវអភិវឌ្ឍផ្នែកទម្លាប់នៃការសិក្សារៀនសូត្រ និងការសង្កេតឲ្យស្គាល់ផ្នែកខាងឯវិញ្ញាណ នោះគេនឹងរីកចំរើនល្អតលាស់ ហើយមិនវង្វេងដោយព្រោះតែពួកខុសឆ្គង ដែលគេបាននាំមកនូវព្រះរាជសារមិនត្រឹមមកកម្ពុជានោះឡើយ ។ ការអធិស្ឋានចំពោះអ្នកដែលទទួលនូវការដឹកនាំឲ្យវង្វេងនោះ គឺជាការសំខាន់។

ចំពោះការពិភាក្សាថា តើបេសកជនថ្មីៗអាចជួយអ្វីប្រសើរបំផុតដល់ក្រុមជំនុំកម្ពុជា? គាត់និយាយថាចំពោះអ្នកទាំងឡាយដែលកំពុងធ្វើការជាមួយក្រុមជំនុំខ្មែរដែលមានរួចហើយនោះ អ្នកនោះត្រូវខំស្វែងរកគតិបណ្ឌិត និងការរួមចំណែកផ្តល់យោបល់ពីក្រុមជំនុំខ្មែរនោះ គឺមានប្រសិទ្ធិភាពជាទីបំផុត ។ ចំពោះអ្នកទាំងឡាយណាដែលមកដល់ ហើយចាប់ផ្តើមបង្កើតក្រុមជំនុំហើយមានគ្រូគង្វាលជាជនបរទេសនោះ ហើយមិនបានយល់ពីទំនៀមទំលាប់ និងប្រវត្តិសាស្ត្ររបស់ខ្មែរនោះគឺមានការពិបាកក្នុងការ

សម្រួលសម្រួលឲ្យចូលធ្លុងគ្នាណាស់ ។ ពួកគេតែងតែទទួលនូវការបោកបញ្ឆោតយ៉ាងងាយស្រួល ពីអ្នកដែលជួយការងាររបស់គេនោះ ដោយព្រោះមានការយល់គ្នាមិនច្បាស់ ។

លោកគ្រូ យង់ សុត អធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រទានការយល់ដឹងពីព្រះបន្ទូលរបស់ព្រះអង្គដល់ក្រុមជំនុំនៅកម្ពុជា ហើយគេយល់ដឹងយ៉ាងច្បាស់ពីអត្ថន័យនៃការបំរើ ។ គាត់អធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រទានពន្លឺ និងគតិបណ្ឌិតឲ្យដល់ប្រជារាស្ត្រកម្ពុជា ដើម្បីឲ្យគេស្វែងរកបំណងព្រះហឫទ័យរបស់ព្រះអង្គ ហើយក៏សូមមានសិទ្ធិសាសនា និងសូមឲ្យអ្នកនយោបាយទាំងអស់ កុំឲ្យគេបង្កើតច្បាប់ហាមប្រាមសិទ្ធិសាសនា និងការថ្វាយបង្គំព្រះនោះឡើយ ។

លោកគ្រូ យង់ សុត បានឃើញព្រះគុណអស្ចារ្យនៃព្រះហស្តការពារ និងការផ្គត់ផ្គង់របស់ព្រះអម្ចាស់ ។ គាត់ក៏បានឃើញការអស្ចារ្យពីលិទ្ធផលនៃការអធិស្ឋានរបស់ម្ដាយគាត់ ដែលបានអធិស្ឋានសំរាប់ជីវិតរបស់គាត់ ។